# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

# (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## វគ្គបណ្តុះបណ្តាលបឋមសម្រាប់គ្រូសហគមន៍

## រយៈពេល ១០ ថ្ងៃ

# សៀវភៅសម្រាប់អ្នកសម្របសម្រួល




ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ខែតុលា ឆ្នាំ២០០៥

# ខ្លឹមសារសំខាន់ៗ

| ថ្ងៃ | | | | ទំព័រ |
|---|---|---|---|---|
| ១ | | គោលបំណង និងវត្ថុបំណង នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ | | ៧ |
| ១ | | សេចក្តីសង្ខេបអំពីរចនាសម្ព័ន្ធ នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ | | ៨ |
| | **ដំណាក់កាលបង្រៀន** | **ខ្លឹមសារប្រធានបទ នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ ថ្ងៃ** | **រយៈពេល (នាទី)** | |
| ១ | ១ | ១ក. ការណែនាំអំពីក្រុមសម្របសម្រួល និងគ្រូសហគមន៍<br>១ខ. ការណែនាំអំពីវគ្គសិក្សា | ៦០ | ៩ |
| | ២ | របៀបកុមាររៀន (VIPP)<br>តើកុមារបានដឹងអ្វីខ្លះមុននឹងពួកគេចូលសាលារៀន?<br>តើពួកគេរៀនអ្វីៗទាំងនោះដោយរបៀបណា? | ៩០ | ១០ |
| | ៣ | ប្រភេទនៃការសិក្សា-ចំណេះដឹង បំនិន ឥរិយាបថ/តំលៃ | ៦០ | ១១ |
| | ៤ | កុមារទាំងអស់គឺខុសប្លែកពីគ្នា (VIPP)<br>តើអ្វីទៅដែលធ្វើអោយកុមារមានលក្ខណៈខុសប្លែកពីគ្នា? | ៦០ | ១២ |
| | ៥ | ការយល់ដឹង និងការបង្រៀនសិស្សមានលក្ខណៈខុសៗគ្នានៅក្នុងថ្នាក់រៀន | ៤៥ | ១៣ |
| | | | **៥.១៥** | |
| ២ | ១ | ដំណាក់កាល លូតលាស់របស់កុមារ រហូតដល់អាយុ១១ឆ្នាំ<br>មូលហេតុចាំបាច់ដែលតំរូវអោយគ្រូត្រូវស្វែងយល់ពីការលូតលាស់របស់កុមារ | ៧៥ | ១៥ |
| | ២ | ដំណាក់កាល នៃការសិក្សារបស់កុមារៈ ភាពឃើញជាក់ស្តែង-និមិត្តសញ្ញា-អរូបី | ៦០ | ១៧ |
| | ៣ | តួនាទី ភាសា ក្នុងការសិក្សាៈ ការប្រើប្រាស់វិធី ធ្វើ (do) ពិភាក្សា (talk) កត់ត្រា (record) | ៧៥ | ២០ |
| | ៤ | ការកសាងបន្ថែមទៅលើអ្វីដែលសិស្សបានដឹងនៅពេលបង្រៀនខ្លឹមសារឬ បញ្ញត្តិថ្មី | ៩០ | ២២ |
| | ៥ | ការអាន "ការសួរបំផុសគំនិតរបស់កុមារ" ដកស្រង់ពី TGL | ៣០ | ២៤ |

| | | | | |
|---|---|---|---|---|
| | ៦ | ការវាយតំលៃការសិក្សា<br>តើយើងដឹងដោយរបៀបណាថា សិស្សបានរៀនអ្វីមួយ? | ៦០ | ២៤ |
| | ៧ | ការត្រួតពិនិត្យឡើងវិញ នូវខ្លឹមសារសំខាន់ៗ នៅថ្ងៃទី១ និង ថ្ងៃទី២ | ១៥ | ២៥ |
| | | | ៦.៤៥ | |
| ៣ | ១ | កម្មវិធីសិក្សានៅសាលាបឋមសិក្សាកម្ពុជា-ផ្នែកសំខាន់ៗ | ៦០ | ២៧ |
| | ២ | មុខវិជ្ជា និងម៉ោងបង្រៀន នៅសាលាបឋមសិក្សាកម្ពុជា | ៦០ | ២៨ |
| | ៣ | សៀវភៅសិស្ស និងសៀវភៅគ្រូ របស់ក្រសួង ពីថ្នាក់ទី១-៦ | ១៨០ | ២៩ |
| | ៤ | ការគាំទ្រ និងការធ្វើអធិការកិច្ចគ្រូបង្រៀន ពីក្រសួងអប់រំ | ៤៥ | ៣៤ |
| | ៥ | ប្រព័ន្ធកម្រងសាលារៀន និងការគាំទ្រគ្រូបង្រៀន | ៤៥ | ៣៤ |
| | ៦ | ការគាំទ្រគ្រូបង្រៀន តាមរយៈគំរោងអេស្កាប់ | ២០ | ៣៦ |
| | | | ៦.៥០ | |
| ៤ | ១ | ការបង្ហាញបញ្ញត្តិនៃ*មេរៀន*នៅសាលារៀនរដ្ឋ | ១៥ | ៣៨ |
| | ២ | ការធ្វើអត្ថសញ្ញាណផ្នែកនៃមេរៀន | ៤៥ | ៣៩ |
| | ៣ | ការបង្កើតនូវកិច្ចតែងការបង្រៀន ហើយប្រៀបធៀបជាមួយ<br>កិច្ចតែងការគំរូរបស់ក្រសួងអប់រំ | ៧៥ | ៤០ |
| | ៤ | ការបង្ហាញលំនាំបង្រៀនមេរៀនទី១- គណិតវិទ្យា | ៧៥ | ៤១ |
| | ៥ | ការបង្ហាញលំនាំបង្រៀនមេរៀនទី២- ភាសាខ្មែរ | ៧៥ | ៤៣ |
| | ៦ | ការប្រើប្រាស់សម្ភារដើម្បីជំរុញការបង្រៀន និងរៀន | ៤៥ | ៤៤ |
| | | | ៥.៣០ | |
| ៥ | ១ | បច្ចេកទេសបង្រៀនTGL ទី១ (ការសួរសំនួរ) ការសំដែងតួទី១<br>និងទី២ | ៣០ | ៤៧ |
| | ២ | ការវិភាគជាក្រុម អំពីការសំដែងតួទី១ និងទី២ | ៦០ | ៤៧ |
| | ៣ | ល្បែងសិក្សា-សកម្មភាពសត្វ (អនុវត្តការអាន សំដែងវិនាដកម្ម) | ១៥ | ៤៨ |
| | ៤ | បច្ចេកទេសបង្រៀន TGL ទី១ ការសំដែងតួទី៣ | ៣០ | ៤៨ |
| | ៥ | ការវិភាគជាក្រុម អំពីការសំដែងតួទី៣ | ៦០ | ៤៨ |
| | ៦ | ល្បែងសិក្សា-បកដំឡូងក្តៅ (អនុវត្តការអាន) | ១៥ | ៤៩ |
| | ៧ | កិច្ចការតាមក្រុមតូចៗដើម្បីអនុវត្តបំនិនសរសេរសំនួរ | ៦០ | ៥០ |
| | ៨ | ការសន្និដ្ឋាន និងការសង្ខេបគំនិតសំខាន់ៗ នៅថ្ងៃទី៥ | ១៥ | ៥០ |

| | | | | |
|---|---|---|---|---|
| | | | ៤.៤៥ | |
| ៦ | ១ | បច្ចេកទេសបង្រៀន TGL ទី២ ( ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី១ | ៤៥ | ៥១ |
| | ២ | ការវិភាគជាក្រុម អំពីការសំដែងតួទី១ | ៤៥ | ៥២ |
| | ៣ | ល្បែងសិក្សា ( លេខក្នុងចិត្ត ការគណនាប្រមាណវិធីទាំង៤) | ១៥ | ៥២ |
| | ៤ | បច្ចេកទេសបង្រៀន TGL ទី២ ( ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី២ | ៣០ | ៥៣ |
| | ៥ | ការវិភាគជាក្រុម អំពីការសំដែងតួទី២ | ៤៥ | ៥៣ |
| | ៦ | ល្បែងសិក្សា- ដូមីណូ ( គណិតវិទ្យា- ការគណនាប្រមាណវិធីទាំង៤) | ៣០ | ៥៤ |
| | ៧ | បច្ចេកទេសបង្រៀន TGL ទី២ ( ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី៣ | ៤៥ | ៥៥ |
| | ៨ | ការវិភាគជាក្រុម អំពីការសំដែងតួទី៣ | ៤៥ | ៥៥ |
| | ៩ | ល្បែងសិក្សា-បង្កើតរូបសត្វដោយប្រើរូបធរណីមាត្រ | ១៥ | ៥៦ |
| | ១០ | អាន និងពិភាក្សា "សិស្សធ្វើការជាក្រុម/ដៃគូ" ដកស្រង់ពី TGL | ៣០ | ៥៦ |
| | ១១ | ការសន្និដ្ឋាន និងការសង្ខេបគំនិតសំខាន់ៗ របស់ថ្ងៃទី៦ | ៤៥ | ៥៧ |
| | | | ៦.៣០ | |
| ៧ | ១ | បច្ចេកទេសបង្រៀន TGL ទី៣ ( ការប្រើប្រាស់បរិស្ថាន) ការសំដែងតួទី១ និង ការវិភាគ | ៤៥ | ៥៨ |
| | ២ | ល្បែង-ត្រីជាប់ក្នុងសំណាញ់ | ១៥ | ៦០ |
| | ៣ | បច្ចេកទេសបង្រៀន TGL ទី៣ ( ការប្រើប្រាស់បរិស្ថាន) ការសំដែងតួទី២ | ៦០ | ៦០ |
| | ៤ | ការវិភាគជាក្រុម អំពីការសំដែងតួទី២ | ៣០ | ៦១ |
| | ៥ | ការត្រួតពិនិត្យឡើងវិញនូវល្បែងសិក្សាទាំងអស់កន្លងមក | ៣០ | ៦២ |
| | ៦ | អាន និងពិភាក្សា "ការរៀបចំជាស្រេចដើម្បីចាប់ផ្តើម និងការស្រូបយកចំណេះដឹងថ្មី" ដកស្រង់ពី TGL | ៣០ | ៦២ |
| | ៧ | ល្បែងសិក្សា- ល្បែងរកពាក្យ ( ការបង្កើតពាក្យ សិក្សាពាក្យ) | ១៥ | ៦២ |
| | ៨ | បច្ចេកទេសបង្រៀន TGL ទី៤ ( ការប្រើប្រាស់ភាសារបស់កុមារ) សកម្មភាពទី១ | ៣០ | ៦៣ |

| | | | | |
|---|---|---|---|---|
| | ៩ | បច្ចេកទេសបង្រៀន TGL ទី៤ (ការប្រើប្រាស់ភាសារបស់កុមារ) សកម្មភាពទី២ | ៣០ | ៦៤ |
| | ១០ | ការអានៈ " ការប្រើប្រាស់ភាសារបស់កុមារ-កង់" ដកស្រង់ពី TGL | ៣០ | ៦៤ |
| | ១១ | ការសន្និដ្ឋាន-ត្រួតពិនិត្យលើបច្ចេកទេសទាំង៤ឡើងវិញ | ៣០ | ៦៥ |
| | | | **៥.៤៥** | |
| ៨ | ១ | កញ្ចប់ធនធានសម្ភារសម្រាប់គ្រូសហគមន៍ | ៤៥ | ៦៦ |
| | ២ | ល្បែងសិក្សា-បញ្ញត្តិសំខាន់១៣ | ៤៥ | ៦៨ |
| | ៣ | ល្បែងសិក្សាសម្រាប់គណិតវិទ្យា | ៩០ | ៧០ |
| | ៤ | ល្បែងសិក្សាសម្រាប់ភាសាខ្មែរ | ៩០ | ៧២ |
| | | | **៤.៣០** | |
| ៩ | ១ | តើអ្វីទៅដែលធ្វើអោយក្លាយជាគ្រូបង្រៀនល្អ? សិក្ខាកាមប្រើបទពិសោធន៍ដើម្បីសរសេរអធិប្បាយពីគ្រូម្នាក់ដែលគាត់ចូលចិត្ត | ៤៥ | ៧៤ |
| | ២ | ២.1 គំនិតអំពីបរិស្ថានសាលាកុមារមេត្រី ២.២ សិទ្ធិកុមារ | ៦០ | ៧៥ |
| | ៣ | គ្រូបង្រៀនគឺជាគំរូល្អនៅក្នុងថ្នាក់រៀន | ៣០ | ៧៧ |
| | ៤ | អ្នកសិក្សាខុសប្លែកពីគ្នា-ការប្រើប្រាស់វិធីសាស្ត្រប្លែកគ្នា | ៤៥ | ៧៩ |
| | ៥ | ការគ្រប់គ្រងថ្នាក់រៀន-ក្បួនច្បាប់ វិន័យ ការសរសើរ ការស្តីបន្ទោស | ៣០ | ៨០ |
| | ៦ | ការរៀបចំបន្ទប់រៀនតាមបែបសិស្សមជ្ឈមណ្ឌល | ៤៥ | ៨១ |
| | ៧ | ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់គ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋ | ៩០ | ៨១ |
| | ៨ | កិច្ចការគ្រប់គ្រងថ្នាក់រៀន របស់គ្រូបង្រៀន និងសិស្ស | ៣០ | ៨៤ |
| | | | **៦.១៥** | |
| ១០ | ១ | ស្ថាប័នរបស់សាលា និង គោលបំណងរបស់វានៅក្នុងសង្គម | ៣០ | ៨៦ |
| | ២ | អ្នកពាក់ព័ន្ធជាមួយសាលារៀន និង បញ្ញត្តិនៃកម្មសិទ្ធិ | ៦០ | ៨៦ |
| | ៣ | បញ្ញតិនៃកម្មសិទ្ធិ និងការជំរុញកម្មសិទ្ធិ | ៦០ | ៨៨ |
| | ៤ | ការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចសាលារៀន (គណៈកម្មការ ទ្រទ្រង់ សាលារៀន (SSC) កម្មវិធីសកម្មភាពជាអាទិភាព (PAP) | ៦០ | ៨៩ |

| | | | | |
|---|---|---|---|---|
| | **៥** | អភិបាលកិច្ចល្អ-ការទទួលខុសត្រូវ តម្លាភាព ការចូលរួម | ៦០ | ៩០ |
| | **៦** | គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFAC) អាជ្ញាធរ និងការអប់រំមូលដ្ឋាន | ៦០ | ៩៣ |
| | **៧** | ការបិទវគ្គបណ្តុះបណ្តាល | ៣០ | ៩៤ |
| | | | **៦.១៥** | |

# ផែនការសំរាប់ការបណ្តុះបណ្តាល
# គ្រូសហគមន៍រយៈពេល១០ថ្ងៃរបស់គំរោងអេស្កាប់

## ថ្ងៃទី១ ការសិក្សារបស់កុមារ

ថ្ងៃទី១

ដំណាក់កាលបង្រៀនទី១ក: ការណែនាំអោយស្គាល់គ្នា ៣០ នាទី

សមាជិកក្រុមអ្នកសម្របសម្រួលធ្វើការណែនាំខ្លួនគាត់ទៅកាន់ក្រុមទាំងមូលរួច ហើយបែងចែកសិក្ខាកាមជាក្រុមតូចៗតាមលក្ខណៈចៃដន្យដើម្បីស្គាល់គ្នាដោយប្រើប្រាស់ប័ណ្ណរូបភាពមួយគូៗ។ ប័ណ្ណត្រូវបានចែកទៅគ្រប់សិក្ខាកាមហើយម្នាក់ៗត្រូវដើរស្វែងរកអ្នកដែលមានរូបភាពអាចផ្គុំគ្នាបាន បន្ទាប់មកដៃគូត្រូវចំណាយពេល៥នាទីដើម្បីស្វែងរកព័ត៌មានពីគ្នាទៅវិញទៅមកមុននឹងណែនាំគ្នាទៅកាន់ក្រុមផ្សេងៗ។ ចំនួនសិក្ខាកាមកំរិតអតិបរមាគឺ១២នាក់ដែលក្រុមនីមួយៗមានអ្នកសម្របសម្រួលម្នាក់ចាំជួយ។

បញ្ជីឈ្មោះរបស់អ្នកសម្របសម្រួលនិងមុខតំណែងនៅក្នុងអង្គការឬក្រសួងអប់រំត្រូវផ្តល់ទៅអោយសិក្ខាកាម (**ឯកសារទី៤**)។ បញ្ជីឈ្មោះសិក្ខាកាមត្រូវប្រមូលព្រមជាមួយនឹងព័ត៌មានអំពីភូមិ ឃុំ គ្រួសារ និងថ្នាក់ដែលពួកគាត់ត្រូវបង្រៀន (បើសិនជាពួកគាត់បានដឹង) ដើម្បីយកមកវាយកុំព្យូទ័រសំរាប់ចែកជូននៅថ្ងៃទី២។

ថ្ងៃទី១

ដំណាក់កាលបង្រៀនទី១ខ: ការណែនាំអំពីវគ្គបណ្តុះបណ្តាល ៣០ នាទី

អ្នកសម្របសម្រួលប្រើឯកសារសង្ខេបដើម្បីពន្យល់សិក្ខាកាមអំពីគោលបំណងនិងរចនាសម្ព័ន្ធវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃការរំពឹងទុករបស់សិក្ខាកាមនិងការឧបត្ថម្ភពីអេស្កាប់។ អ្នកសម្របសម្រួលជំរាបជូនតាមលំដាប់លំដោយនូវប្រធានបទខាងក្រោម:

**រយៈពេលវគ្គបណ្តុះបណ្តាល**

១០ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង០៧:៣០-១១:៣០ និងរសៀលចាប់ពីម៉ោង១៤:០០-១៦:០០

**គោលបំណង និងវត្ថុបំណងវគ្គបណ្តុះបណ្តាល (ឯកសារទី២)**

រៀបចំគ្រូសហគមន៍អោយបំរើការជាគ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋ(អ្នកសម្របសម្រួលបង្ហាញជូនរចនាសម្ព័ន្ធ

គោលបំណង និងវត្ថុបំណងនៅក្នុងឯកសាររបស់សិក្ខាកាម)។

**ខ្លឹមសារវគ្គបណ្តុះបណ្តាល (ឯកសារទី៣) (ឯកសារទី៤)**

មានសមាសភាគសំខាន់២ (អ្នកសម្របសម្រួលបង្ហាញឯកសារអំពីរចនាសម្ព័ន្ធនៃការបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ)

១. ប្រហែល៤-៥ថ្ងៃផ្តោតទៅលើការសិក្សារបស់កុមារនៅសាលារៀន ការធ្វើការងារនៅសាលារដ្ឋ កម្មវិធីសិក្សាបឋមសិក្សាជាតិ និងការទទួលខុសត្រូវរបស់គ្រូបង្រៀនក្នុងថ្នាក់រៀន។

២. ប្រហែល៥-៦ថ្ងៃផ្តោតទៅលើវិធីបង្រៀននៃបំនិនទាំង៨ពីឯកសារបណ្តុះបណ្តាល TGL របស់ក្រសួង: ការសួរសំនួរ ល្បែងសិក្សា ការគ្រប់គ្រងថ្នាក់រៀន ធនធានបង្រៀន (ការប្រើប្រាស់សម្ភារបរិស្ថានជាធនធានសំរាប់ការបង្រៀន។

**សកម្មភាព**

ការអាន ការពិភាក្សាជាក្រុម បច្ចេកទេសបង្រៀន-រៀន ការលេងល្បែង ការធ្វើផែនការ

**ការរំពឹងទុក**

មានការចូលរួមរាល់ថ្ងៃ ហើយទៀងទាត់ពេលវេលា មានការចូលរួមយ៉ាងសកម្មនូវរាល់សកម្មភាព មានការបំពេញនូវរាល់កិច្ចការដែលបានដាក់ជូន។ អ្នកសម្របសម្រួលពិភាក្សាការរំពឹងទុកទាំងអស់នោះជាមួយសិក្ខាកាមរួចហើយសរសេរចំលើយទាំងនោះដាក់លើផ្ទាំងក្រដាសធំដើម្បីទុកជាបទវិន័យសំរាប់សិក្ខាសាលា។

**ប្រាក់ឧបត្ថម្ភ**

ប្រាក់ឧបត្ថម្ភត្រូវបានបើកជូនចំនួន២ដងគឺនៅដំណាច់៥ថ្ងៃដំបូង និង៥ថ្ងៃចុងក្រោយ។

**ថ្ងៃទី១**

**ដំណាក់កាលបង្រៀនទី២: របៀបកុមាររៀន** **៩០ នាទី**

អ្នកសម្របសម្រួលនិយាយថា: ឥឡូវយើងនឹងចាប់ផ្តើមគិតនិងពិភាក្សាអំពីអ្វីដែលយើងបានដឹងអំពីការសិក្សារបស់កុមារ។ យើងមានសំនួរមួយចំនួនសំរាប់អោយលោក/លោកស្រីធ្វើការពិភាក្សាជាក្រុមតូចហើយសរសេរចំលើយទាំងនោះ។ លោក/លោកស្រីអាចពិភាក្សាពីគំនិតជាមួយនឹងសិក្ខាកាមផ្សេងៗ។ លោក/លោកស្រីនឹងប្រើប័ណ្ណដើម្បីសរសេរគំនិតរបស់ខ្លួនចូល។ ចំពោះប័ណ្ណត្រូវអនុវត្តដូចតទៅ: (១) គំនិត១សំរាប់តែប័ណ្ណ១ (២) សរសេរអោយបានធំនិងច្បាស់ (៣) ជាអតិបរមាត្រូវសរសេរ៣ឬ៤បន្ទាត់នៅលើប័ណ្ណនីមួយៗ។ អ្នកសម្របសម្រួលនឹងជួយលោក/លោកស្រីអោយអនុវត្តទៅតាមសេចក្តីណែនាំ។

**សំនួរ: តើកុមារបានដឹងអ្វីខ្លះរួចទៅហើយនៅមុនពេលពួកគេចូលរៀន?**

សិក្ខាកាមធ្វើការជាក្រុមដើម្បីឆ្លើយសំនួរហើយសរសេរចំលើយតបដាក់លើប័ណ្ណVIPP ។ នៅពេលប័ណ្ណទាំងអស់ត្រូវបានបិទនៅលើក្តារខៀន អ្នកសម្របសម្រួលជួយពួកគាត់ធ្វើចំណាត់ថ្នាក់លើប្រភេទប័ណ្ណទៅតាមក្រុមរួចហើយដាក់ជាឈ្មោះក្រុមដោយប្រើប័ណ្ណដែលមានពណ៌ខុសគ្នា។ បន្ទាប់មកទៀតក្រុមនិមួយៗឡើងបង្ហាញពីគំនិតរបស់ពួកគេទៅកាន់ក្រុមទាំងអស់។

**សំនួរៈ តើពួកគេ(កុមារ) រៀនអ្វីៗទាំងនោះដោយរបៀបណា?**

សិក្ខាកាមពិភាក្សាសំនួរជាក្រុមតូចហើយសរសេរចំលើយនៅលើប័ណ្ណVIPP ។ អ្នកសម្របសម្រួលជួយធ្វើចំណាត់ថ្នាក់ប្រភេទលើចំលើយរបស់ពួកគាត់ដោយសរសេរចំណងជើងនោះនៅលើប័ណ្ណពណ៌ផ្សេង។ រួចហើយក្រុមនីមួយៗឡើងបង្ហាញពីគំនិតរបស់ពួកគេ។ អ្នកសម្របសម្រួលសំយោគបង្ហាញដល់ក្រុមទាំងមូល។

**សេចក្តីសន្និដ្ឋានៈ** អ្នកសម្របសម្រួលបញ្ជាក់ថាការរៀនដែលមានប្រសិទ្ធភាពភាគច្រើនកើតឡើងដោយពុំមានការបង្ហាត់បង្រៀនជាផ្លូវការដោយប្រើសៀវភៅសិស្ស សៀវភៅគ្រូ ការសរសេរដោយមានការរៀបចំផ្សេងៗឡើយ។ ការរៀនបែបនេះគេហៅថា "ការរៀនបែបធម្មជាតិ" ។

**ថ្ងៃទី១**

**ដំណាក់កាលបង្រៀនទី៣ៈ ប្រភេទនៃការសិក្សា ៦០ នាទី**

អ្នកសម្របសម្រួលនិយាយទៅកាន់សិក្ខាកាមថា ឥឡូវនេះខ្ញុំចង់អោយលោក/លោកស្រីគិតអំពីប្រភេទនៃកាសេិក្សាផ្សេងៗដែលកុមាររៀន។ អ្នកសម្របសម្រួលផ្តល់ឧទាហរណ៍៣អំពីប្រភេទផ្សេងៗគ្នានៃការសិក្សាដោយប្រើប្រាស់ប័ណ្ណចំនួន៣ដែលសិក្ខាកាមបានធ្វើពីដំបូង។ ឧទាហរណ៍

*ការស្គាល់ឈ្មោះមនុស្សនៅក្នុងភូមិ*

*ការស្គាល់ពីរបៀបស្លៀកពាក់*

*ការដឹងថាវាមានសារៈសំខាន់ក្នុងការចែករំលែកគ្នានូវអ្វីមួយ*

បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញអោយសិក្ខាកាមនូវប័ណ្ណផ្សេងៗទៀតដែលមានឧទាហរណ៍អំពីវត្ថុផ្សេងទៀតដែលកុមារដឹង (វត្ថុជាច្រើនដកស្រង់មកពីកិច្ចការដែលសិក្ខាកាមបានធ្វើពីដំបូង)។ អ្នកសម្របសម្រួលអោយក្រុមនិមួយៗសម្រេចចិត្តដាក់ឧទាហរណ៍នៃវត្ថុទាំងនោះដែលមានន័យដូចគ្នាទៅតាមផ្នែកនៃឧទាហរណ៍៣ខាងលើ។ នៅចុងបញ្ចប់អ្នកសម្របសម្រួលសួរ ថាតើពួកគាត់យល់ស្របទៅលើការដាក់តាមផ្នែកសំរាប់ក្រុមរបស់គាត់ឬទេ។

*ចំលើយរំពឹងទុក: ចំណេះដឹងត្រូវមានលក្ខណ:ដូចគ្នាទៅនឹងចំណាត់ថ្នាក់ប្រភេទរបស់ក្រសួងអប់រំ (ចំណេះដឹង បំនិនកិរិយាបទ/គុំណៃ)។*

អ្នកសម្របសម្រួលសួរក្រុមទាំងមូល: នៅក្នុងភាសាខ្មែរ តើមានពាក្យប៉ុន្មានដែលមានន័យដូចពាក្យ " know "? ហើយពាក្យណាដែលត្រូវជាមួយក្រុមខាងលើ?

*ដឹង* ដឹង បានរៀន បានលឺពីទីណាមួយ

*ស្គាល់* ធ្លាប់បានឃើញពីមុន ហើយចេះចំណាំ

*យល់* ដឹង និងយល់

*ចេះ* ដឹង និងចេះធ្វើ

*ប៉ិនប្រសប់* ដឹង ហើយធ្វើបានយ៉ាងស្ទាត់ជំនាញ និងរហ័ស

**ថ្ងៃទី១**

**ដំណាក់កាលបង្រៀនទី៤: កុមារទាំងអស់គឺមានភាពខុសប្លែកពីគ្នា ៦០ នាទី**

អ្នកសម្របសម្រួលអោយសិក្ខាកាមគិតអំពីអ្វីដែលធ្វើអោយកុមារមានភាពខុសប្លែកពីគ្នា។ ឧទាហរណ៍ តើអ្វីដែលធ្វើអោយកុមារនៅក្នុងគ្រួសារអ្នកមាននៅភ្នំពេញខុសប្លែកពីកុមារនៅក្នុងគ្រួសារកសិករឬអ្នកប្រមាញ់។ តើអ្វីដែលធ្វើអោយកុមារកម្ពុជាខុសប្លែកពីកុមារនៅអាហ្វ្រិកឬអូស្ត្រាលីឬអាមេរិក។

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមតូចដោយមានប័ណ្ណ VIPP ដើម្បីសរសេរចំលើយចំពោះសំនួរខាងក្រោម

**សំនួរ: តើអ្វីទៅដែលធ្វើអោយកុមារនោះមានភាពខុសប្លែកពីគ្នា? (VIPP)**

*ចំលើយអាចដោយសារ: វប្បធម៌ តំណពូជ បរិស្ថាន ស្ថានភាពសេដ្ឋកិច្ចសង្គម គ្រួសារ សុខភាព អាហារូបត្ថម្ភ ភេទ សញ្ជាតិ...* ។

ក្រុមនីមួយៗបិទប័ណ្ណរបស់ពួកគេនៅលើក្តារខៀនដោយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទ ហើយសាកល្បងកំណត់ឈ្មោះអោយក្រុមប្រភេទនោះដោយសរសេរឈ្មោះសំរាប់ក្រុម(ចំលើយ)នីមួយៗនៅលើក្រដាសពណ៌រួចហើយបង្ហាញលទ្ធផល

របស់គេទៅក្រុមផ្សេងទៀត។

ដើម្បីសរុបបញ្ចប់ អ្នកសម្របសម្រួលត្រួតពិនិត្យឡើងវិញនូវឈ្មោះក្រុមផ្សេងៗដែលសិក្ខាកាមបានជ្រើសរើស។ *ចំលើយអាចជា: សុខភាព គ្រួសារ/ជីវវិទ្យា ស្ថានភាពសេដ្ឋកិច្ច វប្បធម៌ សាសនា ភាសា សញ្ជាតិ ទីកន្លែងដែលពួកគេរស់នៅ សុខភាព (ពិការភាព) បុគ្គលិកលក្ខណៈ និងសមត្ថភាព...។*

មានក្រុមជាច្រើននឹងមានការជ្រើសរើសឈ្មោះក្រុមខុសៗគ្នា ហើយរបៀបនៃការធ្វើចំណាត់ថ្នាក់ក៏ខុសគ្នាផងដែរប៉ុន្តែវាអាចមានលក្ខណៈសមហេតុផលនឹងអាចទទួលយកបាន។ សិក្ខាកាមគួរយល់ដឹងថាមិនមានចំលើយត្រឹមត្រូវតែមួយនោះទេមានន័យថារាល់គំនិតយោបល់ និងរបៀបនៃការឆ្លើយគឺអាចទទួលយកបាន។

**ថ្ងៃទី១**

**ដំណាក់កាលបង្រៀនទី៥: ការស្គាល់នូវភាពខុសគ្នា** **៤៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: ឥឡូវនេះខ្ញុំចង់អោយលោក/លោកស្រីគិតអំពីលទ្ធផលនៃសកម្មភាពចុងក្រោយនេះថាវាមានន័យយ៉ាងដូចម្តេចចំពោះពួកយើងជាគ្រូបង្រៀន។ **សំនួរសំរាប់ក្រុមទាំងមូល: តើវាប្រាប់យើងនូវអ្វីខ្លះអំពីកុមារនៅក្នុងថ្នាក់រៀន?**

ដើម្បីជួយសិក្ខាកាមគិតអំពីសំនួរនេះអ្នកសម្របសម្រួលប្រើរូបភាពពីរខាងក្រោម-រូបភាពមួយអំពីកសិករនិងដំណាំស្រូវហើយរូបភាពមួយទៀតអំពីគ្រូបង្រៀន និងសិស្សនៅក្នុងថ្នាក់រៀន។ អ្នកសម្របសម្រួលសួរថា: តើនឹងមានអ្វីកើតឡើងបើសិនជាកសិករប្រើប្រាស់វិធីដូចគ្នាទៅលើដំណាំស្រូវទាំងអស់? តើការធ្វើបែបនេះនឹងទទួលបានលទ្ធផលយ៉ាងណា? ចំពោះគ្រូបង្រៀនវិញ តើអាចប្រព្រឹត្តទៅលើសិស្សទាំងអស់ដោយវិធីដូចៗគ្នាបានដែរឬទេ? តើការធ្វើបែបនេះនឹងទទួលបានលទ្ធផលយ៉ាងណា?

អ្នកសម្របសម្រួលធ្វើបញ្ជីចំលើយតបរបស់សិក្ខាកាមដាក់លើក្តារខៀន...។

*ចំលើយអាចជា:*

*គ្មាននរណាម្នាក់ដូចគ្នានោះទេ-គ្រប់កុមារទាំងអស់គឺខុសប្លែកពីគ្នា*

*កុមារមានបទពិសោធន៏ខុស១គ្នានៅក្នុងជីវិត*

*កុមារក៏អាចរៀនអ្វីមួយទៅតាមរបៀបខុស១គ្នាផងដែរ*

*គ្រូបង្រៀនគួរតែស្គាល់សិស្សម្នាក់១នៅក្នុងថ្នាក់អោយបានច្បាស់ដើម្បីស្វែងយល់ពីរបៀបដែលពួកគេរៀន និងត្រូវដឹងថាជួយគេដោយរបៀបណា*

*កុមារដែលមិនចេះភាសាខ្មែរអាចមានការលំបាកខ្លាំង*

*កុមារដែលមកពីគ្រួសារអ្នកមានអាចមានភាពងាយស្រួលច្រើន*

*កុមារមួយចំនួនអាចរៀនបានរហ័ស ហើយងាយស្រួល ចំណែកកុមារមួយចំនួនទៀតមិនដូច្នោះទេ*

*កុមារមួយចំនួនអាចមានការគាំទ្រនិងការលើកទឹកចិត្តច្រើនពីឪពុកម្តាយ ចំណែកកុមារមួយចំនួនទៀតមិនដូច្នោះទេ*

*កុមារមួយចំនួនអាចយល់ដឹងពីសៀវភៅ និងអក្សរខ្លះហើយ ចំណែកកុមារមួយចំនួនទៀតមិនដូច្នោះទេ*

*កុមារភាគច្រើនមានបងប្អូនបង្កើតហើយលេងរួមគ្នា ចំណែកកុមារមួយចំនួនទៀតមិនដូច្នោះទេ*

*កុមារមួយចំនួនចង់ដឹង ចង់ឃើញ ចង់សាកល្បងអ្វី១ដែលថ្មី ចំណែកកុមារមួយចំនួនទៀតមិនដូច្នោះទេ*

# ថ្ងៃទី២ ការរីកលូតលាស់របស់កុមារ

**ថ្ងៃទី២**

**ដំណាក់កាលបង្រៀនទី១: ដំណាក់កាលរីកលូតលាស់របស់កុមារ** **៧៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: ក្នុងខណៈពេលដែលកុមារកំពុងលូតលាស់ ពួកគេក៏អាចធ្វើអ្វីៗថ្មីបានផងដែរ។ លក្ខណៈបែបនេះមួយចំណែកគឺដោយសារពួកគេទទួលបាននូវបទពិសោធន៍ថ្មី ហើយក៏រៀនបន្ថែមតទៅទៀត។ ប៉ុន្តែវាក៏ដោយសារការលូតលាស់ផ្នែករាងកាយនិងខួរក្បាលរបស់កុមារផងដែរ ដែលហេតុនេះគេអាចរៀនអ្វីៗថ្មីដែលពុំធ្លាប់រៀនពីមុន។ ឧទាហរណ៍កុមារតូចម្នាក់ពុំអាចកាន់និងគ្រប់គ្រងខ្មៅដៃ មិនអាចយល់ពីរបៀបប្រើដើម្បីគូរអ្វីមួយដែលពួកគេបានឃើញឡើយ។ កុមារអាយុ៣ឆ្នាំអាចកាន់ខ្មៅដៃបានតែប្រហែលមិនអាចគ្រប់គ្រងបានល្អទេ។ ពួកគេយល់ពីគំនិតនៃការគូរគំនូរនៃអ្វីដែលគេបានឃើញប៉ុន្តែជាញឹកញាប់គេគូរដោយមានក្បាលធំ ខ្លួនតូច ហើយគូរដៃចេញពីត្រចៀក។ កុមារនៅអាយុ៥ឆ្នាំចេះគូរផ្នែកសំខាន់ៗនៃរាងកាយបានត្រឹមត្រូវ ប៉ុន្តែការលៃអោយមានរូបរាងសមរម្យមិនទាន់បានល្អពិតប្រាកដនៅឡើយទេ។

**កិច្ចការ:** អ្នកសម្របសម្រួលនិយាយថា: សំរាប់កិច្ចការដំបូងនេះ ចូរលោក/លោកស្រីធ្វើការជាមួយសិក្ខាកាមម្នាក់ឬពីរនាក់ផ្សេងទៀតដើម្បីបង្កើតតារាងនៃអ្វីដែលកុមារអាចធ្វើបានទៅតាមអាយុរបស់ពួកគេ។ ចូរគិតអំពីកុមារនៅក្នុងគ្រួសាររបស់អ្នកថាតើពួកគេអាចធ្វើអ្វីបាន ហើយគេមានអាយុប៉ុន្មាន។ យើងចង់អោយលោក/លោកស្រីពិភាក្សានិងបំពេញតារាង (**ឯកសារទី៥**) ដែលបង្ហាញអំពីកុមារ (អាយុ ២ឆ្នាំ) កុមារ (អាយុ ៤ឆ្នាំ) សិស្ស ថ្នាក់ទី១ (អាយុ ៦ឆ្នាំ) និងសិស្សថ្នាក់ទី៦ (អាយុ ១១ឆ្នាំ)។ ចូរគិតថាតើពួកគេអាចធ្វើអ្វីបានទៅតាមចំនុចក្នុងកូឡោនខាងក្រោមដោយប្រើសញ្ញា(✓) បើយល់ព្រម និងប្រើសញ្ញា (×) បើមិនយល់ព្រម។ ចូរចំលងចំលើយក្រុមដាក់លើតារាងរបស់ខ្លួន។

| **អ្វីដែលគេអាចធ្វើបាន** | **កុមារ (អាយុ ២ឆ្នាំ)** | **កុមារ (អាយុ ៤ឆ្នាំ)** | **សិស្សថ្នាក់ទី១ (អាយុ ៦ឆ្នាំ)** | **សិស្សថ្នាក់ទី៦ (អាយុ១១ឆ្នាំ)** |
|---|---|---|---|---|
| ស្គាល់ឈ្មោះខ្លួនឯង | | | | |
| ស្គាល់សមាជិកគ្រួសារ | | | | |
| ស្គាល់យប់និងថ្ងៃ | | | | |
| ស្គាល់ភ្លើង | | | | |
| ស្គាល់អ្វីដែលអាចបរិភោគកើត | | | | |

| | | | | |
|---|---|---|---|---|
| ប្រើស្លាបព្រាដោយខ្លួនឯង | | | | |
| ចេះស្លៀកពាក់ខ្លួនឯង | | | | |
| ចេះសំពះ | | | | |
| ចេះរាប់លេខដល់១០ | | | | |
| ចេះអានអក្ខរក្រម | | | | |
| ចេះសរសេរអក្សរបានខ្លះ | | | | |
| ចេះសរសេរប្រយោគបានខ្លះ | | | | |
| ចេះអានរឿងដោយខ្លួនឯង | | | | |
| ចេះរាប់វត្ថុដល់១០ | | | | |
| រាប់រហូតដល់១០០ | | | | |
| ធ្វើផលបូកដល់១០០ | | | | |
| កាន់ខ្មៅដៃ | | | | |
| ចាប់កាន់បាល់ | | | | |
| រត់ | | | | |
| លោត ជើង១ | | | | |
| ឡើងដើមឈើ | | | | |
| ច្រៀងចំរៀងងាយៗ | | | | |
| ធ្វើកិច្ចការរហូតដល់ជាង១ម៉ោង | | | | |

ក្រុមទាំងឡាយបង្ហាញតារាងទៅវិញទៅមក។ អ្នកសម្របសម្រួលបង្ហាញពីភាពស្រដៀងគ្នា ភាពខុសគ្នា ហើយធ្វើការពន្យល់បន្ថែមបើចាំបាច់។

**អ្នកសម្របសម្រួលសួរថាៈ តើចំនុចសំខាន់បំផុតសំរាប់គ្រូបង្រៀន ដែលបានរៀនពីសកម្មភាពនេះគឺអ្វី?**

***ចំលើយរំពឹងទុកៈ***

*អ្នកត្រូវផ្លាស់ប្តូររបៀបបង្រៀនដោយយោលទៅតាមអាយុរបស់សិស្ស។*

*អ្នកត្រូវគិតអំពីអ្វីដែលកុមារដឹងរួចហើយ អ្វីដែលគេអាចធ្វើបាន និងអ្វីដែលគេមិនអាចធ្វើបាន។*

**ថ្ងៃទី២**

**ដំណាក់កាលបង្រៀនទី២: ដំណាក់កាលនៃការសិក្សារបស់កុមារ** ( *ភាពពិតជាក់ស្តែង និមិត្តសញ្ញា អរូបី* ) **៦០ នាទី**

អ្នកសម្របសម្រួលនិយាយថា: ដូចយើងបានឃើញនៅក្នុងសកម្មភាពចុងក្រោយរួចហើយថាកុមាររក្សាការលួតលាស់នៅពេលដែលគេនៅសាលារៀន។ កុមារនៅថ្នាក់ទី១គឺមានភាពខុសប្លែកពីកុមារនៅថ្នាក់ទី៦ **ទៅលើអ្វីដែលគេអាចរៀន** និង **របៀបដែលគេអាចរៀនបាន**។

**សំនួរ: តើមានភាពខុសគ្នាចំបងៗអ្វីខ្លះរវាងរបៀបកុមាររៀននៅថ្នាក់ទី៦ និងទី១?**

*ចំលើយរំពឹងទុក: កុមារនៅថ្នាក់ទី៦ អាចសរសេរ អាន និងរៀនពីសៀវភៅផ្សេងៗបានហើយកុមារមានការផ្តោតអារម្មណ៏ច្រើនជាងកុមារថ្នាក់ទី១: កុមារនៅថ្នាក់ទី៦អាចរៀនអ្វីៗបានរហ័សជាងកុមារថ្នាក់ទី១...*

អ្នកសម្របសម្រួលនិយាយថា: របៀបមួយនៃការរៀនដែលខុសប្លែករវាងកុមារថ្នាក់ទី១និងទី៦គឺថាកុមារនៅថ្នាក់ទី៦យល់ភាសាបានច្រើនហើយដោះស្រាយបញ្ហាអ្វីៗប្រកបដោយការគិត។ យើងអាចយល់បានច្បាស់នៅក្នុង គណិតវិទ្យាអំពីរបៀបកុមារគិតចំនួន...ឧទាហរណ៏ យើងមានវត្ថុ២ពេលបន្ថែមវត្ថុ២ទៀត តើមានចំនួនប៉ុន្មាន?

១. កុមារតូចៗគិតចំនួនដោយយក**វត្ថុ២** xx និង **វត្ថុ៤ទៀត** xxxx ដាក់រួមគ្នា xxxxxx ហើយគេចាប់ផ្តើមរាប់រហូតបានទទួលចំលើយគឺ៦។

២. កុមារដែលមានវ័យចាស់ជាងគិតលេខដោយសរសេរលេខ២ហើយប្រើសញ្ញា + និងលេខ៤ រួចហើយប្រើម្រាមដៃរបស់គេដើម្បីរាប់បន្ថែម៤ទៀត បន្ទាប់ពីលេខពីរគឺ បី បួន ប្រាំ ប្រាំមួយ ដើម្បីបានចំលើយ **៦** រួចគេសរសេរ=៦។

៣. កុមារដែលមានបទពិសោធន៏ច្រើនអាចដឹងចំលើយភ្លាមគឺ **៦**។

**អ្នកអប់រំនិយាយថាមធ្យោបាយដំបូងគេក្នុងការទទួលចំលើយគឺតាមរយៈភាពពិតជាក់ស្តែង**

**អ្នកអប់រំនិយាយថាមធ្យោបាយដំបូងគេក្នុងការទទួលចំលើយគឺតាមរយៈនិមិត្តសញ្ញា/ពាក់កណ្តាលអរូបី**

**អ្នកអប់រំនិយាយថាមធ្យោបាយដំបូងគេក្នុងការទទួលចំលើយគឺតាមរយៈអរូបី**

នៅទីនេះមានឧទាហរណ៏មួយផ្សេងទៀត។ បើសិនខ្ញុំជាគ្រូបង្រៀនហើយបង្រៀនសិស្សអំពីប្រភេទដើមឈើដែលសិស្ស

មិនធ្លាប់បានឃើញពីមុននោះខ្ញុំមានវិធីច្រើនរបៀបដើម្បីបង្រៀន។ ឧទាហរណ៍ខ្ញុំអាចបង្ហាញជារូបភាពជាការពិពណ៌នាដោយប្រើពាក្យតាមរយៈការសរសេរឬនិយាយ។ ចូរគិតអំពីវិធីទាំងបីនេះ (១) ប្រើរូបភាព (២) ប្រើភាសាតាមរយៈនិយាយឬសរសេរ (៣) បង្ហាញដើមឈើពិតប្រាកដ។ អ្នកសម្របសម្រួលបង្ហាញរូបភាពនៃវិធីបង្រៀនទាំង៣នៅលើក្ដារខៀន (ភាពពិតជាក់ស្ដែង និមិត្តសញ្ញា និង អរូបី)។ អ្នកសម្របសម្រួលអោយសិក្ខាកាមនិយាយទៅកាន់មនុស្សនៅក្បែរពួកគាត់ រួចហើយអោយពួកគាត់លើកដៃដើម្បីបង្ហាញរូបភាពមួយណាបញ្ជាក់ពីភាពពិតជាក់ស្ដែងមួយណាជា និមិត្តសញ្ញា និងមួយណាជាអរូបី។

នៅទីនេះមានគំនិតសំខាន់ៗ២សំរាប់គ្រូបង្រៀន (**ឯកសារទី៦**) គឺៈ

អ្នកសម្របសម្រួលសុំអោយសិក្ខាកាមអានឯកសាររួចហើយអោយពួកគាត់សង្ខេបគំនិតសំខាន់ៗចំនួន២។
គំនិតនោះមានៈ

១. ក្នុងខណៈពេលដែលកុមារលូតលាស់ពីអាយុ៦ឆ្នាំ-១១ឆ្នាំ ពួកគេក៏មានការប្រែប្រួលយ៉ាងខ្លាំងលើការយល់ដឹងពីភាពពិតជាក់ស្ដែងទៅកាន់កំរិតគំនិតអរូបី។ ពួកគេបានដឹងយ៉ាងច្រើនតាមរយៈភាសាជាងការប្រើវត្ថុពិត ការមើលឃើញនិងការជួបប្រទះអ្វីមួយ។

ភាពពិតជាក់ស្ដែង- - - - - - - - -ពាក់កណ្ដាលអរូបី- - - - - - - - -អរូបី
អាយុ៦ឆ្នាំ---------------------------------------------------អាយុ១១ឆ្នាំ

២. នៅពេលកុមារ (ទោះអាយុប៉ុន្មានក៏ដោយ) **កំពុងរៀនអ្វីមួយជាលើកដំបូង** ជាធម្មតាយកល្អត្រូវបង្ហាញភាពពិតជាក់ស្ដែងជាមុន រួចហើយអនុញ្ញាតអោយគេពិសោធន៍និងពិភាក្សាអំពីវត្ថុទាំងនោះដោយខ្លួនឯង។

**ការរៀនអ្វីដែលថ្មីក្នុងគ្រប់កំរិតថ្នាក់**

ថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ ថ្នាក់ទី៤ ថ្នាក់ទី៥ ថ្នាក់ទី៦

ភាពពិតជាក់ស្តែង

ពាក់កណ្តាលអរូបី

អរូបី

បន្ទាប់មកអ្នកសម្របសម្រួលចែកឯកសារ (**ឯកសារទី៧**) ដែលមានតារាងដូចខាងក្រោម។ រួចហើយអ្នកសម្របសម្រួលសួរសំនួរខាងក្រោមនិងអោយពិភាក្សាជាក្រុមតូចដើម្បីស្វែងរកចំលើយសមស្របដាក់ក្នុងតារាង។

**កិច្ចការ: តើភាពពិតជាក់ស្តែងអ្វីខ្លះដែលអ្នកអាចប្រើដើម្បីបង្ហាញប្រធានបទខាងក្រោមនេះទៅអោយសិស្សដែលគេទើបតែរៀនជាលើកដំបូង?**

| ប្រធានបទ | ចូរបង្ហាញដោយប្រើប្រាស់ភាពពិតជាក់ស្តែង |
| --- | --- |
| ទង់ជាតិប្រទេសកម្ពុជា | |
| កូនរុក្ខជាតិដែលមានស្លឹកនិងឫស | |
| ភាពធ្ងន់និងស្រាល | |
| ត្រីកោណ | |
| ទឹកពុះនៅពេលវាក្តៅ | |
| អក្សរថ្មីនៅក្នុងអក្ខរក្រម | |
| មនុស្សរស់នៅក្នុងផ្ទះ | |
| ស្វែងយល់ពីលេខ៤ | |
| សត្វមួយចំនួនក្រាបស៊ុត | |
| មនុស្សជាធម្មតារស់នៅជាគ្រួសារ | |
| ទឹកកកគឺជាទឹកដែលបានកក | |
| មុខរបរនៅក្នុងភូមិរបស់ខ្ញុំ | |

| |
|---|
| អ្នកសម្របសម្រួលសួរតំណាងក្រុមអោយបង្ហាញពីអ្វីដែលបានសរសេរលើប្រធានបទនីមួយៗ បន្ទាប់មកសួរទៅកាន់ក្រុមដទៃក្រែងលោពួកគេមានចំលើយផ្សេងពីនេះ ។<br><br>អ្នកសម្របសម្រួលនិយាយថាៈ ជួនកាលគ្រូពុំអាចបង្ហាញអ្វីមួយដោយពិតជាក់ស្តែងបានទេ។ ឧទាហរណ៍គ្រូនៅប្រទេសកម្ពុជាមិនអាចបង្ហាញកុមារអំពីព្រិលឬមួយគ្រូនៅខេត្តរតនៈគីរីមិនអាចនាំសិស្សទៅមើលមហាសមុទ្រ។<br>**តើគេអាចធ្វើយ៉ាងម៉េចដើម្បីអោយការសិក្សាកាន់តែមានភាពជាក់ស្តែងតាមដែលអាចធ្វើទៅបាន?**<br>***ចំលើយរំពឹងទុកៈ*** *ចូរបង្ហាញរូបភាពនៅក្នុងសៀវភៅឬលើផ្ទាំងក្រដាសធំឬស្វែងរកនរណាម្នាក់នៅក្នុងសហគមន៍ឬដែលធ្លាប់ឃើញព្រិលឬធ្លាប់បានទៅលេងវាលខ្សាច់នៅសមុទ្រមកប្រាប់ដល់សិស្ស ។* |
| **ថ្ងៃទី២**<br>**ដំណាក់កាលបង្រៀនទី៣ៈ ភាសាក្នុងការសិក្សា** **៧៥ នាទី**<br><br>អ្នកសម្របសម្រួលនិយាយទៅកាន់សិក្ខាកាមថាៈ ដូចយើងបានឃើញនៅក្នុងសកម្មភាពចុងក្រោយនេះកុមាររៀនបានកាន់តែច្រើនឡើងតាមរយៈភាសាក្នុងខណៈពេលដែលគេធំឡើងៗ។<br>**សំនួរទៅកាន់ក្រុមទាំងមូលៈ តើមុខវិជ្ជាអ្វីខ្លះដែលកុមាររៀននៅសាលាដោយប្រើប្រាស់ភាសា?**<br>***ចំលើយរំពឹងទុកៈ*** *គ្រប់មុខវិជ្ជា*<br><br>អ្នកសម្របសម្រួលសួរបន្តទៅទៀតថាៈ **ឧទាហរណ៍ នៅក្នុងគណិតវិទ្យា តើមានពាក្យសំខាន់ៗអ្វីខ្លះដែលគេប្រើប្រាស់?**<br>***ចំលើយរំពឹងទុកៈ*** *មួយ ពីរ បី... មួយរយ មួយពាន់ មួយម៉ឺន មួយលាន មួយភាគដប់ ពាក់កណ្តាល ភាគរយ ត្រីកោណ ការេ គីឡូក្រាម ធ្ងន់ លីត្រ បូក ដកចេញ ចែកនឹង ។ល។*<br>អ្នកសម្របសម្រួលនិយាយថាៈ ត្រឹមត្រូវណាស់។ មានភាសាច្រើនដែលយើងប្រើនៅពេលដែលយើងនិយាយអំពីគណិតវិទ្យា។ មនុស្សមួយចំនួនហៅថា " *ភាសាគណិតវិទ្យា* " ។ នេះមានន័យថាបំនិនភាសាគឺជាមូលដ្ឋានគ្រឹះសំរាប់រៀនមុខវិជ្ជាផ្សេងៗទាំងអស់។<br><br>**អ្នកសម្របសម្រួលសួរក្រុមទាំងមូលថាៈ ជាធម្មតាគ្រូបង្រៀននិយាយអំពីបំនិនទាំង៤នៃភាសា។ តើលោក/លោកស្រីគិតថាមានបំនិនអ្វីខ្លះទៅ?**<br>***ចំលើយរំពឹងទុកៈ*** *បំនិនស្តាប់ បំនិននិយាយ បំនិនអាន បំនិនសរសេរ ។* |

អ្នកសម្របសម្រួលនិយាយថា គំនិតសាមញ្ញមួយសំរាប់គ្រូបង្រៀនចងចាំដើម្បីជួយកុមារលើបំនិនទាំង៤នៅគ្រប់មុខវិជ្ជាគឺ:" **ធ្វើ (do) ពិភាក្សា (talk) កត់ត្រា (record)**" ។ នេះមានន័យថាគ្រូព្យាយាមបង្រៀនមេរៀនដើម្បីអោយ (១) កុមារ**ធ្វើ**អ្វីមួយរួមគ្នា បន្ទាប់មក (២) កុមារ**ពិភាក្សា**អំពីអ្វីដែលពួកគេបាន (ស្តាប់ និយាយ) រួចហើយ (៣) កុមារ**កត់ត្រា**ទៅតាមរបៀបណាមួយនូវអ្វីដែលគេបានធ្វើ (អាន សរសេរ) ។

**កិច្ចការ:** អ្នកសម្របសម្រួលបិទតារាងនៅលើក្តារខៀនដោយមានប្រអប់ចំហនៅក្បែរប្រយោគពីរឬបីខាងលើ ។ អោយសិក្ខាកាមគិតអំពីឧទាហរណ៍ដែលពាក់ព័ន្ធនឹងសកម្មភាព **ធ្វើ** និង **កត់ត្រា** ដែលអ្នកសម្របសម្រួលសរសេរលើចំណិតក្រដាសហើយបិទនៅលើតារាង ។ តារាងមានរាងដូចខាងក្រោម (ព្រមទាំងចំលើយរំពឹងទុកដែលសរសេរជាអក្សរទ្រេត) ។ អ្នកសម្របសម្រួលចែកតារាងទៅសិក្ខាកាម (**ឯកសារទី៨**) ដើម្បីកត់ត្រាលទ្ធផលសកម្មភាព ។

វាជាការសំខាន់ណាស់ដែលអ្នកសម្របសម្រួលត្រូវបញ្ជាក់អោយបានច្បាស់នូវទំនាក់ទំនងរវាងគំនិត **ធ្វើ ពិភាក្សា** និង **កត់ត្រា** ។ អ្នកសម្របសម្រួលអាចបង្ហាញឧទាហរណ៍ចំនួន២ខាងក្រោមដើម្បីបង្ហាញពីរបៀបនេះ-

| ធ្វើ | ពិភាក្សា | កត់ត្រា |
|---|---|---|
| កុមារនិងគ្រូដើរលេងនៅក្បែរសាលារៀនហើយអោយកុមារហៅឈ្មោះនិងរាប់សត្វ៣ប្រភេទដែលពួកគេបានឃើញ ។ | គ្រូអោយសិស្សចងចាំឈ្មោះសត្វដែលពួកគេបានឃើញនិងចំនួនរបស់សត្វនោះ ។ | គ្រូប្រាប់អោយកុមារបង្កើតតារាងមួយដែលបង្ហាញឈ្មោះ (ឬរូបភាព) នៃសត្វទាំងបីនិងចំនួនដែលគេបានឃើញ ។ |
| គ្រូអានរឿងអោយសិស្សស្តាប់ | គ្រូ និងសិស្សពិភាក្សាអំពីរឿង តួអង្គ អ្វីដែលបានកើតឡើង រឿងចប់ដោយរបៀបណា... | គ្រូប្រាប់អោយសិស្សគូររូបភាពឬសរសេរប្រយោគអំពីរឿងនោះ |

ខាងក្រោមនេះជាតារាងសំរាប់ប្រើប្រាស់ក្នុងសកម្មភាព (ប៉ុន្តែមិនត្រូវសរសេរចំលើយចូលនៅក្នុងកូឡោនទី១និងទី៣ទេ- ពីព្រោះនេះគឺជាចំលើយរបស់សិក្ខាកាមប៉ុណ្ណោះ) ។

| **កុមារធ្វើអ្វីមួយរួមគ្នា** | **កុមារពិភាក្សា អំពីអ្វី** | **កុមារកត់ត្រាអ្វីដែលបានធ្វើ** |
|---|---|---|
| | | |

| | | | | |
|---|---|---|---|---|
| | ***ចំលើយរំពឹងទុក*** | ដែលបានធ្វើ | ***ចំលើយរំពឹងទុក*** | |
| | *កុមារដើរលេង* | | *កុមារគូររូបភាព* | |
| | *កុមារស្តាប់រឿង* | | *កុមារគូរដ្យាក្រាម* | |
| | *កុមារបង្កើតអ្វីមួយ* | | *កុមារបំពេញតារាង* | |
| | *កុមារមើលអ្វីមួយ* | | *កុមារចំលងពាក្យ* | |
| | *កុមារលេងល្បែង* | | *កុមារចំលងប្រយោគ* | |
| | *កុមាររាប់អ្វីមួយ* | | *កុមារសរសេរពាក្យ* | |
| | *កុមារសាងសង់អ្វីមួយ* | | *កុមារសរសេរប្រយោគ* | |
| | *កុមាររៀបចំអ្វីមួយ* | | .............................. | |
| | ...................... | | | |

**ថ្ងៃទី២**

**ដំណាក់កាលបង្រៀនទី៤: ការបង្កើនទៅលើចំណេះដឹងមានស្រាប់** ៩០ នាទី

អ្នកសម្របសម្រួលនិយាយថា: ក្នុងខណៈពេលដែលកុមារកំពុងលូតលាស់ពួកគេមានបទពិសោធន៍និងការស្វែងយល់កាន់តែច្រើនឡើងអំពីខ្លួនគេផ្ទាល់និងពិភពដែលគេរស់នៅ។ គ្រូដែលល្អត្រូវយល់អំពីបញ្ហានេះហើយប្រើប្រាស់ចំណេះដឹងផ្ទាល់របស់កុមារជាមូលដ្ឋានដើម្បីកសាងការបង្រៀន។ ដូច្នោះនេះមានន័យថាគ្រូបង្រៀនជាញឹកញាប់ត្រូវផ្តើមមេរៀនដោយការសួរសំនួរមួយចំនួនដើម្បីស្វែងរក **អ្វីដែលកុមារបានចេះដឹង**។

**អ្នកសម្របសម្រួលសួរក្រុមទាំងមូលថា: ឧទាហរណ៍ បើសិនជាខ្ញុំបង្រៀនថ្នាក់ទី៥អំពីភូមិវិទ្យានយោបាយប្រទេសកម្ពុជា តើខ្ញុំអាចដឹងយ៉ាងដូចម្តេចនូវអ្វីដែលកុមារបានដឹងរួចហើយ?**

***ចំលើយរំពឹងទុក:*** *ដោយការសួរសំនួរ*

**អ្នកសម្របសម្រួលនិយាយថា: ពិតហើយ តើខ្ញុំអាចសួរសំនួរប្រភេទណា?** (ចាប់ផ្តើមដោយសំនួរងាយទៅលំបាក..)

***ចំលើយរំពឹងទុក:*** *តើយើងឥឡូវនេះកំពុងនៅក្នុងខេត្តអ្វី?*

*តើអ្នកធ្លាប់បានទៅខេត្តផ្សេងដែរឬទេ?*

*តើខេត្តអ្វីដែលនៅជាប់ព្រំប្រទល់ខេត្តនេះ?*

*តើអ្នកស្គាល់ឈ្មោះខេត្តផ្សេងៗទៀតដែរឬទេ?* ***(គ្រូសរសេរចំលើយដាក់លើក្តារខៀន)***

*តើមានខេត្តប៉ុន្មាននៅក្នុងប្រទេសកម្ពុជា?*

*សូមពិនិត្យមើលតើយើងមានខេត្តប៉ុន្មានហើយ?*

រួចហើយគ្រូបង្កើតជាផែនទីសំរាប់ខេត្តទាំងនោះហើយពិនិត្យមើល តើកុមារផ្សេងៗអាចរកឃើញខេត្តផ្សេងៗទៀតឬទេ ហើយបិទប័ណ្ណពាក្យអោយត្រូវចំកន្លែង រួចហើយចាប់ផ្តើមសរសេរឈ្មោះខេត្តទាំងនោះបន្តពីក្រោមចំលើយពីមុន។

(បើសិនជាចាំបាច់...) អ្នកសម្របសម្រួលនិយាយថាៈ ចំពោះឧទាហរណ៍ទីពីរនេះគឺថាថ្ងៃស្អែកយើងនឹងបង្រៀនលោក/លោកស្រីអំពីកម្មវិធីសិក្សានិងសៀវភៅសិក្សារបស់ក្រសួងអប់រំ។ **តើមានសំនួរអ្វីខ្លះដែលយើងអាចសួរលោក/លោកស្រីអំពីឯកសារទាំង នោះ?**

***ចំលើយរំពឹងទុកៈ***

*តើលោក/លោកស្រីអាចប្រាប់ខ្ញុំបានអ្វីខ្លះអំពីសៀវភៅដែលប្រើប្រាស់នៅក្នុងសាលារៀនក្រសួង?*

*តើលោក/លោកស្រីធ្លាប់បានឃើញសៀវភៅនោះឬទេ ?(តើកូនរបស់លោក/លោកស្រីយកសៀវភៅនោះមកផ្ទះឬទេ?)*

*តើថ្នាក់និងមុខវិជ្ជាអ្វីខ្លះដែលមានសៀវភៅសិក្សា?*

*តើកុមារទាំងអស់មានសៀវភៅសិក្សាគ្រប់គ្នាឬទេ?*

*តើមានអ្វីខ្លះនៅក្នុងសៀវភៅ?*

*តើសៀវភៅនោះថ្លៃប៉ុន្មាន?*

**កិច្ចការៈ** អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាមបង្កើតជាក្រុមដើម្បីសរសេរសំនួរដែលគ្រូអាចប្រើដើម្បីស្វែងរកអ្វីដែលសិស្សបានដឹងលើប្រធានបទខាងក្រោមដែលបានមកពីសៀវភៅសិក្សាសង្គមសិស្សនៅបឋមសិក្សា (នៅខាងក្រោម)។ ប្រធានបទសំរាប់ក្រុមនីមួយៗគឺខុសគ្នា ហើយក៏រិតថ្នាក់ក៏ខុសគ្នាផងដែរ។

| ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ | ក្រុមទី៥ |
|---|---|---|---|---|
| ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ |
| ប្រព័ន្ធញាតិសន្តាន<br>មេរៀនទី៤<br>ទំព័រ៦-៧ | ចំណីអាហារ<br>មេរៀនទី២៨<br>ទំព័រ៣៧ | តំបន់ភ្នំ<br>មេរៀនទី៣២<br>ទំព័រ៤៥ | សិទ្ធិកុមារ<br>មេរៀនទី៤៦<br>ទំព័រ៥០ | ជំងឺអេដស៍<br>មេរៀនទី១៣<br>ទំព័រទី១៥ |

សិក្ខាកាមបង្ហាញសំនួរនិងពិភាក្សា។ អ្នកសម្របសម្រួលផ្តល់មតិកែលំអ។អ្នកសម្របសម្រួលសរុបសេចក្តីៈ គំនិតនៃការបង្រៀនបែបនេះជាធម្មតាគេហៅថាៈ **ការកសាងចំណេះដឹងថ្មីពីលើអ្វីដែលកុមារបានដឹង**

| |
|---|
| **ថ្ងៃទី២**<br>**ដំណាក់កាលបង្រៀនទី៥: ការអានឯកសារ "ការសួរបំផុសគំនិតកុមារ"** **៣០ នាទី**<br><br>អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថាគាត់នឹងចែកជូនឯកសារអាន (**ឯកសារទី៩**) លើប្រធានបទដែលដកស្រង់ពីកញ្ចប់ TGL។ បន្ទាប់មកអ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុម ហើយអ្នកសម្របសម្រួលផ្សេងៗទៀតចូលរួមទៅតាមក្រុមនីមួយៗហើយនឹងចែកឯកសារ។ សិក្ខាកាមអានឯកសារ ពិភាក្សាជាក្រុម និងសួរសំនួរ។ រាល់សំនួរណាដែលមិនអាចដោះស្រាយនៅក្នុងក្រុមបាន ពួកគេអាចធ្វើកំណត់សំគាល់ទុក។<br><br>នៅពេលក្រុមតូចបានពិភាក្សាចប់ អ្នកសម្របសម្រួលសួរថាតើពួកគេមានសំនួរដែលត្រូវសួរឬទេ។ បើសិនជាគ្មានសំណួរទេអ្នកសម្របសម្រួលអាចអោយសិក្ខាកាមសង្ខេបចំនុចសំខាន់ៗពីឯកសារ។ អ្នកសម្របសម្រួលម្នាក់ផ្សេងទៀតកត់ត្រាចំនុចនោះនៅលើក្តារខៀន។<br><br>**អ្នកសម្របសម្រួលសន្និដ្ឋានបញ្ចប់ដោយសួរថា: តើយើងបានពិភាក្សាអំពីគំនិតនេះពីដំបូងនៅក្នុងសិក្ខាសាលានេះឬទេ?**<br>***ចំលើយរំពឹងទុក:*** *បាទ/ចាស់ នៅក្នុងដំណាក់កាលបង្រៀនពីមុនដែលនិយាយអំពីការស្វែងរកអ្វីដែលកុមារបានដឹងរួចហើយនៅមុនពេលពួកគេចូលសាលារៀន។* |
| **ថ្ងៃទី២**<br>**ដំណាក់កាលបង្រៀនទី៦: ការវាយតំលៃការសិក្សា** **៦០ នាទី**<br><br>អ្នកសម្របសម្រួលនិយាយថា ក្នុងពេលនេះលោក/លោកស្រីត្រូវឆ្លើយសំនួរ: តើយើងដឹងដោយរបៀបណាថាកុមារបានរៀនអ្វីមួយ? រួចហើយអ្នកសម្របសម្រួល<br><br>• សួរសិក្ខាកាមម្នាក់អំពីឈ្មោះរបស់គាត់<br>• សុំអោយសិក្ខាកាមផ្សេងមួយទៀតសរសេរឈ្មោះរបស់គាត់នៅលើប័ណ្ណមួយ<br>• លើកបង្ហាញចង្អុះ៥ហើយសួរសិក្ខាកាមផ្សេងថា តើមានចំនួនប៉ុន្មាន?<br>• សុំអោយសិក្ខាកាមម្នាក់រៀបចំគំរូនៃចំនួន"**២៥**" ដោយប្រើបំពង់បឺតនិងកៅស៊ូកង<br>• រៀបចំប្រស្នាគ្រាប់ឈើគួសជារាង**ការេ** ហើយអោយសិក្ខាកាមដោះស្រាយ |

តើមានរូបការេចំនួនប៉ុន្មាន?

១ × ១ = ១៦

២ × ២ = ៩

៣ × ៣ = ៤

៤ × ៤ = ១

សរុប ៣០ ការេ

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមតូច ដើម្បីគិត និងពិភាក្សាអំពីការបង្ហាញខាងលើ រួចហើយឆ្លើយសំនួរ: **តើគ្រូអាចមានវិធីអ្វីសំរាប់អោយកុមារធ្វើដើម្បីអោយបានដឹងថាពួកគេបានរៀនចេះអ្វីមួយ?**

បន្ទាប់មកសិក្ខាកាមពិភាក្សានិងធ្វើបញ្ជីអំពីរបៀបដែលកុមារអាចបង្ហាញអោយដឹងនូវអ្វីដែលបានរៀន។

***ចំលើយអាចជា:***

*ការឆ្លើយសំនួរពីនរណាម្នាក់ដោយនិយាយ*

*ការឆ្លើយសំនួរពីនរណាម្នាក់ដោយសរសេរ*

*ការធ្វើកិច្ចការឬដោះស្រាយបញ្ហាអ្វីមួយ*

*ការបង្ហាញពីរបៀបធ្វើអ្វីមួយបាន*

*ការពន្យល់ទៅកាន់នរណាម្នាក់អំពីអ្វីមួយដែលអ្នកដឹង...*

ក្រុមតូចឡើងរាយការណ៍ដោយបង្ហាញអំពីបញ្ជីចំលើយ។ បើមានពេលខ្លីអោយតែក្រុមមួយរាយការណ៍ចំណែកក្រុមដ៏ទៃទៀតអាចបន្ថែមចំនុចដែលខុសគ្នា។

**ថ្ងៃទី២**

**ដំណាក់កាលបង្រៀនទី៧: ការសង្ខេបគំនិតសំខាន់ៗនៅថ្ងៃទី២ ១៥ នាទី**

អ្នកសម្របសម្រួលអោយសិក្ខាកាមសង្ខេបគំនិតសំខាន់ៗដែលបានរៀននៅថ្ងៃនេះ:

១. ការរីកលូតលាស់របស់កុមារពីអាយុ២ឆ្នាំទៅ១១ឆ្នាំ

២. កុមារឆ្លងកាត់ពីដំណាក់កាលភាពពិតជាក់ស្តែងទៅពាក់កណ្តាលអរូបី និងទៅអរូបីក្នុងការសិក្សា

៣. ភាសាត្រូវបានគេប្រើក្នុងមុខវិជ្ជាទាំងអស់-ធ្វើ-ពិភាក្សា-កត់ត្រាគឺជាវិធីដ៏មានសារៈប្រយោជន៍មួយដើម្បីអភិវឌ្ឍការយល់ដឹង និងបំនិនទាំង៤របស់កុមារ។

៤. ការកសាងទៅលើអ្វីដែលគេបានដឹងរួចហើយនៅពេលបង្រៀនខ្លឹមសារនិងគំនិតថ្មី។

៥. មានវិធីផ្សេងៗជាច្រើនដែលគ្រូអាចយកមកប្រើដើម្បីស្វែងរកនូវអ្វីដែលកុមារបានរៀនឬពុំបានរៀន (ពោលគឺការវាយតំលៃការសិក្សារបស់កុមារ)។

## ថ្ងៃទី៣ កម្មវិធីសិក្សាជាតិនិងធនធានពីក្រសួងអប់រំ យុវជន និងកីឡា

ថ្ងៃទី៣

ដំណាក់កាលបង្រៀនទី១: កម្មវិធីសិក្សបឋមសិក្សា ៦០ នាទី

អ្នកសម្របសម្រួលនិយាយទៅកាន់ក្រុមទាំងមូលៈ តើគ្រូបង្រៀនត្រូវដឹងដោយរបៀបណាអំពីអ្វីដែលត្រូវបង្រៀននៅដើមឆ្នាំសិក្សា? ចំពោះគ្រូមួយចំនួនដែលធ្លាប់បង្រៀននៅថ្នាក់ណាមួយកាលពីឆ្នាំមុនវាហាក់ដូចជាពួកគេធ្វើការងារនោះដដែលឡើងវិញ។ ប៉ុន្តែគ្រូថ្មីឬគ្រូដែលត្រូវបង្រៀនថ្នាក់ថ្មីត្រូវតែដឹងចំលើយចំពោះសំនួរនេះ។ **តើលោក/លោកស្រីគិតថាមានចំលើយអ្វីខ្លះចំពោះសំនួរនេះ?**

***ចំលើយរំពឹងទុកៈ***

*នាយកសាលានឹងប្រាប់ពួកគេនូវអ្វីដែលត្រូវធ្វើ*

*គ្រូផ្សេងៗទៀតនឹងប្រាប់ពួកគេនូវអ្វីដែលត្រូវធ្វើ*

*ក្រសួងអប់រំ/មន្ទីរអបរំ/ការិយាល័យអប់រំស្រុកនឹងប្រាប់ពួកគេនូវអ្វីដែលត្រូវធ្វើ*

*គ្រូអនុវត្តតាមសៀវភៅសិក្សារបស់ក្រសួង*

អ្នកសម្របសម្រួលនិយាយថាមានចំលើយជាច្រើនចំពោះសំនួរនេះ។ នេះគឺជាឯកសារដែលសង្ខេបពីមធ្យោបាយផ្សេងៗ (**ឯកសារទី១០**)ដែលគ្រូត្រូវដឹងថាខ្លួនត្រូវធ្វើអ្វី។ សូមអានរួចហើយពិភាក្សាជាក្រុម។ បើសិនជាមានសំនួរឬការអធិប្បាយពន្យល់ចូរសួរនៅពេលបញ្ចប់ការអាន។

- **កម្មវិធីសិក្សាបឋមសិក្សាជាតិ**បង្ហាញពីគោលបំណងចំបងៗនៃការអប់រំនៅបឋមសិក្សា មុខវិជ្ជា ការបែងចែកម៉ោងតាមកំរិតថ្នាក់ ( គ្រូភាគច្រើនមិនប្រើឯកសារនេះទេ)
- **កម្មវិធីតាមមុខវិជ្ជា** សំរាប់មុខវិជ្ជានីមួយៗនៅបឋមសិក្សាដែលបង្ហាញពីគោលបំណងចំបងៗ ការសង្ខេប ខ្លឹមសារ និងដំណើរការគ្រប់ថ្នាក់ទាំងអស់នៅបឋមសិក្សាក្នុងមុខវិជ្ជានីមួយៗ ( គ្រូភាគច្រើនមិនប្រើឯកសារ នេះទេ)
- **សៀវភៅសិស្ស** មានការរៀបចំទៅតាមថ្នាក់តាមមុខវិជ្ជាមានបង្ហាញពីអ្វីដែលត្រូវបង្រៀនក្នុង១ឆ្នាំសិក្សា ( គ្រូនិងសិស្សភាគច្រើនប្រើប្រាស់ឯកសារនេះប្រចាំថ្ងៃ)
- **សៀវភៅគ្រូ** សៀវភៅនេះផ្តល់នូវគំនិតបន្ថែមសំរាប់ការបង្រៀនមេរៀនផ្សេងៗនៅក្នុងសៀវភៅសិស្សហើយមានប្រយោជន៍ណាស់ បើសិនជាគ្រូពុំយល់ច្បាស់ពីខ្លឹមសារសៀវភៅសិស្សឬកំពុងតែព្យាយាមសរសេរកិច្ចតែង

ការបង្រៀន( គ្រូភាគច្រើនពុំមានពេលប្រើប្រាស់សៀវភៅគ្រូនេះបានពេញលេញទេ) ។

- **ឯកសារសង្ខេបមេរៀនដែលត្រូវបង្រៀនប្រចាំខែ** ឯកសារនេះបានពីការិយាល័យអប់រំស្រុកដែលបង្ហាញមេរៀននៅក្នុងសៀវភៅសិស្សសំរាប់ការបង្រៀនតាមខែនីមួយៗ ( គ្រូភាគច្រើនបំផុតអនុវត្តទៅតាមឯកសារនេះ)
- **កាលវិភាគសាលា** ត្រូវបានធ្វើដោយនាយកសាលាដែលបង្ហាញពីម៉ោងបត្រូវបង្រៀនក្នុងសប្តាហ៍នីមួយៗ។
- **គ្រូបង្រៀនក៏អាចប្រើបទពិសោធន៏ផ្ទាល់ខ្លួន** និងគំនិតក្នុងការផ្លាស់ប្តូរខ្លឹមសារមេរៀននិងរបៀបបង្រៀនដើម្បីធ្វើអោយមានលក្ខណៈសមស្របទៅនឹងគំនិតយល់ដឹងរបស់កុមារនិងតំបន់នៃសាលារៀននោះ (ឧទាហរណ៍ ផ្លាស់ប្តូរខ្លឹមសារមេរៀននៅក្នុងសៀវភៅសិស្សសិក្សាសង្គមអំពីភូមិវិទ្យាក្នុងតំបន់ ទីកន្លែង ស្ថាប័នផ្សេងៗដើម្បីអោយសមស្របទៅនឹងតំបន់ដែលកុមារកំពុងរស់នៅ) ។

សិក្ខាកាមអាននិងពិភាក្សាក្រុមតូច រួចហើយសួរសំនួរឬលើកបញ្ហាទៅកាន់អ្នកសម្របសម្រួល។

**ថ្ងៃទី៣**

**ដំណាក់កាលបង្រៀនទី២:កម្មវិធីសិក្សាបឋមសិក្សា-មុខវិជ្ជានិងម៉ោងបង្រៀន** **៦០ នាទី**

អ្នកសម្របសម្រួលនិយាយថា: បច្ចុប្បន្ននេះក្រសួងរៀបចំធ្វើការផ្លាស់ប្តូរលើកម្មវិធីសិក្សា។ ឯកសារ (**ឯកសារទី១១**) ដែលផ្តល់ជូននៅពេលឥឡូវនេះជាតារាងសង្ខេបអំពីការរៀបចំមុខវិជ្ជា និងម៉ោងបង្រៀនតាមកម្មវិធីចាស់សំរាប់ប្រៀបធៀបជាមួយនឹងកម្មវិធីថ្មី។ យើងផ្តល់អោយលោក/លោកស្រីចំនួន១០នាទីដើម្បីមើលឯកសាររួចហើយយើងនឹង ពិភាក្សា។

មុខវិជ្ជា(**ម៉ោង/សប្តាហ៍**) នៅសាលាបឋមសិក្សាពីថ្នាក់ទី១-៦នៅក្នុងប្រទេសកម្ពុជា

| **មុខវិជ្ជា** | **ថ្នាក់ទី១** | **ថ្នាក់ទី២** | **ថ្នាក់ទី៣** | **ថ្នាក់ទី៤** | **ថ្នាក់ទី៥** | **ថ្នាក់ទី៦** |
|---|---|---|---|---|---|---|
| ភាសាខ្មែរ | ១៣ | ១១ | ១១ | ១០ | ៨ | ៨ |
| គណិតវិទ្យា | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| វិទ្យាសាស្ត្រ | ១ | ២ | ២ | ២ | ២ | ២ |
| សិក្សាសង្គម | ៥ | ៦ | ៦ | ៧ | ៨ | ៨ |
| កីឡា | ១ | ១ | ១ | ១ | ១ | ១ |
| ភាសាបរទេស | | | | | ១ | ១ |

| | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ |
|---|---|---|---|---|---|---|

អ្នកសម្របសម្រួលសួរសិក្ខាកាមនូវសំនួរមួយចំនួនដែលតំរូវអោយពួកគេបកស្រាយព័ត៌មាននៅក្នុងតារាងទាំងពីរ ។ ឧទាហរណ៍សំនួរ

១. តើមុខវិជ្ជានិងម៉ោងបង្រៀនដូចគ្នាលើគ្រប់មុខវិជ្ជាទាំងអស់ឬទេ?
២. តើមានមុខវិជ្ជាប៉ុន្មាននៅក្នុងកម្មវិធីសិក្សាថ្មីថ្នាក់ទី១?
៣. តើម៉ោងសម្រាប់មុខវិជ្ជាគណិតវិទ្យានៅគ្រប់កំរិតថ្នាក់ដូចគ្នាឬទេ?
៤. តើមុខវិជ្ជាភាសាខ្មែរនៅថ្នាក់ទី៣មានប៉ុន្មានម៉ោង?
៥. មានម៉ោងច្រើនសំរាប់បង្រៀនភាសាខ្មែរថ្នាក់ទី១ជាងថ្នាក់ទី៦-តើពិតឬមិនពិត?
៦. តើម៉ោងបង្រៀនសរុបលើមុខវិជ្ជាទាំងអស់ដូចគ្នាឬទេក្នុងគ្រប់កំរិតថ្នាក់ទាំងអស់?
៧. តើមុខវិជ្ជាអ្វីដែលមានបង្រៀនតែនៅថ្នាក់ទី៥និងទី៦?
៨. តើមុខវិជ្ជាអ្វីដែលមានម៉ោងច្រើនជាងគេ? តើមុខវិជ្ជាអ្វីដែលមានម៉ោងច្រើនជាងគេលំដាប់ទី២នៅក្នុងថ្នាក់ទី១, ថ្នាក់ទី៣ និងថ្នាក់ទី៦?

*ចំលើយរំពឹងទុក: ១. ទេ ២. ៥មុខវិជ្ជា ៣.បាទ/ចាស់ ៤.១១ ម៉ោង ៥. ពិត ៦. បាទ/ចាស់ ៧. ភាសាបរទេស ៨. មុខវិជ្ជាភាសាខ្មែរមានម៉ោងច្រើនជាងគេ ។ មុខវិជ្ជាដែលមានម៉ោងបង្រៀនច្រើនជាងគេទី២គឺគណិតវិទ្យានិងសិក្សាសង្គមក្នុងថ្នាក់ទី១ និងសិក្សាសង្គមក្នុងថ្នាក់ទី៣និងទី៦ ។*

អ្នកសម្របសម្រួលសន្និដ្ឋានបញ្ចប់ដោយនិយាយថា ក្រសួងអប់រំកំពុងរៀបចំនយោបាយថ្មីលើម៉ោងបង្រៀនសំរាប់មុខវិជ្ជាទាំងអស់នៅបឋមសិក្សា ។ ការរៀបចំនេះអាចនឹងចាប់ផ្តើមនៅឆ្នាំនេះឬឆ្នាំក្រោយ ។

**ថ្ងៃទី៣**

**ដំណាក់កាលបង្រៀនទី៣: សៀវភៅសិស្សនិងសៀវភៅគ្រូ** ១៨០ នាទី

**៣.១ សេចក្តីផ្តើម** ២០ នាទី

អ្នកសម្របសម្រួលនិយាយថាដំណាក់កាលបន្ទាប់នេះគឺមានរយៈពេលយូរ ។ ដំណាក់កាលនេះបង្ហាញពីប្រធានបទសំខាន់៧នៃសៀវភៅសិស្សនិងសៀវភៅគ្រូដែលបង្កើតដោយក្រសួងអប់រំ ។ សៀវភៅសិស្សនិងសៀវភៅគ្រូគឺជាធនធាន

សំខាន់សំរាប់គ្រូបង្រៀនដើម្បីបង្រៀនសិស្ស ដូច្នោះពួកគេត្រូវតែដឹងនិងស្វែងយល់ពីរបៀបប្រើប្រាស់។ អ្នកសម្របសម្រួលនិយាយថា មានសៀវភៅសិស្សចំនួន៤ក្បាលនិងសៀវភៅគ្រូ៤ក្បាលសំខាន់ៗសំរាប់កំរិតថ្នាក់នីមួយៗ។ អ្នកសម្របសម្រួលសួរសិក្ខាកាមថាតើពួកគេអាចទស្សន៍ទាយអំពីសៀវភៅសិស្សនិងសៀវភៅគ្រូឬទេថា សៀវភៅទាំងនោះសំរាប់នរណានិងបំរើអោយគោលបំណងអ្វី? អ្នកសម្របសម្រួលសរសេរគំនិតរបស់សិក្ខាកាមដាក់លើតារាង (ដូចតារាងខាងក្រោមដែលមានចំលើយរំពឹងទុកជាអក្សរទ្រេត)

| **សៀវភៅសិស្ស (TX)** | **សៀវភៅគ្រូ (TM)** |
|---|---|
| *សំរាប់កុមារប្រើប្រាស់* | *សំរាប់គ្រូប្រើប្រាស់* |
| *ដើម្បីជួយកុមារអោយរៀន* | *ដើម្បីជួយគ្រូអោយយល់ខ្លឹមសារ* |
| *ដើម្បីផ្តល់កិច្ចការអោយកុមារធ្វើ* | *ដើម្បីជួយគ្រូក្នុងការធ្វើកិច្ចតែងការបង្រៀន* |
| *សំរាប់អោយកុមារធ្វើកិច្ចការនៅផ្ទះ* | *ដើម្បីផ្តល់គំនិតដល់គ្រូសំរាប់ការបង្រៀន* |
| *។ល។* | *។ល។* |

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមបង្កើតជា៦ក្រុម មួយក្រុមមួយកំរិតថ្នាក់។ បើសិនជាសិក្ខាកាមដឹងថាគេត្រូវនៅថ្នាក់ណាមួយពួកគេគួរតែរួមគ្នាតែមួយក្រុមទៅតាមកំរិតថ្នាក់នោះ (អ្នកសម្របសម្រួលត្រូវធ្វើការលៃលកចំនួនមនុស្សនៅក្នុងក្រុមអោយបានសមរម្យកុំអោយច្រើនពេកឬតិចពេក)។

**៣.២ ភាសាខ្មែរ** ៦០ នាទី

បន្ទាប់មកអ្នកសម្របសម្រួលចែកសៀវភៅសិស្ស សៀវភៅគ្រូភាសាខ្មែរទៅតាមកំរិតថ្នាក់ទៅអោយក្រុមនីមួយៗទាំង៦គឺថ្នាក់ទី១ ដល់ថ្នាក់ទី៦។

**កិច្ចការទី១** (៣០ នាទី) អ្នកសម្របសម្រួលអោយក្រុមនីមួយៗមើលសៀវភៅសិស្សភាសាខ្មែរយ៉ាងរហ័សទៅតាមកំរិតថ្នាក់ដោយអោយមើលទៅលើរចនាសម្ព័ន្ធនិងការរៀបចំសៀវភៅ រួចហើយឆ្លើយសំនួរខាងក្រោមដោយមានការកត់ត្រាចំលើយផង។

**តើសៀវភៅនេះមានប៉ុន្មានជំពូក?**

**នៅក្នុងជំពូកនិមួយៗមានប្រធានបទប៉ុន្មាន?**

តើនៅក្នុងសៀវភៅទាំងមូលមានប្រធានបទប៉ុន្មាន?

តើនៅក្នុងប្រធានបទនិមួយៗមានបំនិនប៉ុន្មាន? អ្វីខ្លះ។

តើមាននិមិត្តសញ្ញាអ្វីខ្លះដែលប្រើនៅក្នុងសៀវភៅនេះហើយវាមានន័យដូចម្តេច?

នៅពេលសិក្ខាកាមបានឆ្លើយសំនួរអស់ ពួកគេឡើងរាយការណ៍ពីលទ្ធផលហើយអ្នកសម្របសម្រួលសរុបបញ្ចប់ សកម្មភាព។

ក្រុមក្រោយៗមិនគួរបង្ហាញឡើងវិញជាពិស្តារនូវអ្វីដែលបានរកឃើញឡើយ បើសិនជាក្រុមមុនៗបានបកស្រាយបង្ហាញរួចហើយ-ពួកគេគ្រាន់តែនិយាយថាចំលើយចំពោះសំនួរនេះគឺដូចក្រុមមុនដែរ ពោលគឺផ្តោតទៅលើតែអ្វីដែលជាចំលើយខុសគ្នា។

**កិច្ចការទី២** (៣០ នាទី): អ្នកសម្របសម្រួលអោយក្រុមនីមួយៗមើល**សៀវភៅ**គ្រូភាសាខ្មែរយ៉ាងរហ័សទៅតាមកំរិតថ្នាក់ដោយមើលទៅលើការរៀបចំនៃសៀវភៅ (**មិនមែនខ្លឹមសារ**) (ឧទាហរណ៍ ក្រប បញ្ជីខ្លឹមសារ ជំពូក ប្រធានបទ មេរៀន និមិត្តសញ្ញា។ល។ បន្ទាប់មកក្រុមទាំងអស់ចាប់ផ្តើមឆ្លើយសំនួរឈុតទី២**អំពីសៀវភៅ**គ្រូខាងក្រោមដោយមានកំណត់សំគាល់ ចំលើយផង។

តើសៀវភៅនេះមានប៉ុន្មានជំពូក?

តើនៅក្នុងជំពូកនិមួយៗមានប្រធានបទប៉ុន្មាន?

តើនៅក្នុងសៀវភៅទាំងមូលមានប្រធានបទប៉ុន្មាន?

តើនៅក្នុងប្រធានបទនិមួយៗមានបំនិនប៉ុន្មាន? អ្វីខ្លះ។

តើមាននិមិត្តសញ្ញាអ្វីខ្លះដែលប្រើនៅក្នុងសៀវភៅនេះហើយវាមានន័យដូចម្តេច?

សិក្ខាកាមឡើងរាយការណ៍ដោយចៀសវាងចំលើយជាន់គ្នាហើយអ្នកសម្របសម្រួលពន្យល់បន្ថែមបើចាំបាច់។

**៣.៣ គណិតវិទ្យា** ៤០ នាទី

អ្នកសម្របសម្រួលអោយសិក្ខាកាមបង្កើតជា៦ក្រុមទៅតាមកំរិតថ្នាក់ ហើយផ្តល់សៀវភៅ**គណិតវិទ្យា**សិស្សនិងគ្រូទៅតាមកំរិតដែលក្រុមនីមួយៗទទួលបន្ទុក។

**កិច្ចការទី១** (២០ នាទី) អ្នកសម្របសម្រួលអោយក្រុមនីមួយៗមើលសៀវភៅសិស្ស**គណិតវិទ្យា**យ៉ាងរហ័សទៅតាម

ក៏រិតថ្នាក់ ហើយឆ្លើយសំនួរខាងក្រោម

**តើសៀវភៅនេះមានប៉ុន្មានជំពូក?**
**តើនៅក្នុងជំពូកនិមួយៗមានប្រធានបទប៉ុន្មាន?**
**តើនៅក្នុងសៀវភៅទាំងមូលមានប្រធានបទប៉ុន្មាន?**
**តើមាននិមិត្តសញ្ញាអ្វីដែលប្រើក្នុងសៀវភៅនេះឬទេហើយវាមានន័យដូចម្តេច?**

ក្រុមនីមួយៗឡើងរាយការណ៍ចាប់ផ្តើមពីថ្នាក់ទី១ដោយចៀសវាងចំលើយជាន់គ្នា។

**កិច្ចការទី២** (២០ នាទី): អ្នកសម្របសម្រួលអោយសិក្ខាកាមមើលសៀវភៅ**គណិតវិទ្យាសំរាប់**គ្រូទៅតាមក៏រិតថ្នាក់ ហើយធ្វើការកត់សំគាល់លើរចនាសម្ព័ន្ធ (ឧទាហរណ៏ វត្ថុបំណង ប្រធានបទនីមួយៗ សម្ភារ ពាក្យគន្លឹះ ម៉ោងកំណត់ សកម្មភាព ការវាយតំលៃ...)

ក្រុមនីមួយៗឡើងរាយការណ៍ចាប់ផ្តើមពីថ្នាក់ទី១ដោយចៀសវាងចំលើយជាន់គ្នា។

**៣.៤ សៀវភៅសិក្សាសង្គមនិងវិទ្យាសាស្ត្រអនុវត្ត** ៤០ នាទី

អ្នកសម្របសម្រួលអោយសិក្ខាកាមបង្កើតជា៦ក្រុមទៅតាមក៏រិតថ្នាក់ ហើយផ្តល់សៀវភៅសិក្សាសង្គមសំរាប់សិស្សនិងគ្រូទៅអោយក្រុមថ្នាក់ទី១ ទី៣ និងទី៥ ហើយផ្តល់**សៀវភៅវិទ្យាសាស្ត្រអនុវត្ត**សំរាប់គ្រូនិងសិស្សទៅអោយក្រុមទី២ ទី៤ និងទី៦។

**កិច្ចការទី១** (២០ នាទី): អ្នកសម្របសម្រួលអោយក្រុមនីមួយៗមើល**សៀវភៅសិក្សាសង្គម**សំរាប់សិស្សនិង**សៀវភៅវិទ្យាសាស្ត្រអនុវត្ត**សំរាប់សិស្សយ៉ាងរហ័សទៅតាមក្រុមដែលកំណត់រួចហើយ បន្ទាប់មកអោយឆ្លើយសំនួរខាងក្រោមៈ

**តើសៀវភៅនេះមានប៉ុន្មានជំពូក?**
**តើនៅក្នុងជំពូកនីមួយៗមានប្រធានបទប៉ុន្មាន?**
**តើនៅក្នុងសៀវភៅទាំងមូលមានប្រធានបទប៉ុន្មាន?**
**តើមាននិមិត្តសញ្ញាអ្វីដែលប្រើក្នុងសៀវភៅនេះឬទេហើយវាមានន័យដូចម្តេច?**

ក្រុមនីមួយៗឡើងរាយការណ៍ចាប់ផ្តើមពីថ្នាក់ទី១ដោយចៀសវាងចំលើយជាន់គ្នា។

**កិច្ចការទី២** (២០ នាទី): អ្នកសម្របសម្រួលអោយសិក្ខាកាមមើល**សៀវភៅសិក្សាសង្គម**និង**សៀវភៅវិទ្យាសាស្ត្រ អនុវត្ត**សំរាប់គ្រូទៅតាមកំរិតថ្នាក់ដោយធ្វើការកត់សំគាល់ទៅលើរចនាសម្ព័ន្ធ (ឧទាហរណ៍ វត្ថុបំណងប្រធានបទ នីមួយៗ សម្ភារ ពាក្យគន្លឹះ ម៉ោងកំនត់ សកម្មភាព ការវាយតំលៃ...) ។

ក្រុមនីមួយៗឡើងរាយការណ៍ចាប់ផ្តើមពីថ្នាក់ទី១ដោយជៀសវាងចំលើយជាន់គ្នា។

**៣.៥ ការវិភាគជំពូកនៅក្នុងសៀវភៅសិស្ស** (សៀវភៅសិក្សាសង្គមថ្នាក់ទី៣ ជំពូកទី១៨) ៣០ នាទី

អ្នកសម្របសម្រួលប្រាប់ក្រុមទាំងអស់អោយមើលសៀវភៅសិស្ស មុខវិជ្ជាសិក្សាសង្គមសំរាប់ថ្នាក់ទី៣ជំពូក១៨ដោយពិភាក្សានិងឆ្លើយសំនួរខាងក្រោម។

| **សំនួរ** | ***ចំលើយរំពឹងទុក*** |
|---|---|
| តើអ្វីជាប្រធានបទសំខាន់នៅក្នុងជំពូកទី១៨? | *ការសំអាត* |
| តើនៅក្នុងជំពូកនេះមានប៉ុន្មានផ្នែក (មេរៀន)? | *៣* |
| តើផ្នែក (មេរៀន)នីមួយៗនិយាយអំពីអ្វី? | *(១) សំអាតកាយ (២) សំអាតមាត់ ធ្មេញ (៣) សំអាតផ្ទះសំបែង* |
| តើផ្នែក (មេរៀន)នីមួយៗបង្រៀនប៉ុន្មានម៉ោង? | *១ ម៉ោង* |
| តើវត្ថុបំណងនៅក្នុងផ្នែក (មេរៀន) នេះរួមបញ្ចូល ចំណេះដឹង បំនិន និងឥរិយាបទ ឬទេ? ចូរផ្តល់ឧទាហរណ៍សំរាប់ផ្នែកនីមួយៗ | *បាទ/ចាស់ (ចំលើយរបស់សិក្ខាកាម)* |

ក្រុមនីមួយៗឡើងរាយការណ៍ចាប់ផ្តើមពីថ្នាក់ទី១ដោយចៀសវាងចំលើយជាន់គ្នា។

**ថ្ងៃទី៣**

**ដំណាក់កាលបង្រៀនទី៤: រចនាសម្ព័ន្ធអធិការកិច្ច** (អធិការ នាយក ប្រធានក្រុមបច្ចេកទេស) ៤៥ នាទី

អ្នកសម្របសម្រួលនិយាយថា: ឥឡូវនេះយើងចង់ពិភាក្សាអំពីការគាំទ្រដែលអាចទទួលបាននៅក្នុងប្រព័ន្ធអប់រំដើម្បីធ្វើអោយការងារមានការរីកចំរើន។ មានមធ្យោបាយសំខាន់ៗ៥ដែលគ្រូបង្រៀននឹងទទួលបានហើយខ្លឹមសារត្រូវបានគេសង្ខេបនៅក្នុងឯកសារ (**ឯកសារទី១២**) ដែលនឹងចែកជូន។ ចូរអាននិងពិភាក្សាជាមួយលោក/លោកស្រីដែលនៅ ក្បែរ។

ឯកសារអំពីឈ្មោះនិងការបរិយាយសង្ខេបពីតួនាទីនិងទំនាក់ទំនង

១. **អធិការនិងគ្រូឧទ្ទេស** មកពីមន្ទីរអប់រំ/ការិយាល័យអប់រំស្រុកមានតួនាទីសង្កេតថ្នាក់រៀន បើកវគ្គវិក្រឹតការកំណត់ការទស្សនៈកិច្ចទៅតាមសាលានៅជនបទដាច់ស្រយាល។
២. **នាយកសាលា** ទទួលខុសត្រូវខាងការសង្កេតថ្នាក់រៀន ផ្តល់ព័ត៌មានកែលំអ ទទួលខុសត្រូវការងាររដ្ឋបាល (នាយកសាលាមួយចំនួនមានភាពសកម្មខ្លះទៀតមិនសកម្មទេ)
៣. **នាយករងសាលា** ទទួលខុសត្រូវខាងបច្ចេកទេសនិងមួយផ្នែកទៀតលើការសង្កេតថ្នាក់រៀន (នាយករងមួយចំនួនមានភាពសកម្មខ្លះទៀតមិនសកម្មទេ)
៤. **ប្រធានក្រុមបច្ចេកទេសTGL** មាន២ប្រភេទគឺប្រធានក្រុមបច្ចេកទេសថ្នាក់សាលានិងប្រធានក្រុមបច្ចេកទេសថ្នាក់កម្រងដែលទទួលខុសត្រូវលើការប្រជុំរាល់ថ្ងៃព្រហស្បតិ៍ រៀបចំការបង្រៀនបង្ហាញគំរូការធ្វើកិច្ចតែងការជាក្រុម ការពិភាក្សារាល់បញ្ហាដែលកើតមានក្នុងចំណោមគ្រូបង្រៀនទៅតាមកំរិតថ្នាក់ (ប្រធានក្រុមបច្ចេកទេសខ្លះមានភាពសកម្មខ្លះទៀតមិនសកម្មទេ)
៥. **គ្រូផ្សេងៗទៀត**-តាមពិតគ្រូទាំងនេះពុំមានការទទួលខុសត្រូវជាផ្លូវការទេ ប៉ុន្តែពួកគេគឺជាប្រភពមួយសំខាន់សំរាប់ផ្តល់ដំបូន្មានអំពីអ្វីដែលចាំបាច់ត្រូវធ្វើ របៀបដោះស្រាយបញ្ហា "ប្រភពជួយ សង្គ្រោះ"។

សិក្ខាកាមអាននិងពិភាក្សាជាក្រុមតូចរួចហើយលើកបញ្ហាឬសំនួរទៅកាន់អ្នកសម្របសម្រួល។

**ថ្ងៃទី៣**

**ដំណាក់កាលបង្រៀនទី៥: ប្រព័ន្ធកម្រងសាលារៀន និងការគាំទ្រគ្រូបង្រៀន ៤៥ នាទី**

អ្នកសម្របសម្រួលនិយាយថាដំណាក់កាលនេះនឹងបង្ហាញអំពីសេចក្តីសង្ខេបនៃបញ្ញត្តិកម្រងសាលា ប្រភេទសាលាដែលស្ថិតនៅក្នុងកម្រងនោះ មុខងារមូលដ្ឋាននិងការរៀបចំផ្សេងៗពីព្រោះវានឹងមានផលប៉ះពាល់ដល់គ្រូសហគមន៍ថ្មី។

អ្នកសម្របសម្រួលអោយសិក្ខាកាមអានឯកសារ (**ឯកសារទី១៣**) ដែលមានបញ្ជីឈ្មោះមនុស្សសំខាន់ៗហើយនិងស្ថាប័ននៅក្នុងកម្រងព្រមទាំងការបរិយាយខ្លីៗអំពីការទទួលខុសត្រូវរបស់ពួកគេ។ ឯកសារនេះមានដូចខាងក្រោម...

**សាលាកម្រង:** គឺជាការរួមផ្តុំគ្នានៃសាលាបឋមសិក្សាដែលធ្វើការជាមួយគ្នាដើម្បីចែករំលែកធនធាន (ធនធានជាក់ស្តែងនិងធនធានមនុស្ស ហើយជួនកាលក៏មានធនធានហិរញ្ញវត្ថុទៀតផង) និងបទពិសោធន៍។ កម្រងនេះមានប្រយោជន៍ណាស់នៅក្នុងប្រទេសកម្ពុជាពីព្រោះវាជាកន្លែងសំរាប់អ្នកគ្រប់គ្រងការអប់រំ គ្រូបង្រៀន និងសហគមន៍ក្នុងមូលដ្ឋានជួបប្រជុំគ្នាធ្វើការបណ្តុះបណ្តាល ធ្វើផែនការនិងការតាមដានត្រួតពិនិត្យ។ នៅក្នុងសាលាកម្រងបែងចែកជាសាលាបង្គោលមួយនិងសាលាឧបសម្ព័ន្ធជាច្រើនទៀត។ សាលាទាំងអស់នៅក្នុងកម្រងត្រូវបានកំណត់ចំងាយប្រមាណ៧គីឡូម៉ែត្រពីសាលាបង្គោលដើម្បីធ្វើអោយ នាយកសាលា គ្រូបង្រៀននិងតំណាងសហគមន៍ជួបប្រជុំគ្នាដោយងាយស្រួលដោយពុំមានការចំណាយលុយកាក់ធ្វើដំណើរច្រើន។

**ប្រភេទសាលាកម្រង:** សាលាកម្រងមាន៤ប្រភេទចំបងៗគឺ: (១) កម្រងធម្មតា: គឺជាក្រុមសាលាមួយក្រុមដែលមានចំងាយប្រហែល៧គីឡូម៉ែត្រជុំវិញសាលាបង្គោលហើយរាល់ការធ្វើដំណើរមានភាពងាយស្រួល។ (២) កម្រងប្រជុំជន: គឺជាកម្រងដែលមានសាលានៅជិតៗគ្នាហើយមានទំហំធំដែលជាធម្មតាមានតែនៅក្នុងទីប្រជុំជនឬទីរួមខេត្ត។ (៣) កម្រងដាច់ស្រយាល: គឺជាកម្រងដែលសាលាភាគច្រើនមានចំងាយឆ្ងាយពីគ្នាហើយពុំអាចធ្វើការប្រជុំបាន។ (៤) កម្រងមិនធម្មតា: គឺជាកម្រងដែលសាលាភាគច្រើនស្ថិតនៅជិតៗគ្នាគឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងកម្រងធម្មតាដែរក៏ប៉ុន្តែនៅក្នុងកម្រងនេះមានសាលាពីរឬបីស្ថិតនៅឆ្ងាយជាងគេណាស់។

**នាយកកម្រង:** គឺជានាយកម្នាក់នៅក្នុងចំណោមនាយកទាំងអស់នៅក្នុងកម្រង។ នាយកកម្រងត្រូវធ្វើជាអធិបតីនៅក្នុងការប្រជុំគណៈកម្មការកម្រងសាលាមូលដ្ឋានដែលជួយដល់នាយកសាលាលើកិច្ចការគ្រប់គ្រង ជួយដល់ប្រធានក្រុមបច្ចេកទេសក្នុងការប្រជុំរាល់ថ្ងៃព្រហស្បតិ៍។

**ប្រធានក្រុមបច្ចេកទេសកម្រង:** ប្រធានក្រុមបច្ចេកទេសកម្រងត្រូវបានជ្រើសរើសទៅតាមកំរិតថ្នាក់នីមួយៗពីសាលានៅក្នុងកម្រង។ ប្រធានក្រុមបច្ចេកទេសត្រូវទទួលខុសត្រូវលើការអនុវត្តការប្រជុំបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍និងជួយដល់គ្រូបង្រៀនទៅតាមកំរិតថ្នាក់ដើម្បីពង្រីកការបង្រៀន។

**សាលាបង្គោល:** ជាសាលានៅក្នុងកម្រងដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅចំកណ្តាលរវាងចំងាយ៧គីឡូម៉ែត្រពីសាលាឧបសម្ព័ន្ធផ្សេងៗ។ នាយកសាលានឹងគ្រូបង្រៀនទាំងអស់ជួបប្រជុំគ្នានៅសាលាបង្គោលដើម្បីអភិវឌ្ឍអាជីពដែលធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ រយៈពេលមួយឬពីរដងក្នុងមួយខែ។

**គណៈកម្មការកម្រងសាលារៀនមូលដ្ឋានៈ**

សមាជិកនៃគណៈកម្មការនេះគឺមាននាយកសាលាបឋមសិក្សានៅក្នុងកម្រងទាំងអស់ ប្រធានក្រុមបច្ចេកទេស តំណាងសហគមន៍ នាយកសាលាមធ្យមសិក្សាបឋមភូមិ (បើមាន) និងអ្នកតំណាងមកពីក្រុមប្រឹក្សា ឃុំ ឬគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ។ នៅពេលកម្រងសាលាទទួលការគាំទ្រពីអង្គការអន្តរជាតិឬអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ណាមួយ ដូចជាអេស្កាប់នេះជាដើម។ គណៈកម្មការកម្រងសាលារៀនមូលដ្ឋាននោះមានតួនាទីសំខាន់ណាស់ក្នុងការធ្វើការសម្រេចចិត្តលើការប្រើប្រាស់មូលនិធិនោះ។ ចំពោះប្រាក់ PAP សាលាទាំងអស់ត្រូវសម្រេចចិត្តខ្លួនឯងប៉ុន្តែកម្រង គឺជាវេទិការមួយដែលមានប្រយោជន៍ណាស់សំរាប់ការពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ ហើយធានាថាការធ្វើផែនការ និងការគ្រប់គ្រងប្រាក់ PAP មានលក្ខណៈត្រឹមត្រូវ។

**សាលាសម្ព័ន្ធៈ** គឺជាសាលាបឋមសិក្សាផ្សេងៗទៀតដែលស្ថិតក្នុងកម្រងប៉ុន្តែមិនមែនជាសាលាបង្គោលទេ។ គ្រូបង្រៀនជាធម្មតាជួបប្រជុំគ្នានៅថ្ងៃព្រហស្បតិ៍នៅសាលាផ្ទាល់របស់ពួកគេឬនៅក្បែរសាលារៀននោះ ក្នុងពេលដែលគេមិនមានកម្មវិធីត្រូវទៅប្រជុំនៅសាលាបង្គោល។

ក្នុងពេលដែលសិក្ខាកាមអានឯកសារ អ្នកសម្របសម្រួលគួរដង្វាក្រាមនៅលើក្តារខៀនអំពីកម្រងសាលាដោយបង្ហាញពី ផ្លូវ ទន្លេ ចំងាយនិងដោយប្រើសញ្ញាផ្សេងៗសំរាប់បង្ហាញពីសាលាបង្គោលនិងសាលាសម្ព័ន្ធ។ បន្ទាប់ពីការអានសិក្ខាកាមអាចលើកបញ្ហានិងសួរសំនួរ។ អ្នកសម្របសម្រួលអាចឆ្លើយតបដោយប្រើដ្យាក្រាម។

អ្នកសម្របសម្រួលគួរតែពន្យល់បន្ថែមថា កម្រងគឺមានសារៈសំខាន់ណាស់នៅក្នុងគំរោងអេស្កាប់ពីព្រោះមធ្យោបាយសំខាន់ដែលអេស្កាប់កំពុងព្យាយាមជួយសាលារៀនគឺតាមរយៈការផ្តល់អំណោយតាមកម្រង។

**ថ្ងៃទី៣**

**ដំណាក់កាលបង្រៀនទី៦ៈ ការគាំទ្រពី អេស្កាប់/ESCUP** **២០ នាទី**

អ្នកសម្របសម្រួលផ្តល់ឯកសារសង្ខេប អំពីមធ្យោបាយសំខាន់ៗដែលអេស្កាប់នឹងជួយគាំទ្រគ្រូសហគមន៍ (ដោយប្រើតារាងដែលបានរៀបចំនៅលើក្រដាសធំ) និងឯកសារគាំទ្រ (**ឯកសារទី១៤**)។

- ការផ្តួចផ្តើមការបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ និងការផ្តល់កញ្ចប់សម្ភារផ្សេងៗ។
- ការប្រជុំប្រចាំខែ

- ការទទួលបាននូវធនធានមនុស្សពីអេស្កាប់
- ការទទួលបាននូវការគាំទ្រនៅក្នុងប្រព័ន្ធក្រសួងអប់រំ
- ការតាមដានត្រួតពិនិត្យដោយគណៈកម្មការកម្រងសាលាមូលដ្ឋាននិងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ
- ការបើកប្រាក់ខែទៀងទាត់ដោយគណៈកម្មការកម្រងសាលាមូលដ្ឋាននិងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ

បន្ទាប់មកអ្នកសម្របសម្រួលអនុញ្ញាតអោយគ្រូសហគមន៏សួរសំណួរផ្សេងៗ។

អ្នកសម្របសម្រួលចែកអោយសិក្ខាកាមនូវឯកសារព័តិមានទូទៅអំពីអេស្កាប់ ប៉ុន្តែមិនត្រូវបានយកមកពិភាក្សានៅក្នុងពេលបណ្តុះបណ្តាលនោះទេ។

## ថ្ងៃទី៤ ការរៀបចំការបង្រៀន និងរៀននៅក្នុងថ្នាក់រៀន

ថ្ងៃទី៤

ដំណាក់កាលបង្រៀនទី១: ការណែនាំបង្ហាញ ពីគំនិតនៃមេរៀន ១៥ នាទី

អ្នកសម្របសម្រួលនិយាយថា: នៅពេលលោក/លោកស្រីទៅបង្រៀនជារៀងរាល់ថ្ងៃលោក/លោកស្រីត្រូវមានគំនិតថានឹងត្រូវបង្រៀនអ្វីមួយ។

អ្នកសម្របសម្រួលនិយាយថា: យើងបានដឹងពីម្សិលមិញហើយថាគ្រូបង្រៀននៅប្រទេសកម្ពុជាអនុវត្តតាមកម្មវិធីសិក្សាជាតិនិងប្រើសៀវភៅសិស្ស សៀវភៅគ្រូសំរាប់មេរៀនរបស់គេដូច្នោះលោក/លោកស្រីដឹងហើយថារាល់ថ្ងៃនីមួយៗត្រូវបង្រៀនភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គមនិងវិទ្យាសាស្រ្តអនុវត្ត។

អ្នកសម្របសម្រួលនិយាយថា: គ្រូភាគច្រើនបែងចែកការបង្រៀនជាផ្នែកៗទៅតាមថ្ងៃនីមួយៗ។ សាលាបឋមសិក្សារដ្ឋភាគច្រើនអនុវត្តតាមកម្មវិធីបង្រៀនដែលមានរយៈពេល៤ម៉ោងក្នុងមួយថ្ងៃដោយបំបែកទៅជា៤*មេរៀន* ហើយមេរៀននីមួយៗមានរយៈពេល ៤៥ នាទី។

**អ្នកសម្របសម្រួលសួរសិក្ខាកាម: តើកាលវិភាគសំរាប់បង្រៀនពេលព្រឹកនិងពេលរសៀលនៅសាលាបឋមសិក្សារដ្ឋមានលក្ខណៈដូចម្តេច?**
*ចំលើយរំពឹងទុក: ឧទាហរណ៏ ពេលព្រឹកពីម៉ោង០៧០០-១១០០ ពេលរសៀលពីម៉ោង១៣០០-១៧០០ ចូលរៀនបន្ទាប់ពីគោរពទង់ជាតិ មេរៀននីមួយៗមានរយៈពេល៤៥នាទីដែលមានចេញលេង១៥នាទីក្នុងមួយពេលត្រូវបង្រៀន៤មេរៀន។*

អ្នកសម្របសម្រួលនិយាយថា: ទោះជាយ៉ាងណាក៏ដោយចូរចាំថាកុមារតូចៗចូលចិត្តអោយមានការផ្លាស់ប្តូរសកម្មភាពអោយបានញឹកញាប់ហេតុដូច្នោះគ្រូបង្រៀននៅថ្នាក់ទី ១, ២ និងទី ៣ ត្រូវចេះបង្កើតកម្មវិធីដែលមានសកម្មភាពប្លែកៗគ្នាអោយបានច្រើន។ អ្នកសម្របសម្រួលពន្យល់ផងដែរថា ក្រសួងមានគោលនយោបាយមួយអំពីវិមជ្ឈការកាលវិភាគដែលលោកគ្រូអ្នកគ្រូអាចបង្រៀនក្នុងរយៈពេលវែង និងមានការសំរាកចេញលេងក្នុងរយៈពេលខ្លីជាងនៅកំឡុងពេលព្រឹកនិងពេលរសៀល។ តែការធ្វើបែបនេះមិនមានច្រើនទេនៅតាមសាលារៀន។

**ថ្ងៃទី៤**

**ដំណាក់កាលបង្រៀនទី២: ការងារជាក្រុមធំ-ផ្នែកផ្សេងៗនៃមេរៀន ៤៥ នាទី**

អ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមធំ: **តាមរយៈបទពិសោធន៍ពីសាលារៀននិងសុភវិនិច្ឆ័យផ្ទាល់របស់**

**លោក/លោកស្រីតើមានសកម្មភាពអ្វីខ្លះដែលជាធម្មតាកើតឡើងក្នុងពេលបង្រៀន?** អ្នកសម្របសម្រួលសរសេរចំលើយរបស់សិក្ខាកាមនៅលើប័ណ្ណហើយបិទលើក្តារខៀនដូចជា

| | |
|---|---|
| ការពន្យល់របស់គ្រូបង្រៀន ( គ្រូនិយាយ) | គ្រូចែកសម្ភារ |
| គ្រូបង្រៀនបង្ហាញមេរៀនគំរូ (ឧ. ធ្វើពិសោធន៍) | គ្រូសរសេរលើក្តារខៀន |
| គ្រូសួរសំនួរដើម្បីត្រួតពិនិត្យការយល់ដឹងរបស់កុមារ | កុមារលេងល្បែង |
| គ្រូនិងកុមារមើលសៀវភៅ | កុមារអានរឿង |
| គ្រូសួរសំនួរ | កុមារគូររូបភាព |
| កុមារធ្វើតេស្ត | កុមារច្រៀង |
| កុមារពិភាក្សាក្នុងក្រុម | សិស្សសួរសំនួរ |
| កុមារសំអាតថ្នាក់ | គ្រូប្រើប្រាស់សម្ភារបង្រៀន |
| កុមារឆ្លើយសំនួរ | កុមារសរសេរចូលសៀវភៅ |

រួចហើយអ្នកសម្របសម្រួលធ្វើចំណាត់ថ្នាក់ចំលើយ ដោយមានជំនួយពីសិក្ខាកាមទៅដាក់តាមចំណងជើងនៃគំនិតដែលបានផ្តល់ដោយសិក្ខាកាមរួចហើយអោយពួកគេ

*គូរបន្ទាត់ពីក្រោមសកម្មភាពដែលធ្វើដោយគ្រូ*

*គូរជារង្វង់ជុំវិញសកម្មភាពដែលធ្វើដោយសិស្ស*

*ដាក់ប្រអប់ជុំវិញអ្វីដែលត្រូវធ្វើដោយប្រើសម្ភារ*

*ដាក់បន្ទាត់រលកពីក្រោមអ្វីមួយដែលបង្ហាញពីការវាយតំលៃការសិក្សា*

*ដាក់សញ្ញាព្រួញពីមុខនិងពីក្រោយចំពោះសកម្មភាពដែលរៀបចំសំរាប់ពង្រឹងបន្ថែមដល់សិស្ស*

*ដាក់សញ្ញាផ្កាយពីមុខនិងពីក្រោយអ្វីដែលជាវត្ថុបំណងមេរៀន*

បន្ទាប់មកអ្នកសម្របសម្រួលធ្វើបញ្ជីចំណងជើងទាំងនេះជាប្រអប់ៗនៅក្បែរបញ្ជីរបស់សិក្ខាកាមដើម្បីទុកជាការរៀបចំសំរាប់សកម្មភាពបន្ទាប់ដោយមានដាក់ស្លាកសំគាល់ដូចជា

គោលបំណង សម្ភារ ជំហានការបង្រៀន សកម្មភាពសិស្ស ការវាយតំលៃ សកម្មភាពពង្រឹងបន្ថែម

**ថ្ងៃទី៤**

**ដំណាក់កាលបង្រៀនទី៣: ការបង្កើតប្លង់គំរូសំរាប់ការបង្រៀន ( កិច្ចតែងការបង្រៀន)** **៧៥ នាទី**

អ្នកសម្របសម្រួលនិយាយថា ចំណេងជើងទាំងនេះគឺពិតជាដូចឬស្រដៀងគ្នាទៅនឹងអ្វីដែលគ្រូនៅទូទាំងពិភពលោកប្រើប្រាស់ដើម្បីរៀបចំកិច្ចតែងការបង្រៀន។ នៅពេលពួកគេធ្វើកិច្ចតែងការបង្រៀនវាមានសភាពលក្ខណៈដូចខាងក្រោមនេះ (អ្នកសម្របសម្រួលបង្ហាញតារាងនៅលើក្តារខៀន)...

| កិច្ចតែងការបង្រៀន | | | |
|---|---|---|---|
| # | ផ្នែក | ការបរិយាយ | ខ្លឹមសារមេរៀន |
| ១ | វត្ថុបំណង | អ្វីដែលកុមារនឹងរៀន | xxxxxxxxxxx |
| ២ | សម្ភារ | អ្វីដែលគ្រូ/កុមារនឹងប្រើ | xxxxxxxxxxx |
| ៣ | ជំហាននៃការបង្រៀន | អ្វីដែលគ្រូនឹងធ្វើ-ជាជំហានតាមលំដាប់ពីដំបូងដល់បញ្ចប់ | xxxxxxxxxxx |
| ៤ | សកម្មភាពរៀន | អ្វីដែលកុមារនឹងធ្វើ | xxxxxxxxxxx |
| ៥ | ការវាយតំលៃ | អ្វីដែលគ្រូបង្រៀននឹងធ្វើដើម្បីអោយដឹងថាកុមារបានរៀន ឬមិនបានរៀន | xxxxxxxxxxx |
| ៦ | កិច្ចការពង្រឹងបន្ថែម | អ្វីដែលគ្រូរៀបចំដើម្បីពង្រឹងការរៀនរបស់សិស្សតាមរយៈការផ្តល់កិច្ចការអោយធ្វើនៅផ្ទះនិងការអនុវត្តផ្សេងៗ | xxxxxxxxxxx |

នេះគឺជាអ្វីដែលយើងហៅថាកិច្ចតែងការសំរាប់<u>គ្រូបង្រៀន</u>

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនគឺជាប្រភេទមនុស្សដែលមានការរវល់ច្រើន។ នៅក្នុងប្រទេសមួយចំនួនដែលគ្រូទទួលបានប្រាក់ខែច្រើនគេអាចចំណាយពេលបានច្រើនទៅលើការងារបង្រៀន ពោលគឺគេរៀបចំកិច្ចតែងការគ្រប់មេរៀននិងរាល់ថ្ងៃ។ នៅពេលដែលគេមានបទពិសោធន៍កាន់តែច្រើន កិច្ចតែងការរបស់គេក៏កាន់តែខ្លី។ គ្រូបង្រៀនជាច្រើនក៏ប្រើប្រាស់សម្ភារដូចជាសៀវភៅសិស្សទាំងនេះផងដែរ ដូច្នោះពួកគេពុំចាំបាច់ធ្វើកិច្ចតែងការមួយពេញលេញសំរាប់រាល់មេរៀនទាំងអស់នោះទេ។

អ្នកសម្របសម្រួលនិយាយថាៈ ចំពោះគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលនៅសាលាគរុកោសល្យ ពួកគេក៏បានរៀនយ៉ាងច្រើនអំពីវិធីសាស្រ្តនិងការរីកលូតលាស់របស់កុមារ ហើយពួកគេត្រូវសរសេរកិច្ចតែងការអោយបានល្អិតល្អន់ដោយគិតអំពីពាក្យណាមួយត្រូវប្រើដើម្បីសួរសំនួរនិងកិច្ចការណាត្រូវដាក់អោយសិស្សធ្វើ។ នេះជាការពិតណាស់នៅកម្ពុជាដែលកិច្ចតែងការជាផ្លូវការរបស់ក្រសួងមានភាពស្មុគស្មាញច្រើន។ យើងនឹងផ្តល់ឧទាហរណ៍អំពីប្រភេទកិច្ចតែង

ការនេះដើម្បីអោយលោក/លោកស្រីបានស្គាល់វា នៅពេលឃើញវា។

**កិច្ចការ:** អ្នកសម្របសម្រួល ផ្តល់នូវគំរូកិច្ចតែងការងាយៗ និងកិច្ចតែងការរបស់ក្រសួង (**ឯកសារទី១៥**)។ សិក្ខាកាម អានឯកសារនោះហើយពិភាក្សាជាមួយអ្នកនៅក្បែរអំពីភាពដូចគ្នានិងភាពខុសគ្នា។

អ្នកសម្របសម្រួលនិយាយថា: ភាពខុសគ្នាចំបងៗរវាងកិច្ចតែងការងាយរបស់យើងនិងកិច្ចតែងការផ្លូវការនោះគឺថា តាមក្រសួងគ្រូបង្រៀនត្រូវ

- គិតអំពីវត្ថុបំណង-ចំនេះដឹង បំនិន និងឥរិយាបថ
- រួមបញ្ចូលផ្នែកមួយដែលកុមារបានរៀនពីមុនហើយដែលជាប់ទាក់ទងមេរៀនថ្មី
- អនុវត្តតាម៥ជំហានដើម្បីបង្កើតជាកិច្ចតែងការ
- កិច្ចតែងការបង្រៀនបែងចែកជា៣កូឡោន-សកម្មភាពគ្រូ ខ្លឹមសារ និងសកម្មភាពសិស្ស

**អ្នកសម្របសម្រួលសួរសំនួរ: តើអ្នកអាចមើលឃើញភាពស្រដៀងគ្នារវាងកិច្ចតែងការគំរូរបស់ក្រសួងនិងកិច្ចតែងការ ទំរង់ងាយៗនេះដែរឬទេ? សូមប្រាប់ខ្ញុំនូវភាពស្រដៀងគ្នានោះ។**

*ចំលើយរំពឹងទុក: វាទាំងពីរមានវត្ថុបំណង មានការប្រើសម្ភារ មានសកម្មភាពសំរាប់គ្រូ និងកុមារ មានការវាយតំលៃ ដូចគ្នា។*

អ្នកសម្របសម្រួលនិយាយថា: ចូរកុំបារម្ភពីកិច្ចតែងការគំរូរបស់ក្រសួងសំរាប់ការធ្វើកិច្ចតែងការបង្រៀនប្រចាំថ្ងៃគឺ អ្នកអាចធ្វើតាមរបៀបងាយៗដែលបានបង្ហាញរួចហើយ ប៉ុន្តែអ្នកត្រូវធ្វើតាមរបៀបរបស់ក្រសួងនៅពេលអ្នករួមប្រជុំ បច្ចេកទេសនៅរៀងរាល់ថ្ងៃព្រហស្បតិ៍។

**ថ្ងៃទី៤**

**ដំណាក់កាលបង្រៀនទី៤: ការវិភាគមេរៀនទី១លើមុខវិជ្ជាគណិតវិទ្យា ៧៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: សូមមេត្តាមើលខ្ញុំនៅពេលដែលខ្ញុំសំដែងតួលើការបង្រៀនមេរៀននៅក្នុងគណិតវិទ្យា។ ពេលការសំដែងតួចប់ខ្ញុំចង់អោយលោក/លោកស្រីពិភាក្សាជាក្រុមអំពីអ្វីដែលបានឃើញ ហើយព្យាយាមសរសេរទៅ តាមកិច្ចតែងការបង្រៀន(**ឯកសារទី១៦**)។ ដូច្នេះក្នុងខណៈដែលខ្ញុំកំពុងសំដែងតួចូរអ្នកគិតអំពីៈវត្ថុបំណងរបស់ខ្ញុំ សម្ភារដែលខ្ញុំប្រើ ជំហានដែលខ្ញុំអនុវត្ត (អ្វីកើតឡើងដំបូងគេ ទី២ ទី៣ ជាដើម) សកម្មភាពរៀនរបស់កុមារ

និងអ្វីដែលខ្ញុំធ្វើដើម្បីវាយតំលៃការរៀនសូត្ររបស់កុមារ ។

អ្នកសម្របសម្រួលធ្វើការសំដែងតួដោយប្រើប័ណ្ណចំនួន ប័ណ្ណឈ្មោះលេខ និង តារាងប្រព័ន្ធចំនួន។

*លទ្ធផលរំពឹងទុកៈ ការសង្កេតបងាយ១ដែលអនុវត្តតាមកិច្ចតែងការដែលមើលទៅមានរាងដូចខាងក្រោម*

| កិច្ចតែងការបង្រៀន | | |
|---|---|---|
| ១ | វត្ថុបំណង | កុមារអនុវត្តរាប់ចំនួនតាមលំដាប់<br>កុមារធ្វើការរួមគ្នាជាក្រុម |
| ២ | សម្ភារ | តារាងចំនួន ប័ណ្ណចំនួន ក្តារឆ្នួន |
| ៣ | ជំហាននៃការបង្រៀន | គ្រូណែនាំមេរៀន<br>គ្រូចង្អុលទៅតារាងលេខតាមលំដាប់ក្នុងខណៈពេលកុមារអាន<br>គ្រូបង្ហាញប័ណ្ណលេខ កុមារផ្តល់ចំលើយ<br>គ្រូច្របល់លំដាប់លេខចូលគ្នានៅលើក្តារខៀន សិស្សទាំងមូលកែលំអលំដាប់នោះអោយបានត្រឹមត្រូវ<br>គ្រូបែងចែកជាក្រុមតូច១<br>គ្រូផ្តល់ប័ណ្ណលេខច្របល់ទៅតាមក្រុមនីមួយ១<br>ការពិភាក្សាជាក្រុមតូចដើម្បីរៀបលេខតាមលំដាប់<br>ក្រុមតូចបង្ហាញលទ្ធផលដល់គ្រូ |
| ៤ | សកម្មភាពរៀន | កុមារឆ្លើយសំនួរនិងចូលរួមក្នុងក្រុមទាំងមូលយ៉ាងសកម្ម<br>កុមារពិភាក្សានិងយល់ព្រមលើការដាក់ប័ណ្ណលេខច្របល់តាមលំដាប់ដែលត្រឹមត្រូវ |
| ៥ | ការវាយតំលៃ | គ្រូប្រាប់អោយកុមារដោះស្រាយបញ្ហា កុមារដោះស្រាយហើយបង្ហាញការយល់ដឹង |
| ៦ | ការពង្រីងបន្ថែម | សុំអោយកុមារនាំយកកញ្ចប់មួយចំនួនពីផ្ទះដែលមានសរសេរលេខនៅពីលើ |

ថ្ងៃទី៤

**ដំណាក់កាលបង្រៀនទី៥: ការវិភាគមេរៀនទី២ លើមុខវិជ្ជាភាសាខ្មែរ ៧៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: សូមមេត្តាមើលខ្ញុំនៅពេលដែលខ្ញុំសំដែងតួលើការបង្រៀនមេរៀននៅក្នុងភាសាខ្មែរ។

ពេលការសំដែងតួចប់ខ្ញុំចង់អោយលោក/លោកស្រីពិភាក្សាអំពីអ្វីដែលបានឃើញជាក្រុមហើយព្យាយាមសរសេរទៅតាមកិច្ចតែងការបង្រៀន (**ឯកសារទី១៧**) ។ ដូច្នេះក្នុងខណៈដែលខ្ញុំកំពុងសំដែងតួ ចូរអ្នកគិតអំពីៈវត្ថុបំណងរបស់ខ្ញុំ សម្ភារដែលខ្ញុំប្រើ ជំហានដែលខ្ញុំអនុវត្ត (អ្វីកើតឡើងដំបូងគេ ទី២ ទី៣ ជាដើម) សកម្មភាពរៀនរបស់កុមារ និងអ្វីដែលខ្ញុំធ្វើដើម្បីវាយតំលៃការរៀនរបស់កុមារ ។

អ្នកសម្របសម្រួលធ្វើការសំដែងតួដោយប្រើអត្ថបទនិងប័ណ្ណពាក្យ ។

*លទ្ធផលរំពឹងទុកៈ ការសង្ខេបងាយៗដែលអនុវត្តតាមកិច្ចតែងការដែលមើលទៅមានរាងដូចខាងក្រោម*

| **កិច្ចតែងការបង្រៀន** | | |
|---|---|---|
| ១ | វត្ថុបំណង | កុមារអនុវត្តការស្តាប់អត្ថបទ<br>កុមារអនុវត្តន៏អោយស្គាល់ពាក្យនិងជំនាញរៀបពាក្យដើម្បីបង្កើតប្រយោគចេញពីពាក្យច្របល់ |
| ២ | សម្ភារ | អត្ថបទរឿង ប័ណ្ណពាក្យសំរាប់ប្រយោគពីរ<br>**អត្ថបទគំរូ**<br>*សុក និង ចាន់ថា ដើរទៅសាលារៀនជារៀងរាល់ថ្ងៃតាម**ផ្លូវ**ដែលមានភក់ ។ ពួកគេចំណាយពេល២០នាទី ទៅកាន់សាលារៀន ។ ពិសិតរស់នៅតាមផ្លូវមួយឆ្ងាយជាងហើយវា**ជិះ**កង់រយៈពេល៣០**នាទី**មកកាន់**សាលារៀន** ។ ពិសិតខុបមិត្តរបស់វាឈ្មោះរតនៈដែលរស់នៅក្បែរផ្ទះទៅជាមួយផងដែរ ។ រតនៈធ្លាប់មានជំងឺ**ពួលខ្សួ**កាលពីនៅតូចហើយមិនអាច**ដើរ**បានល្អទេ ។ បើសិនជាពិសិតមិនបានជួយទេ**រតនៈ**ប្រហែលជាមិនអាចមករៀនបានឡើយ ។* |
| | | |

| | | |
|---|---|---|
| ៣ | ជំហាននៃការបង្រៀន | គ្រូបង្ហាញមេរៀនអំពីការស្តាប់ហើយបង្កើតជាប្រយោគពេញលេញមួយ ។<br>គ្រូអានអត្ថបទហើយសួរសំនួរអំពីអត្ថបទនោះ (ឧ តើអត្ថបទនេះនិយាយអំពីអ្វី? តើមាននរណាខ្លះនៅក្នុងអត្ថបទ? តើពិសិតធ្វើអ្វី?...)<br>គ្រូអានអត្ថបទម្តងទៀតរួមគ្នាជាមួយសិស្សទាំងអស់ ។<br>គ្រូអានអត្ថបទម្តងទៀតហើយឈប់ផ្អាកនៅកន្លែងសំខាន់ៗ (កន្លែងអក្សរដិត) ដើម្បីទុកពេលអោយកុមារអានពាក្យបន្ទាប់នោះ ។<br>គ្រូអានអត្ថបទម្តងទៀត ។<br>គ្រូរៀបចំជាក្រុមតូចៗហើយផ្តល់ប័ណ្ណពាក្យមួយឈុតដល់ក្រុមនីមួយៗ ។<br>ក្រុមតូចៗពិភាក្សាដើម្បីរៀបពាក្យនោះទៅជាប្រយោគ ។<br>ក្រុមតូចៗអានប្រយោគទៅកាន់គ្រូរបស់គេនិងសិស្សទាំងអស់ ។ |
| ៤ | សកម្មភាពរៀន | កុមារស្តាប់ហើយឆ្លើយសំនួររបស់គ្រូអំពីអត្ថបទនោះ ។<br>សិស្សប្រើបំនិនចំណាំពាក្យដើម្បីបង្កើតជាលំដាប់មួយត្រឹមត្រូវ |
| ៥ | ការវាយតំលៃ | កុមារបានស្តាប់និងប្រើប្រាស់បំនិនចំណាំពាក្យដែលបានបង្កើតលំដាប់ពាក្យបានត្រឹមត្រូវ ។ |
| ៦ | ការពង្រឹងបន្ថែម | គ្រូអោយកុមារសួរឪពុកម្តាយរបស់គេអំពីមធ្យោបាយដែលពួកគាត់ទៅសាលារៀនកាលពីនៅតូច ។ |

**ថ្ងៃទី៤**

**ដំណាក់កាលបង្រៀនទី៦: ការផលិតសម្ភារដើម្បីជំរុញការបង្រៀននិងរៀន ៤៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: គ្រូបង្រៀនប្រើប្រាស់វត្ថុផ្សេងៗ ច្រើនបែបសំរាប់ការបង្រៀន (ដែលយើងហៅថា "ធនធាន ឬសម្ភារ") ។ អ្នកសម្របសម្រួលសួរសិក្ខាកាមថា: **តើលោក/លោកស្រីអាចគិតពីឧទាហរណ៏នៃវត្ថុមួយចំនួនដែលគ្រូអាចប្រើប្រាស់បានឬទេ?** (មិនចាំបាច់កត់ត្រាចំលើយរបស់សិក្ខាកាមទេ)

***ចំលើយរំពឹងទុក:*** *សៀវភៅសិស្ស រូបភាព គំនូរ សៀវភៅ តារាង ផែនទី ដ្យាក្រាម វត្ថុតួយ៉ាងធម្មជាតិ (ឧ. កូនរុក្ខជាតិ សត្វល្អិត) គំរូ ល្បែង ។ល។*

អ្នកសម្របសម្រួលសួរសិក្ខាកាមទាំងមូលថា: **ហេតុអ្វីក៏លោក/លោកស្រីគិតថាគ្រូបង្រៀនត្រូវប្រើប្រាស់វត្ថុទាំងអស់**

**នោះ?** (សរសេរគំនិតរបស់សិក្ខាកាមដាក់ជាបញ្ជីនៅលើក្តារខៀន)

***ចំលើយរំពឹងទុក:*** *សិស្សយល់បានច្បាស់ សិស្សចូលចិត្តការសិក្សាពីព្រោះវាងាយស្រួលរៀនបើសិនជាយើងអាចមើលឃើញអ្វីមួយឬរូបភាពនៃអ្វីមួយបានច្រើនជាងតាមរយៈការពិពណ៌នា។*

អ្នកសម្របសម្រួលនិយាយថា ដូច្នោះសម្ភារមានប្រយោជន៍ណាស់ដើម្បីជួយអោយកុមាររៀនបានពូកែ នោះហើយជាមូលហេតុដែលនៅថ្ងៃទី៨នៃសិក្ខាសាលានេះយើងនឹងផ្តល់អោយលោក/លោកស្រីនូវ**សម្ភារឈុត១** និងបរិក្ខារមួយចំនួនដែលលោក/លោកស្រីអាចប្រើប្រាស់នៅក្នុងថ្នាក់រៀនជាមួយកុមារទាំងអស់។ នៅក្នុងរយៈពេលពីរឬបីថ្ងៃបន្ទាប់ទៅនេះយើងនឹងអោយលោក/លោកស្រីអនុវត្តនូវឧទាហរណ៍មួយចំនួន អំពីប្រភេទផ្សេងៗនៃល្បែងសិក្សាដែលលោក/លោកស្រីអាចយកទៅលេងនៅក្នុងថ្នាក់រៀនបាន។ ល្បែងនេះកុមាររីករាយនឹងលេងហើយដោយសារល្បែងនេះកុមារអាចអនុវត្តនូវអ្វីដែលគេទើបតែរៀននិងសំរាប់រៀនអ្វីដែលថ្មីផងដែរ។ បញ្ហាសំខាន់ដែលត្រូវដឹងគឺថា<u>សម្ភារដែលល្អមិនមែនទាល់តែមានលក្ខណៈល្អិតល្អន់ឬមានតំលៃថ្លៃនោះទេ-គ្រូបង្រៀនអាចបង្កើតទៅជាអ្វីដែលមានប្រយោជន៍ច្រើនទៀតដោយខ្លួនឯង។</u>

អ្នកសម្របសម្រួលនិយាយថា: សំរាប់សកម្មភាពចុងក្រោយនៅថ្ងៃនេះ ខ្ញុំនឹងអោយលោក/លោកស្រីនូវឧទាហរណ៍មួយចំនួនអំពីរបៀបដែលគ្រូបង្រៀនអាចប្រើសម្ភារងាយៗដើម្បីផ្តល់ឱកាសអោយកុមារដោះស្រាយបញ្ហានិងជំនាញការងារក្រុមក្នុងខណៈពេលអនុវត្តឬដោះស្រាយគណិតវិទ្យាងាយៗ។

បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញផ្ទាំងក្រដាសធំឬគូរដ្យាក្រាមនៅលើក្តារខៀនអំពីការរៀបចំគ្រាប់ឈើគូស ហើយសួរសំនួរទៅកាន់សិក្ខាកាមដែលគេត្រូវតែឆ្លើយតាមរយៈការសង្កេតឬតាមការធ្វើការបម្លាស់ទីគ្រាប់ឈើគូស។ ក្នុងពេលដែលសិក្ខាកាមដោះស្រាយបញ្ហានីមួយៗ អ្នកសម្របប្រាប់ពួកគេអំពីកិច្ចការបន្ទាប់ដែលត្រូវធ្វើ។

**ប្រស្នាបំពង់បឺត...**

សិក្ខាកាមបង្កើតទ្រង់ទ្រាយ រួចហើយដកឬរំកិលបំពង់បឺតក្នុងទ្រង់ទ្រាយនោះដើម្បីបង្កើតជាទ្រង់ទ្រាយផ្សេងៗទៀតទៅតាមការណែនាំរបស់អ្នកសម្របសម្រួល។ នៅពេលបញ្ចប់រាល់សកម្មភាពនីមួយៗត្រូវរៀបបំពង់បឺតជារៀងការេឡើងវិញ។

១. ចូររៀបចំបំពង់បឺតចំនួន១២ដើមដើម្បីបង្កើតរូបការេធំមួយ (២×២) ដោយប្រើបំពង់បឺតចំនួន៨ រួចហើយចែកការេខាងក្នុងនោះជា៤ទៀត។ តើសរុបទាំងអស់មានការេចំនួនប៉ុន្មាន? (ចំលើយគឺ: មានការេចំនួន៥)
២. ចូរដកបំពង់បឺតចេញចំនួន២ហើយទុកអោយនៅសល់ការេចំនួន៣

៣. ចូររៀបចំទ្រង់ទ្រាយអោយដូចដើមវិញ (ដូចក្នុងប្រស្នាទី១) -ឥឡូវនេះចូរដកបំពង់បឺតចេញចំនួន៤ដោយបន្សល់ទុកនូវការេចំនួន១

៤. ចូររៀបចំទ្រង់ទ្រាយអោយដូចដើមវិញ (ដូចក្នុងប្រស្នាទី១) -ឥឡូវនេះចូរដកបំពង់បឺតចេញចំនួន១ដោយបន្សល់ទុកនូវការេចំនួន៣

៥. ចូររៀបចំទ្រង់ទ្រាយអោយដូចដើមវិញ (ដូចក្នុងប្រស្នាទី១) -ឥឡូវនេះចូរដកបំពង់បឺតចេញចំនួន២ដោយបន្សល់ទុកនូវការេចំនួន២

៦. ចូរដកបំពង់បឺតចំនួន៣ចេញពីក្នុងចំនួន១២នោះ ហើយប្រើប្រាស់បំពង់បឺតដែលនៅសល់ចំនួន៩ដើម្បីបង្កើតជារូបទ្រង់ទ្រាយត្រីកោណអោយបានច្រើនតាមដែលអាចធ្វើបាន។

អ្នកសម្របសម្រួលសួរសំនួរសិក្ខាកាម ហើយអោយពួកគេធ្វើនៅផ្ទះ។ សំនួរៈ **តើប្រភេទចំណេះដឹងឬបំនិនអ្វីដែលលោក/លោកស្រីគិត ថាសិស្សនឹងរីកចំរើនដោយសារការលេងល្បែងប្រភេទនេះ?**

*ចំលើយរំពឹងទុកៈ ការចេះដោះស្រាយបញ្ហា ភាពចេះបត់បែន បំនិនក្រុម និងសង្គម បំនិនភាសា (បើសិនពិភាក្សាជាមួយអ្នកដទៃ) បំនិនគណិតវិទ្យា... ។*

បន្ទាប់មកអ្នកសម្របសម្រួលអាចសួរថាៈ (១) តើលោក/លោកស្រីគិតថាសកម្មភាពនេះសមស្របសំរាប់កំរិតថ្នាក់ទីប៉ុន្មាន? (២) តើលោក/លោកស្រីរីករាយនៅពេលលេងល្បែងនេះដែរឬទេ? តើលោក/លោកស្រីគិតថាកុមារចូលចិត្តលេងល្បែងនេះឬទេ? (៣) តើលោក/លោកស្រីគិតថាសម្ភារដែលយកមកប្រើប្រាស់មានតំលៃប៉ុន្មាន?

## ថ្ងៃទី ៥ បច្ចេកទេសបង្រៀន TGL ទី១ អំពីការសួរសំនួរ

| |
|---|
| **ថ្ងៃទី៥**<br>**ដំណាក់កាលបង្រៀនទី១: ការសំដែងតួទី១និងទី២** ៣០ នាទី<br><br>អ្នកសម្របសម្រួលនិយាយថា ឥឡូវនេះខ្ញុំនឹងធ្វើជាគ្រូបង្រៀនហើយលោក/លោកស្រីទាំងអស់គ្នាត្រូវធ្វើជាសិស្ស។ អ្នកសម្របសម្រួលពន្យល់ទៀតថាគាត់នឹងបង្រៀនមេរៀនខ្លីពីរ (មួយមេរៀនប្រហែល៥នាទី)។ សិក្ខាកាមត្រូវស្តាប់ និងសង្កេតដោយយកចិត្តទុកដាក់នូវអ្វីដែលអ្នកសម្របសម្រួលធ្វើហើយធ្វើការប្រៀបធៀប ថាតើការសំដែងតួទាំងពីរនេះមានលក្ខណៈខុសគ្នាអ្វីខ្លះ?<br><br>បន្ទាប់មកអ្នកសម្របសម្រួលចាប់ផ្តើមសំដែងដោយប្រើប្រាស់គោលវិធីខុសៗគ្នាចំនួនពីរចំពោះមេរៀនតែមួយ។ នៅក្នុងការសំដែងតួទី១គ្រូគូរតារាងអំពីសត្វ អ្វីដែលសត្វស៊ី និងសារៈប្រយោជន៍នៃសត្វចំពោះមនុស្ស រួចហើយគ្រូផ្តល់នូវខ្លឹមសារទាំងអស់ដោយពុំមានការឆ្លើយតបពីសិស្សទេ។នៅពេលដែលគ្រូសួរសំនួរគាត់ឆ្លើយតែខ្លួនឯង។ មេរៀននេះគឺធ្វើទៅតាមគោលវិធីគ្រូមជ្ឈមណ្ឌល។ នៅក្នុងការសំដែងតួទី២គ្រូផ្តល់តែគ្រោងនៃតារាងហើយរាល់ព័ត៌មានទាំងអស់ត្រូវសួរបំផុសពីសិស្សដោយការសួរសំនួរ។ មេរៀននេះគឺអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលដោយការចូលរួមរបស់កុមារមានកំរិតខ្ពស់។ |
| **ថ្ងៃទី៥**<br>**ដំណាក់កាលបង្រៀនទី២: ការពិភាក្សាក្រុមតូច** ៦០ នាទី<br><br>បន្ទាប់ពីការសំដែងតួទី១ និងទី២ អ្នកសម្របសម្រួលប្រាប់សិក្ខាកាមអោយបង្កើតជា៤ក្រុមដើម្បីពិភាក្សាសំនួរ៤ខាងក្រោម:<br>១. តើគ្រូបានធ្វើអ្វីខ្លះដើម្បីកសាងខ្លឹមសារមេរៀននៅក្នុងការសំដែងតួទី១?<br>២. តើគ្រូបានធ្វើអ្វីខ្លះដើម្បីកសាងខ្លឹមសារមេរៀននៅក្នុងការសំដែងតួទី២?<br>៣. តើលោក/លោកស្រីគិតថាវិធីបង្រៀនមួយណាមានប្រសិទ្ធភាពជាង? ហេតុអ្វី?<br>៤. តើគ្រូបានធ្វើការវាយតំលៃនៅពេលណា? ហើយធ្វើដូចម្តេច?<br>បន្ទាប់ពីការពិភាក្សា ក្រុមនីមួយៗនៃសិក្ខាកាមរាយការណ៍ទៅកាន់ក្រុមផ្សេងៗ។ អ្នកសម្របសម្រួលពន្យល់/ផ្តល់គំនិតបន្ថែមបើចាំបាច់។ |

ថ្ងៃទី៥

**ដំណាក់កាលបង្រៀនទី៣: ល្បែងសិក្សា-សកម្មភាពសត្វ** **១៥ នាទី**

ក្រុមនីមួយៗបញ្ជូនអ្នកតំណាង២នាក់ទៅខាងមុខដើម្បីទទួលរូបភាពសត្វឬប័ណ្ណឈ្មោះ។ ពួកគេមិនត្រូវបង្ហាញរូបនោះទៅកាន់ក្រុមរបស់គេទេ។ រួចហើយអ្នកតំណាងម្នាក់ក្នុងចំណោមនោះត្រូវសំដែងអោយដូចសត្វក្នុងរូបភាព រហូតដល់ក្រុមរបស់គេទាយត្រូវ។ក្រុមណាទាយត្រូវច្រើនជាងគេក្នុងម៉ោងកំណត់ដូចគ្នាគឺជាអ្នកឈ្នះ។

អ្នកសម្របសម្រួលសួរសិក្ខាកាមៈ **តើល្បែងនេះផ្តល់ចំណេះដឹងអ្វី?**
***ចំលើយរំពឹងទុកៈ*** *ការអាន ការសំដែង/វិនាដកម្ម*

អ្នកសម្របសម្រួលក៏អោយឯកសារ "កំណត់ហេតុល្បែង" (**ឯកសារទី១៨**)។ សិក្ខាកាមសរសេរការបរិយាយខ្លីៗអំពីល្បែងនីមួយៗដែលគេជួបប្រទះនៅក្នុងវគ្គបណ្តុះបណ្តាលនេះហើយត្រូវរក្សាទុកជាឯកសារ។

ថ្ងៃទី៥

**ដំណាក់កាលបង្រៀនទី៤: ការសំដែងតួទី៣** **៣០ នាទី**

អ្នកសម្របសម្រួលនិយាយថា គាត់នឹងសំដែងតួជាគ្រូបង្រៀនម្តងទៀត ចំណែកឯសិក្ខាកាមត្រូវសំដែងតួជាសិស្ស។

បន្ទាប់មកគ្រូចាប់ផ្តើមសំដែងតួទី៣ដែលមានការសួរសំនួរជាបន្តបន្ទាប់ទៅកាន់សិក្ខាកាមអំពីសត្វ (សំនួរនេះត្រូវបានរៀបចំជាមុន)។ ដើម្បីឆ្លើយសំនួរនេះ "កុមារ " អាចចងចាំព័ត៌មានអំពីការសំដែងតួទី១និងទី២ហើយព្រមទាំងចងចាំអ្វីដែលពួកគេបានដឹងតាមរយៈបទពិសោធន៍ផ្ទាល់ផងដែរ។ ពួកគេត្រូវឆ្លើយដោយប្រើគំនិតយោបល់របស់គេផ្ទាល់។

ថ្ងៃទី៥

**ដំណាក់កាលបង្រៀនទី៥: ការពិភាក្សាក្រុមតូច** **៦០ នាទី**

បន្ទាប់ពីការសំដែងតួ អ្នកសម្របសម្រួលយកផ្ទាំងក្រដាសធំដែលមានសំនួរនៃការសំដែងតួទី៣ទាំងអស់មកបិទលើក្តារខៀនឬលើជញ្ជាំង។

អ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមតូចៗដើម្បីអាននិងពិភាក្សាសំនួរម្តងមួយម្តងមួយ។ សិក្ខាកាមត្រូវធ្វើការសម្រេចចិត្តថាតើសំនួរនីមួយៗជាសំនួរប្រភេទអ្វី-តើវាជា:

- សំនួរចងចាំ (ដែលបានពីមេរៀនដំបូងក្នុងការសំដែងតួទី១ និងទី២) ឬ?
- សំនួរចងចាំដែលកុមារត្រូវប្រើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេឬ?
- ឬជាសំនួររិះគិតដែលកុមារត្រូវឆ្លើយដោយប្រើប្រាស់យោបល់និងហេតុផលផ្ទាល់ខ្លួនឬ?

នៅពេលក្រុមតូចៗបានបញ្ចប់ការធ្វើចំណាត់ថ្នាក់នៅលើក្រដាសផ្ទាំងធំ រួចហើយពួកគេក៏បិទទៅលើជញ្ជាំង។ អ្នកសម្របសម្រួលអោយក្រុមស្វែងរកមើលភាពខុសគ្នា។ បើសិនជាមានចំលើយតបខុសគ្នា ក្រុមនោះអាចពន្យល់មូលហេតុដែលគេធ្វើដូចនោះ។ ហើយបើសិនជាក្រុមទាំងអស់បានធ្វើចំនាត់ថ្នាក់សំនួរដែលមិនត្រឹមត្រូវដូចគ្នា នោះអ្នកសម្របសម្រួលអាចសួរសំនួរ។ សិក្ខាកាមអាចធ្វើការកត់ត្រាវិភាគនៅលើ **ឯកសារទី១៩**។

អ្នកសម្របសម្រួលសន្និដ្ឋានបញ្ចប់ដោយសួរសិក្ខាកាមថា: តើលោក/លោកស្រីអាចប្រាប់ខ្ញុំបានទេ ថាតើមានប្រភេទពាក្យសំនួរអ្វីខ្លះដែលគេប្រើច្រើនបំផុតនៅក្នុងសំនួរបែបរិះគិត?
ចំលើយរំពឹងទុក: សំនួររិះគិតភាគច្រើនហាក់ដូចជាចាប់ផ្តើមដោយពាក្យមួយចំនួនដូចខាងក្រោម

| ពាក្យខ្មែរ | ពាក្យអង់គ្លេស |
|---|---|
| ហេតុអ្វី | Why |
| ប្រសិនបើ | What if… |
| យ៉ាងណា | How |
| ដូចម្តេច | How |
| ដើម្បីអ្វី | Why |

**ថ្ងៃទី៥**

**ដំណាក់កាលបង្រៀនទី៦: ល្បែងសិក្សា: បកដំឡូងក្តៅ** **២០ នាទី**

ជាល្បែងអំនានដែលគេយកក្រដាសរុំវត្ថុមួយជាច្រើនជាន់ ហើយវត្ថុនោះមានសរសេរសេចក្តីណែនាំនៅក្នុងនោះផង។ គ្រូឬសិស្សម្នាក់ឈរនៅខាងមុខ (ដោយបែរខ្នងដាក់សិក្ខាកាម) ហើយក្នុងអំឡុងពេលណាមួយត្រូវគោះក្តារខៀនឬផ្ទឹ

កញ្ចែ ក្នុងខណៈពេលដែលកញ្ចប់នោះកំពុងត្រូវបានគេបោះពីម្នាក់ទៅម្នាក់ទៀត។ សិក្ខាកាមណាដែលកំពុងតែកាន់កញ្ចប់នោះក្នុងពេលដែលគេផ្លុំកញ្ចែឬគោះក្តារខៀន អ្នកនោះត្រូវស្រាយកញ្ចប់ហើយអានដើម្បីអនុវត្តទៅតាមសេចក្តីណែនាំនោះ (ឧទាហរណ៍ រាំ សំដែងជាសត្វកង្កែបលោតឬជាការឆ្លើយសំនួរ។ល។

នៅពេលល្បែងនេះចប់អ្នកសម្របសម្រួលសួរថា: **តើនៅក្នុងល្បែងនេះផ្តល់នូវចំណេះដឹងអ្វី?**
***ចំលើយរំពឹងទុក:*** *ការអាន ការចាប់កាន់ឬហុចអ្វីមួយ ការសំដែងតួ...*

**ថ្ងៃទី៥**

**ដំណាក់កាលបង្រៀនទី៧: កិច្ចការអនុវត្តសំនេរលើប្រភេទសំនួរផ្សេងៗ ៦០ នាទី**

អ្នកសម្របសម្រួលពន្យល់ថា: សិក្ខាកាមនឹងធ្វើការជាក្រុមតូចៗដើម្បីសរសេរប្រភេទសំនួរផ្សេងៗ។ សំនួរទាំងឡាយត្រូវផ្អែកទៅលើមេរៀនដែលគេបានបង្ហាញនៅក្នុងសៀវភៅសិស្សតាមកំរិតថ្នាក់ដែលពួកគេនឹងបង្រៀន (បើសិនជាពួកគេបានដឹងពីកំរិតថ្នាក់ ហើយមានសិក្ខាកាមគ្រប់គ្រាន់ដើម្បីបង្កើតជាក្រុម)

អ្នកសម្របសម្រួលនិយាយថាសិក្ខាកាមត្រូវ

(១) សរសេរសំនួរចងចាំ៥និងសំនួររិះគិត៥ នៅក្នុងមេរៀនទី៣នៃសៀវភៅគណិតវិទ្យាសិស្សថ្នាក់ទី៣អំពីប្រភាគ (ទំព័រ១៨-២១) និង

(២) សរសេរសំនួរចងចាំ៥និងសំនួររិះគិត៥ នៅក្នុងមេរៀនទី៦នៃសៀវភៅសិក្សាសង្គមសិស្សថ្នាក់ទី៣អំពីភូមិនិងប្រធានភូមិ (ទំព័រ១២)។

សិក្ខាកាមបង្កើតជាក្រុមដែលមានគ្នា៥នាក់ដើម្បីសរសេរសំនួរដាក់លើក្រដាសផ្ទាំងធំ។ ក្រុមទាំងឡាយឡើងរាយការណ៍ទៅកាន់ក្រុមទាំងមូលនូវសំនួររបស់គេ។ សិក្ខាកាមផ្សេងទៀតអាចយល់ស្របឬបដិសេធពីរបៀបដែលពួកគេសរសេរសំនួរ។ សិក្ខាកាមអាចធ្វើការកត់ត្រាវិភាគនៅលើ **ឯកសារទី២០**។

**ថ្ងៃទី៥**

**ដំណាក់កាលបង្រៀនទី៨: សេចក្តីសន្និដ្ឋាន ១៥ នាទី**

អ្នកសម្របសម្រួលអោយសិក្ខាកាមសរុបគំនិតសំខាន់ៗនៅថ្ងៃទី៥នេះ។ អ្នកសម្របសម្រួលធ្វើកំណត់សំគាល់នៅលើក្តារខៀនក្នុងខណៈដែលសិក្ខាកាមនិយាយ ហើយអាចសួរសំនួរដើម្បីរំលឹកពួកគេនូវអ្វីដែលភ្លេច។

## ថ្ងៃទី៦  បច្ចេកទេសបង្រៀនTGLទី២  អំពីការគ្រប់គ្រងថ្នាក់រៀន

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី១: ការសំដែងតួលើកទី១** **៤៥ នាទី**

ការស្វែងរកទ្រង់ទ្រាយធរណីមាត្រដោយធ្វើការជាលក្ខណៈបុគ្គល ដៃគូ បីនាក់ ក្រុមតូចនិងក្រុមទាំងមូល។

អ្នកសម្របសម្រួលពន្យល់ថា គាត់នឹងសំដែងតួជាគ្រូហើយសិក្ខាកាមទាំងអស់ត្រូវសំដែងជាសិស្ស។ អ្នកសម្របសម្រួលចាប់ផ្តើមសំដែងតួដោយធ្វើការរំលឹកសិស្ស (សិក្ខាកាម) អំពីរូបធរណីមាត្រដែលគេបានរៀនរួចហើយ។ គាត់សួរសំនួរហើយអោយសិក្ខាកាមឡើងគូររូបការេ ចតុកោណកែង ត្រីកោណកែង និងរង្វង់នៅលើក្តារខៀន។ បន្ទាប់មកអ្នកសម្របសម្រួលប្រាប់សិក្ខាកាមអោយអានឈ្មោះទ្រង់ទ្រាយម្នាក់មួយៗដើម្បីបង្កើតក្រុមដែលមានសមាជិក៦នាក់។

អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមហើយពន្យល់ពីប្រព័ន្ធក្នុងការធ្វើការជាដៃគូ ជាបីនាក់ ជាក្រុមតូច (ដោយដាក់ឈ្មោះសិក្ខាកាមដូចជា ក១ ក២ ក៣ ខ១ ខ២ ខ៣ ។ល។) និងត្រួតពិនិត្យដើម្បីធានាថាពួកគាត់បានស្គាល់ដៃគូរ និងក្រុមរងបានច្បាស់។ បន្ទាប់មកអ្នកសម្របសម្រួលចែករូបភាពវត្ថុ២ (ដែលមានរូបធរណីមាត្រ) ទៅអោយមនុស្សម្នាក់ៗក្នុងក្រុមដើម្បីត្រួតពិនិត្យមើល។ នៅក្នុងគំនូរ២នោះមានរូបខុសៗគ្នាចំនួន៣ប្រភេទ។ ជាដំបូងសិក្ខាកាមពិនិត្យរូបភាពជាលក្ខណៈបុគ្គលហើយព្យាយាមរាប់ចំនួនប្រភេទទ្រង់ទ្រាយនីមួយៗ។ បន្ទាប់មកគេបង្កើតជាដៃគូដើម្បីបង្ហាញគ្នាទៅវិញទៅមកអំពីរូបភាពនិងចំនួនដែលគេបានរកឃើញរួចហើយពិភាក្សា។ បន្ទាប់មកទៀតគេប្រាប់ពីលទ្ធផលទៅដល់ក្រុមទាំងមូលនិងព្យាយាមព្រមព្រៀងគ្នាអំពីចំនួនទ្រង់ទ្រាយដែលពួកគេបានរកឃើញ។ បន្ទាប់មកសមាជិកម្នាក់ៗក្នុងក្រុមឡើងរាយការណ៍ទៅកាន់ក្រុមទាំងអស់ដោយការបំពេញទៅតាមផ្នែកនៅក្នុងតារាង។

| ឈ្មោះក្រុម | ក្រុមការេ | ក្រុមត្រីកោណ | ក្រុមចតុកោណ | ក្រុមរង្វង់ |
|---|---|---|---|---|
| ការេ | | | | |
| រង្វង់ | | | | |
| ចតុកោណកែង | | | | |
| ត្រីកោណ | | | | |

ក្រុមណាដែលបានរកឃើញរូបធរណីមាត្រច្រើនជាងគេ ដោយបានបង្ហាញទីតាំងច្បាស់លាស់ផងនោះគឺជាអ្នកឈ្នះ។

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី២៖ ការពិភាក្សាក្រុមតូចៗអំពីការសំដែងតួទី១** **៤៥ នាទី**

បន្ទាប់ពីការសំដែងតួទី១ អ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមតូចដើម្បីពិភាក្សាសំនួរ៥ ហើយសរសេរចំលើយចូលតារាងខាងក្រោម ។

១. តើលោក/លោកស្រីគិតថាខ្លឹមសារមេរៀននេះបានមកពីមុខវិជ្ជាអ្វី?
២. តើនៅក្នុងមេរៀននេះសិស្សបានធ្វើការតាមប្រភេទក្រុមអ្វីខ្លះ?
៣. តើមានសកម្មភាពចំបងៗអ្វីខ្លះដែលសិស្សបានធ្វើនៅក្នុងក្រុមផ្សេងៗគ្នានេះ?
៤. តើកុមារបានទទួលអត្ថប្រយោជន៍អ្វីខ្លះនៅពេលគេធ្វើការតាមរបៀបខុសៗគ្នានេះ?
៥. តើលោក/លោកស្រីគិតថាសកម្មភាពគ្រប់គ្រងថ្នាក់ទាំងនេះអាចប្រើប្រាស់ក្នុងមុខវិជ្ជាផ្សេងៗបានឬទេ?

តារាង

| សំនួរ | *ចំលើយរំពឹងទុក* |
|---|---|
| ១ | *គណិតវិទ្យា* |
| ២ | *ជាបុគ្គល ដៃគូរ (២នាក់) ក្រុមតូច (៦នាក់) ថ្នាក់ទាំងមូល* |
| ៣ | *ការសង្កេត ការធ្វើអត្តសញ្ញាណទ្រង់ទ្រាយ ការរាប់ ការនិយាយ (ពិពណ៌នា ពន្យល់ បង្ហាញ)* |
| ៤ | *ធ្វើអោយការសិក្សាមានភាពសប្បាយ លើកទឹកចិត្ត និងមានការប្រកួតប្រជែង រៀនពីគ្នាទៅវិញទៅមក ការអនុវត្តការស្តាប់ និងនិយាយ ឆ្លុះបង្ហាញគំនិតផ្ទាល់ខ្លួន បានអនុវត្តន៍តាមភាពសហការ និងការចេះធ្វើការជាក្រុម... ។* |
| ៥ | *បាទ/ចាស៎* |

បន្ទាប់មកតំណាងក្រុមនីមួយៗឡើងរាយការណ៍ ។ អ្នកសម្របសម្រួលជួយបំពេញបន្ថែម បើមានចំនុចខ្វះខាត ។

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី៣៖ ល្បែងសិក្សា៖ លេខក្នុងចិត្ត** **១៥ នាទី**

អ្នកសម្របសម្រួលនិយាយថា៖ ខ្ញុំមានចំនួនមួយ កាលណាខ្ញុំគុណនឹង៥ ខ្ញុំបូកនឹង២៥ ចែកនឹង៥ ដកនឹង៥ ខ្ញុំឃើញ៥ ។

តើចំនួននោះជាចំនួនប៉ុន្មាន? *(ចំលើយរំពឹងទុក: ៥)*

អ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាបុគ្គលរួចហើយផ្ទៀងផ្ទាត់ក្នុងក្រុម និងឡើងរាយការណ៍ទៅតាមក្រុមនីមួយៗ។ បន្ទាប់មកអ្នកសម្របសម្រួលផ្តល់គំនិតបន្ថែម។

**ថ្ងៃទី៦**

**ដំណាក់កាលបង្រៀនទី៤: ការសំដែងតួទី២ ៣០ នាទី**

ការសរសេរតាមអានរៀបចំ

អ្នកសម្របសម្រួលពន្យល់ថាឥឡូវនេះ គាត់នឹងសំដែងតួជាគ្រូបង្រៀនម្តងទៀតហើយសិក្ខាកាមទាំងអស់សំដែងតួជាសិស្ស។ បន្ទាប់មកគ្រូបង្រៀនចាប់ផ្តើមសំដែងតួទី២ដោយធ្វើការបែងចែកសិក្ខាកាមជាក្រុមដែលមានគ្នា៦នាក់។ អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាមតាមក្រុមឈរជាជួរពីលេខ១-៥ដោយទុកអោយលេខ៦អង្គុយចាំកន្លែង។

អ្នកលេខ១ទៅយកព័តិមានពីតុគ្រូមកប្រាប់អ្នកលេខ៦ដើម្បីកត់ត្រា។ នៅពេលអ្នកលេខ៦សរសេរចប់គាត់ត្រូវមកឈរខាងក្រោយលេខ៥ក្នុងជួរហើយអ្នកលេខ១ចូលអង្គុយម្តង។ បន្ទាប់មកអ្នកលេខ២ទៅយកព័តិមានពីតុគ្រូមកប្រាប់អ្នកលេខ១ (ព័តិមានជាប្រយោគឬជាឃ្លាដែលមាននៅតុគ្រូត្រូវបង់លេខពី១-៦ដើម្បីកុំអោយច្រឡំ)។ សមាជិកក្រុមបន្តធ្វើររបៀបនេះរហូតគ្រប់គ្នា។

គ្រប់ក្រុមទាំងអស់អនុវត្តក្នុងពេលជាមួយគ្នារហូតដល់យកព័តិមានអស់ពីតុគ្រូមកសរសេរតាមក្រុម។ បន្ទាប់មកអ្នកសម្របសម្រួលប្រាប់អោយសមាជិកក្រុមនីមួយៗត្រួតពិនិត្យនិងកែលំអអត្ថបទរបស់ពួកគេ។ រួចហើយក្រុមនីមួយៗផ្តល់អត្ថបទរបស់ពួកគេទៅអោយក្រុមផ្សេងៗទៀតដើម្បីជួយកែលំអបន្ថែម។ ក្រុមឈ្នះគឺជាក្រុមដែលសរសេរពុំមានកំហុសឬមានកំហុសតិចជាងគេ។

**ថ្ងៃទី៦**

**ដំណាក់កាលបង្រៀនទី៥: ការពិភាក្សាក្រុមតូចៗលើការសំដែងតួទី២ ៤៥ នាទី**

បន្ទាប់ពីបូកសរុបរបាយការណ៍ក្រុម អ្នកសម្របសម្រួលអោយក្រុមនីមួយៗពិភាក្សាលើការសំដែងតួទី២ដោយឆ្លើយសំនួរទាំង៥ (សំនួរដូចការសំដែងតួទី១)។

តើអ្នកគិតថាខ្លឹមសារមេរៀននេះបានមកពីមុខវិជ្ជាអ្វី?

តើនៅក្នុងមេរៀននេះសិស្សបានធ្វើការតាមប្រភេទក្រុមអ្វីខ្លះ?

តើមានសកម្មភាពចំបងៗអ្វីខ្លះដែលសិស្សបានធ្វើនៅក្នុងក្រុមផ្សេងៗគ្នានេះ?

តើកុមារបានទទួលអត្ថប្រយោជន៍អ្វីខ្លះនៅពេលគេធ្វើការតាមរបៀបខុសៗគ្នានេះ?

តើអ្នកគិតថាសកម្មភាពគ្រប់គ្រងថ្នាក់ទាំងនេះអាចប្រើប្រាស់ក្នុងមុខវិជ្ជាផ្សេងៗបានឬទេ?

តារាង

| សំនួរ | *ចំលើយរំពឹងទុក* |
|---|---|
| ១ | *ភាសា* |
| ២ | *ជាបុគ្គល ដៃគូ (២នាក់) ក្រុមតូច* |
| ៣ | *ការអាន ការនិយាយ ការស្តាប់ ការសរសេរ (បំនិនទាំង៤)* |
| ៤ | *ការសិក្សាមានការចាប់អារម្មណ៏ ការប្រកួតប្រជែងប្រកបដោយការលើកទឹកចិត្ត រៀនពីគ្នាទៅវិញទៅមក អនុវត្តបំនិនទាំង៤ បង្កើតការសហការ និងការងារក្រុម...* |
| ៥ | *បាទ/ចាស់* |

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី៦: ល្បែងសិក្សាៈ ដូមីណូ** **៣០ នាទី**

អ្នកសម្របសម្រួលចែកបាច់ដូមីណូទៅអោយក្រុមនីមួយៗដើម្បីលេង (**ឯកសារទី២១**) ហើយណែនាំពីរបៀបលេងដោយប្រើសកម្មភាពជាក់ស្តែង ។ ម្យ៉ាងទៀតអ្នកសម្របសម្រួលគួរតែបញ្ជាក់ពីផលប្រយោជន៍នៃល្បែងនេះថាបានជួយពង្រឹងដល់ភាពរហ័សក្នុងការគិតលើប្រមាណវិធីទាំង៤ដល់សិស្ស ។

ល្បែងដូមីណូនេះគេអាចយកទៅថតចំលង ហើយកាត់ជាសន្លឹកៗសំរាប់អោយសិក្ខាកាមប្រើប្រាស់ ។ សន្លឹកដូមីណូមានសរសេរចំនួនឬផលបូក (ឧទាហរណ៏ ២+៤)នៅចុងសន្លឹកម្ខាងៗ ប័ណ្ណដូមីណូខ្លះមានលទ្ធផលស្រាប់នៅចំកណ្តាលសន្លឹក ។សិស្ស (សិក្ខាកាម) ត្រូវស្វែងរកសន្លឹកដូមីណូរបស់អ្នកផ្សេងដែលមានចំនួន ផលបូក ផលចែក ផលដក ។ល ។ ដែលមានលទ្ធផលត្រូវគ្នា ។

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី៧: ការសំដែងតួទី៣** **៤៥ នាទី**

អនាម័យមូលដ្ឋាន (ដកស្រង់ពីសៀវភៅសិក្សាសង្គមរបស់សិស្ស ថ្នាក់ទី២ ទំព័រ ២៣)

អ្នកសម្របសម្រួលនិយាយថា គាត់នឹងដើរតួជាគ្រូបង្រៀនម្តងទៀតហើយសិក្ខាកាមដើរតួជាសិស្ស។ អ្នកសម្របសម្រួលចាប់ផ្តើមសំដែងតួទី៣ ដោយធ្វើការរំលឹកមេរៀនពីមុន១ដែលទាក់ទងនឹងអនាម័យ។ បន្ទាប់មកអោយសិក្ខាកាមរៀបរាប់ឧបករណ៍ប្រើប្រាស់សំរាប់អនាម័យដូចជា ច្រាសដុសធ្មេញ ថ្នាំដុសធ្មេញ កន្សែងពោះគោ ធុងទឹក សាប៊ូ... ។ បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមអានពាក្យទាំងនោះដើម្បីចែកក្រុម។

អ្នកសម្របសម្រួលពន្យល់ពីផលប្រយោជន៍អនាម័យខ្លួនប្រាណ ដោយប្រៀបធៀបជាមួយអ្នកដែលគ្មានអនាម័យ។ ក្រោយពីពន្យល់ណែនាំ អ្នកសម្របសម្រួលចែករូបអនាម័យ មួយក្រុមមួយឈុត (៤សន្លឹក) ដើម្បីអោយគេសរសេរជាអត្ថបទរឿងមួយងាយ១ទៅតាមលំដាប់លំដោយរូបភាពនោះ។ អ្នកសម្របសម្រួលត្រួតពិនិត្យក្រុម។ បន្ទាប់មកអោយសិក្ខាកាម២នាក់មកពីក្រុមនីមួយ១ឡើងរាយការណ៍ដោយម្នាក់អានអត្ថបទរឿងនិងម្នាក់ទៀតបង្ហាញរូបភាព។ ក្នុងពេលដែលក្រុមនីមួយ១ឡើងរាយការណ៍អ្នកសម្របសម្រួលប្រាប់អោយក្រុមផ្សេង១គិតពិចារណា ថាតើក្រុមមួយណាល្អជាងគេ។ នៅពេលដែលស្វែងរកក្រុមល្អជាងគេហើយពួកគេត្រូវសំដែងតាមរូបភាពនោះដូចជា ដុសធ្មេញ សិតសក់ ស្លៀកពាក់ជាដើម។

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី៨: ការពិភាក្សាក្រុមតូច១លើការសំដែងតួទី៣** **៤៥ នាទី**

បន្ទាប់ពីការរាយការណ៍សង្ខេបពីក្រុមទាំងឡាយ អ្នកសម្របសម្រួលប្រាប់អោយក្រុមនីមួយ១ពិភាក្សាលើការសំដែងតួទី៣ហើយឆ្លើយសំនួរទាំង៥ (សំនួរដូចការសំដែងតួទី១) ដោយប្រើតារាង។

- តើអ្នកគិតថាខ្លឹមសារមេរៀននេះបានមកពីមុខវិជ្ជាអ្វី?
- តើនៅក្នុងមេរៀននេះសិស្សបានធ្វើការតាមប្រភេទក្រុមអ្វីខ្លះ?
- តើមានសកម្មភាពចំបង១អ្វីខ្លះដែលសិស្សបានធ្វើនៅក្នុងក្រុមផ្សេង១គ្នានេះ?
- តើកុមារបានទទួលអត្ថប្រយោជន៍អ្វីខ្លះនៅពេលគេធ្វើការតាមរបៀបខុស១គ្នានេះ?
- តើអ្នកគិតថាសកម្មភាពគ្រប់គ្រងថ្នាក់ទាំងនេះអាចប្រើប្រាស់ក្នុងមុខវិជ្ជាផ្សេង១បានឬទេ?

តារាង

| សំនួរ | *ចំលើយរំពឹងទុក* |
|---|---|
| ១ | *សិក្សាសង្គម* |
| ២ | *ជាបុគ្គល ដៃគូ (២នាក់សំរាប់ការឡើងបង្ហាញ) ក្រុមតូច* |
| ៣ | *បំនិនភាសាទាំង៤ ការបង្ហាញ ការសំដែងតួ* |
| ៤ | *ធ្វើអោយការសិក្សាមានការចាប់អារម្មណ៍ មានការលើកទឹកចិត្តដោយសារកាប្រើប្រាស់រូបភាពទាំង៤ ការរៀនពីគ្នាទៅវិញទៅមក អនុវត្តបំនិនទាំង៤ បង្កើនការសហការ និងការងារក្រុម...* |
| ៥ | *បាទ/ចាស់* |

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី៩: ល្បែងសិក្សា-ការធ្វើគំរូសត្វដោយប្រើទ្រង់ទ្រាយធរណីមាត្រ ១៥ នាទី**

អ្នកសម្របសម្រួលរៀបចំសម្ភារដូចជា កន្ត្រៃ និងសន្លឹកក្រដាសដែលមានគូរប្រអប់ក្រឡា និងមានបន្ទាត់ជិតជាសញ្ញាបង្ហាញរូបធរណីមាត្រ (**ឯកសារទី២២**) ។ អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាមកាត់រូបភាពនោះទៅតាមបន្ទាត់ជិតដើម្បីបង្កើតជារូបធរណីមាត្រអោយបាន៧ រួចហើយផ្គុំរូបទាំងនោះធ្វើជារូបអ្វីមួយ (ឧទាហរណ៍ រូបភាពសត្វ) ទៅតាមសេចក្តីណែនាំរបស់អ្នកសម្របសម្រួល ។ បន្ទាប់មកអោយក្រុមនីមួយៗយករូបភាពនោះទៅបិទនៅលើក្តារខៀន ។

អ្នកសម្របសម្រួលជួយកែតម្រូវបើចាំបាច់ ។ ការងារនេះអាចបន្តទៅរកការបង្កើតរូបភាពផ្សេងៗទៀតបើសិនមានពេលគ្រប់គ្រាន់ ។

ថ្ងៃទី៦

**ដំណាក់កាលបង្រៀនទី១០: ការអានឯកសារ " សិស្សធ្វើការជាក្រុមនិងជាដៃគូ" ៣០ នាទី**

អ្នកសម្របសម្រួលផ្តល់ឯកសារជាអត្ថបទពីឯកសារTGL (ទំព័រ ១៨-១៩) សំរាប់គ្រូបង្រៀនដើម្បីអានស្វែងយល់បន្ថែមទៀតលើបច្ចេកទេសទី២ (**ឯកសារទី២៣**) ។

នៅពេលបញ្ចប់ការអាននិងការពិភាក្សា អ្នកសម្របសម្រួលសួរសំនួរមួយចំនួនដើម្បីវាយតំលៃកំរិតយល់ដឹង ។

**ថ្ងៃទី៦**

**ដំណាក់កាលបង្រៀនទី១១: ការសង្ខេបគំនិតសំខាន់ៗនៃបច្ចេកទេសបង្រៀន TGL ទី២ ៤៥ នាទី**

អ្នកសម្របសម្រួលសួររំលឹកឡើងវិញយ៉ាងរហ័សអំពីការសំដែងតួទាំង៣។ បន្ទាប់មកអោយសិក្ខាកាមធ្វើការជាក្រុមដើម្បីពិភាក្សាសំនួរៈ **តើអត្ថប្រយោជន៍ចំបងៗអ្វីខ្លះដែលលោក/លោកស្រីទទួលបានពីការធ្វើការជាក្រុមតូចនិងក្រុមថ្នាក់ទាំងមូល?** សិក្ខាកាមពិភាក្សាគំនិតរបស់គេហើយកត់ត្រាចំលើយនៅក្រោមកូឡោន/ចំណងជើងពីរ (មើលតារាងខាងក្រោម)។

បន្ទាប់មកសិក្ខាកាមរាយការណ៍ត្រឡប់ ហើយអ្នកសម្របសម្រួលប្រមូលគំនិតទាំងនោះដាក់ទៅលើតារាងធំមួយ។ នៅពេលក្រុមទាំងអស់បង្ហាញចប់ អ្នកសម្របសម្រួលបន្ថែមគំនិតផ្សេងៗបើចាំបាច់។

| អត្ថប្រយោជន៍នៃការងារក្រុមតូច | អត្ថប្រយោជន៍នៃការងារថ្នាក់ទាំងមូល |
|---|---|
| *ចំលើយរំពឹងទុក*<br>• *គ្រប់គ្នាមានភាពសកម្ម និងចេះពិភាក្សា*<br>• *គ្រប់គ្នាមានឱកាសអនុវត្ត*<br>• *កុមាររៀនធ្វើការរួមគ្នា*<br>• *កុមាររៀនពីកុមារផ្សេងទៀត*<br>• *កុមារមានទំនុកចិត្តច្រើន និងអាចធ្វើការដោយភាពឯករាជ្យ (ដោយមិនចាំបាច់មានគ្រូបង្រៀន)*<br>• *កុមារអនុវត្តបំនិនស្តាប់និងនិយាយ*<br>• *មានភាពរីករាយនិងប្រកបដោយការលើកទឹកចិត្តច្រើន*<br>• *គ្រូអាចដើរត្រួតពិនិត្យដោយផ្ទាល់លើក្រុមផ្សេងៗ* | *ចំលើយរំពឹងទុក*<br>• *មានភាពរហ័សនិងសន្សំពេលវេលា*<br>• *អាចទទួលបានគំនិតច្រើនយ៉ាងរហ័ស*<br>• *ងាយស្រួលចំពោះគ្រូបង្រៀន*<br>• *ធ្វើអោយកុមារក្លាហានក្នុងការនិយាយ* |

អ្នកសម្របសម្រួលសរុបបញ្ចប់ដោយនិយាយពីតំលៃនៃកិច្ចសហការ និងក្រុមការងារ រួចហើយសួរសិក្ខាកាមអំពីការរំពឹងទុករបស់គេទៅលើបច្ចេកទេសដើម្បីយកទៅអនុវត្តក្នុងស្ថានភាពជាក់ស្តែងនៅក្នុងសាលារៀន។

## ថ្ងៃទី៧ បច្ចេកទេសបង្រៀនTGL ទី៣ និងទី៤

៣. ការប្រើប្រាស់សម្ភារបរិស្ថានជាធនធានសំរាប់ការបង្រៀន

៤. ការប្រើប្រាស់ភាសារបស់កុមារដើម្បីកែលំអបំនិនសរសេររបស់ពួកគេ

ថ្ងៃទី៧

**ដំណាក់កាលបង្រៀនទី១: ការសំដែងតួទី១** ៤៥ នាទី

ការវិភាគសម្ភារបរិស្ថាន

មុនពេលបង្រៀនអ្នកសម្របសម្រួលរៀបចំសម្ភារបរិស្ថានជាមូលដ្ឋានមួយចំនួនៈ ដុំថ្មតូចៗ កំណាត់ឈើដែលមានប្រវែងខុសៗគ្នា ស្លឹកឈើដែលមានទំហំនិងប្រភេទខុសៗគ្នា កំប៉ុងភេសជ្ជៈ កញ្ចប់បារី ប្រអប់ឈើគូសទទេ កៅស៊ូកង១០។ល។ សម្ភារទាំងនេះត្រូវបានគេដាក់ទៅក្នុងថង់ប្លាស្ទិចចំនួន៤ដែលថង់ទាំងនោះមានសម្ភារគ្រប់ប្រភេទខាងលើដូចគ្នា។

អ្នកសម្របសម្រួលនិយាយថាមានវត្ថុជាច្រើននៅក្នុងបរិស្ថាន ដែលគ្រូបង្រៀនអាចយកទៅប្រើប្រាស់ជាធនធានសំរាប់ការបង្រៀននិងរៀន។ ឧទាហរណ៍នៅក្នុងថ្នាក់រៀន តើលោក/លោកស្រីអាចមើលឃើញគំរូវត្ថុអ្វីខ្លះដែលមានរាងមូល ការេ ចតុកោណកែង និងត្រីកោណ? សិក្ខាកាមឆ្លើយតបហើយអ្នកសម្របសម្រួលធ្វើបញ្ជីនៅលើក្តារខៀន។ អ្នកសម្របសម្រួលសួរថាៈ **តើកុមារកំពុងរៀន ឬកំពុងអនុវត្តអ្វីខ្លះ?**

***ចំលើយរំពឹងទុកៈ*** *គណិតវិទ្យា ការស្គាល់រូបទ្រង់ទ្រាយ និងឈ្មោះទ្រង់ទ្រាយ។*

អ្នកសម្របសម្រួលបន្ទាប់មកនិយាយថាៈ **បើសិនជាខ្ញុំសុំអោយលោក/លោកស្រីពិភាក្សាហើយធ្វើបញ្ជីអំពីវត្ថុដែលមានរាងមូលទាំងអស់ ដូច្នោះតើអ្នកកំពុងរៀនឬកំពុងអនុវត្តអ្វី?**

***ចំលើយរំពឹងទុកៈ*** *គណិតវិទ្យា ការស្គាល់រូបទ្រង់ទ្រាយ និងឈ្មោះទ្រង់ទ្រាយ ព្រមទាំងអនុវត្តបំនិននិយាយ ស្តាប់ និងសរសេរ និង ជំនាញវិទ្យាសាស្ត្រនៃការសង្កេតនិងការធ្វើចំណាត់ថ្នាក់។*

អ្នកសម្របសម្រួលនិយាយថា មានមធ្យោបាយជាច្រើនដែលគេអាចប្រើប្រាស់បរិស្ថានធ្វើជាធនធានសំរាប់ការបង្រៀននិងរៀន។ បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមបង្កើតជា៤ក្រុមហើយក្រុមនីមួយៗទទួលបានថង់ប្លាស្ទិចមួយដែលមានបណ្តុំសម្ភារផ្សេងៗ។

បន្ទាប់ពីបានត្រួតពិនិត្យសម្ភាររួចហើយ អ្នកសម្របសម្រួលផ្តល់សំនួរ៣អោយក្រុមពិភាក្សានិងធ្វើវិភាគ ហើយឆ្លើយដោយប្រើតារាងខាងក្រោម ។

១. ចូរធ្វើចំណាត់ថ្នាក់សម្ភារនៅក្នុងថង់-តើវាជាសម្ភារធម្មជាតិឬជាសម្ភារដែលធ្វើដោយមនុស្ស រួចហើយសរសេរឈ្មោះវត្ថុនោះ ។
២. តើគ្រូបង្រៀនអាចប្រើសម្ភារទាំងនោះសំរាប់ការបង្រៀនបានឬទេ? ចូរសរសេរឧទាហរណ៏នៃមេរៀន៣ដែលសម្ភារទាំងនោះត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងការបង្រៀនបាន ។
៣. ចូរសរសេរវត្ថុងាយៗ២ផ្សេងទៀតនៅក្នុងបរិស្ថាន ហើយពណ៌នាពីរបៀបដែលអាចយកទៅប្រើប្រាស់ក្នុងការបង្រៀន ។

សិក្ខាកាមនៅតាមក្រុមនីមួយៗរាយការណ៏ចំលើយ ។ អ្នកសម្របសម្រួលត្រួតពិនិត្យចំលើយ ហើយបន្ថែមគំនិតផ្សេងៗទៀតបើចាំបាច់ ។

| សំនួរ | *ចំលើយរំពឹងទុក* |
|---|---|
| ១ | *ធ្វើដោយមនុស្ស: ដបទឹកសុទ្ធ កំប៉ុងទឹកដោះគោ កញ្ចប់បារី ប្រអប់ឈើគូស កៅស៊ូកង*<br>*ដោយធម្មជាតិ: កំណាត់ឈើ ស្លឹកឈើ គ្រាប់ត្នោត* |
| ២ | *បាទ/ចាស៎ ។ របស់ទាំងនេះអាចយកទៅប្រើប្រាស់ក្នុងការបង្រៀនបាន ឧទាហរណ៏*<br>*១. កំណាត់ឈើសំរាប់អោយកុមារអនុវត្តរាប់ចំនួននិងចំណាត់ជាក្រុម ប្រៀបធៀបប្រវែងនិងបង្កើតជាទ្រង់ទ្រាយអ្វីផ្សេងទៀត*<br>*២. ដបទឹកសុទ្ធ/កំប៉ុងទឹកដោះគោ/កញ្ចប់បារីសំរាប់ការបង្រៀនអំពីទ្រង់ទ្រាយ ចំណុះ ប្រវែង× ទទឹង× កំពស់ អានរូបសញ្ញា និងព័ត៏មានដែលនៅលើសម្ភារនោះ*<br>*៣. ស្លឹកឈើប្រើសំរាប់ការបង្រៀនអំពីទ្រង់ទ្រាយ ការរាប់ចំនួន*<br>*៤. ស្លឹកឈើប្រើសំរាប់ពិពណ៌នាអំពីពណ៌ ទ្រង់ទ្រាយ ភាពរលោង គ្រើម ស្អិត (ដោយផ្ទាល់មាត់ឬដោយសរសេរ)*<br>*៥. កៅស៊ូកងប្រើសំរាប់ចងបាច់ជាចំនួនដប់ៗនិងសំរាប់បង្រៀនពីតំលៃលេខឬបង្កើតជារូបទ្រង់ទ្រាយធរណីមាត្រ*<br>*៦. ដបទឹកសុទ្ធ កញ្ចប់បារីប្រើសំរាប់បង្រៀនអំពីអក្សរ ពាក្យ អក្ខរក្រម* |
| ៣ | *សត្វល្អិត-ប្រើសំរាប់បង្រៀនពីវដ្តជីវិត ផ្នែកផ្សេងៗរបស់សត្វល្អិត ឈ្មោះរបស់សត្វល្អិត* |

| | |
|---|---|
| | *សង្ខាក់ចំណីអាហារនិងប្រព័ន្ធអេកូឡូស៊ី ។*<br>*ដើមឈើផ្សេងៗ-ប្រើសំរាប់បង្រៀនអំពីផ្នែកផ្សេងៗរបស់ដើមឈើនិងការប្រើប្រាស់ជាឈើអុសសំរាប់ដុត ។*<br>*តូបផ្សេងៗនៅក្នុងសាលារៀន-ប្រើសំរាប់បង្រៀនអំពីប្រភេទអាហារ ការគណនាតំលៃប្រាក់ (ឧ. ការបង់ប្រាក់និងការអាប់លុយ) ចំនួន...*<br>*សួនច្បារដំណាំឬតូបនៅតាមផ្សារ-ប្រើសំរាប់បង្រៀនអំពីផ្លែឈើ បន្លែ អាហារូបត្ថម្ភ* |

**សេចក្តីសន្និដ្ឋានៈ** អ្នកសម្របសម្រួលនិយាយថាៈ សូមលោក/លោកស្រីរិះគិតនៅពេលកំពុងធ្វើកិច្ចតែងការបង្រៀនដោយសួរខ្លួនឯងថាៈ តើមានសម្ភារបរិស្ថានល្អៗអ្វីខ្លះដែលខ្ញុំអាចយកទៅប្រើប្រាស់ដើម្បីធ្វើអោយកុមារកាន់តែរៀនសូត្របានប្រសើរឡើង?

អ្នកសម្របសម្រួលនិយាយថាៈ ចូរលោក/លោកស្រីចងចាំថាសម្ភារដែលបានមកពីបរិស្ថានមានអត្ថប្រយោជន៍ច្រើនណាស់ដូចជា វាមានតំលៃថោក ងាយស្រួលស្វែងរក (កុមារអាចស្វែងរកសំរាប់ជាកិច្ចការនៅផ្ទះ) សម្ភារភាគច្រើនកុមារបានស្គាល់រួចទៅហើយ សម្ភារនោះអាចយកទៅប្រើប្រាស់បានច្រើនរបៀប ហើយជាពិសេសកុមារចូលចិត្តលេង។

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី២ៈ ល្បែង ត្រីជាប់ក្នុងសំណាញ់ ១៥ នាទី**

អ្នកសម្របសម្រួលពន្យល់ពីវិធីលេងល្បែង ដោយប្រាប់អោយសិក្ខាកាមពីរក្រុមឈរកាន់ដៃគ្នាជារង្វង់មូលដើម្បីធ្វើជាសំណាញ់ ហើយ២ក្រុមទៀតឈរខាងក្នុងរង្វង់នោះដើម្បីធ្វើជាត្រី។ ត្រីទាំងអស់ត្រូវប្រឹងរត់គេចចេញពីសំណាញ់នេះ។ នៅពេលត្រីទាំងនេះបានគេចចេញអស់ហើយ ពួកគេត្រូវធ្វើជាសំណាញ់ហើយសំណាញ់ត្រូវធ្វើជាត្រីជំនួសវិញ។ ក្នុងពេលលេងល្បែងនេះអ្នកទាំងឡាយដែលធ្វើជាសំណាញ់ត្រូវឈរយោលដៃព្រមទាំងច្រៀងផងដែរ។

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៣ៈ ការសំដែងតួទី២ ៦០ នាទី**

អ្នកសម្របសម្រួលពន្យល់ថាគាត់នឹងលេងសំដែងតួពីមេរៀនមួយក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៤។ អ្នកសម្របសម្រួលប្រាប់សិក្ខាកាមអោយបង្កើតជាក្រុម។ អ្នកសម្របសម្រួលអោយប្រភេទផ្កាខុសៗគ្នាទៅក្រុមនីមួយៗដើម្បី

ត្រួតពិនិត្យ ។

បន្ទាប់មកទៀតអ្នកសម្របសម្រួលអោយផ្កា១ទៀតទៅក្រុមនីមួយៗ (ផ្កាដូចៗគ្នា) ហើយអោយសិក្ខាកាមនីមួយៗនៅក្នុងក្រុមគូររូបផ្កានោះព្រមទាំងប្រាប់ពីឈ្មោះផ្នែកផ្សេងៗរបស់ផ្កានោះផង បន្ទាប់មកអោយសមាជិកក្រុមប្រៀបធៀបគ្នាដើម្បីសម្រេចយកផ្កាតែ១ដែលល្អជាងគេយកទៅបិទនៅលើក្ដារខៀន ។

បន្ទាប់ពីក្រុមនីមួយៗរាយការណ៍រួចហើយ អ្នកសម្របសម្រួលបង្ហាញរូបគំនូរផ្កា (ដែលគាត់បានរៀបចំរួចជាស្រេច) ដោយបិទលើក្ដារខៀនព្រមទាំងប័ណ្ណឈ្មោះនៃផ្នែកនីមួយៗរបស់ផ្កាផងដែរ ។ បន្ទាប់មកអ្នកសម្របសម្រួលគូរតារាងជាកូឡោនដែលកូឡោននីមួយៗមានសរសេរចំណងជើងឈ្មោះផ្នែកផ្សេងៗនៃផ្កា (**មើលតារាងខាងក្រោម**) ។ អ្នកសម្របសម្រួលប្រាប់ក្រុមនីមួយៗអោយបំពេញតារាងនូវប្រភេទផ្កាផ្សេងៗ ដែលគេបានពិនិត្យកាលពីពេលចាប់ផ្ដើមមេរៀនដំបូង ។

បន្ទាប់ពីក្រុមទាំងឡាយបានបំពេញតារាងរួចហើយ អ្នកសម្របសម្រួលចង់ពង្រឹងបន្ថែមដោយបិទរូបភាពផ្កាមួយផ្សេងទៀត (ត្រូវបានរៀបចំរួចជាស្រេច) នៅលើក្ដារខៀនហើយអោយសិក្ខាកាមផ្គូរផ្គងផ្នែកផ្សេងៗនៃផ្កានោះជាក្រុមថ្នាក់ទាំងមូល ។

**តារាង**

| ឈ្មោះផ្កា | ចំនួនស្រទាប់ | ពណ៌ស្រទាប់ | ចំនួនត្របក | ពណ៌ត្របក | ទីតាំងកញ្ចុំកេសរឈ្មោល | ទីតាំងកញ្ចុំកេសរញី |
|---|---|---|---|---|---|---|
| ផ្កាឈូក | | | | | | |
| ។ល។ | | | | | | |
| ។ល។ | | | | | | |

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៤: ការពិភាក្សាជាក្រុមតូចៗ** **៣០ នាទី**

អ្នកសម្របសម្រួលអោយក្រុមនីមួយៗពិភាក្សាការសំដែងតួទី៣ រួចហើយឆ្លើយសំនួរខាងក្រោម

| សំនួរ | *ចំលើយរំពឹងទុក* |
|---|---|
| ហេតុអ្វីបានជាគ្រូបង្រៀនប្រើប្រាស់ផ្កាជាក់ស្តែង | *បទពិសោធន៍ពិតជាក់ស្តែង សម្ភារងាយរក* |

| | |
|---|---|
| ជំនួសអោយរូបភាពផ្កានៅក្នុងសៀវភៅ? | *និងមានតំលៃថោក។* |
| ហេតុអ្វីបានជាគ្រូបង្រៀនអោយកុមារគូររូបផ្កាល់ខ្លួនជំនួសការចំលងគំនូរផ្កាពីគ្រូដោយផ្ទាល់? | *ការគូរដោយខ្លួនឯងគឺធ្វើអោយមានការគិត កុមារទាំងអស់ចូលរួមគ្រប់ៗគ្នា។* |
| បន្ទាប់មកហេតុអ្វីក៏គ្រូបង្រៀនអោយកុមារស្វែងរកផ្នែកផ្សេងៗនៅលើផ្កាទាំងអស់នោះ? | *ដូច្នោះកុមារអាចនិយាយពីចំណេះដឹងថ្មី ប្រើទ្រឹស្តីដើម្បីអនុវត្តការនិយាយនិងការស្តាប់ពីគ្នាទៅវិញទៅមក។* |

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៥: រំលឹកល្បែងសិក្សា** **៣០ នាទី**

អ្នកសម្របសម្រួលអោយសិក្ខាកាមរំលឹកឡើងវិញពីល្បែងសិក្សាទាំងអស់ ដែលគេបានជួបប្រទះនៅក្នុងវគ្គបណ្តុះបណ្តាលនេះ ហើយរៀបរាប់អំពីអ្វីដែលល្បែងនេះជួយពង្រីកការយល់ដឹងនិងបំនិន (សមត្ថភាព) របស់សិស្ស។ អ្នកសម្របសម្រួលចែកឯកសារដែលមានឈ្មោះល្បែងដើម្បីអោយសិក្ខាកាមអាចធ្វើកំណត់សំគាល់ផ្សេងៗអំពីល្បែងនោះ។

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៦: ការអាន "ការត្រៀមខ្លួនជាស្រេចដើម្បីចាប់ផ្តើមមេរៀន និងការស្រូបយកចំណេះដឹងថ្មី" ៣០ នាទី**

អ្នកសម្របសម្រួលចែកឯកសារដែលដកស្រង់ពីឯកសារTGL (ទំព័រ៩-១០) សំរាប់គ្រូបង្រៀនដើម្បីស្វែងយល់បន្ថែមពីបច្ចេកទេសទី២ (**ឯកសារទី២៤**)។

នៅពេលបញ្ចប់ការអាននិងការពិភាក្សា អ្នកសម្របសម្រួលសួរសំនួរមួយចំនួនដើម្បីវាយតំលៃការយល់ដឹងរបស់សិក្ខាកាម។

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៧: ល្បែងសិក្សា: ប្រអប់អក្សរ** **១៥ នាទី**

ការហាត់បង្កើតពាក្យ, ព្យាង្គ

អ្នកសម្របសម្រួលកំណត់អក្សរ ព្យញ្ជនៈ ស្រៈ ក្នុងតារាង រួចហើយអោយសិក្ខាកាមបង្កើតពាក្យមួយព្យាង្គ ពីរព្យាង្គ

និងបីព្យាង្គ នៅក្នុងក្រុមរបស់ខ្លួន។ អ្នកសម្របសម្រួលអោយសមាជិកនីមួយៗក្នុងក្រុមឡើងរាយការណ៍ ហើយគាត់ជួយកែលំអ។

**បច្ចេកទេសបង្រៀន TGL ទី៤: ការពង្រីកបំនិនសរសេររបស់កុមារដោយការប្រើប្រាស់ភាសាផ្ទាល់របស់គេ**

**ថ្ងៃទី៧**

**ដំណាក់កាលបង្រៀនទី៨: ការសរសេររបស់កុមារ-សកម្មភាពទី១** ៣០ នាទី

អ្នកសម្របសម្រួលលើកបង្ហាញទង់ជាតិប្រទេសអូស្ត្រាលី ហើយអោយសិក្ខាកាមក្នុងក្រុមដែលមានគ្នា៤នាក់នូវក្រដាស២ចំណិត។ អ្នកសម្របសម្រួលអោយពួកគេសរសេរប្រយោគ២ដោយពិពណ៌នាអំពីទង់ជាតិនោះ ប្រយោគមួយដាក់លើសន្លឹកក្រដាសមួយ។ នៅពេលគ្រប់គ្នាបានបញ្ចប់ ត្រូវយកសន្លឹកក្រដាសនោះទៅបិទនៅលើក្តារខៀន។ ការសរសេរនេះមួយចំនួនតូចអាចមានលក្ខណះដូចគ្នា។ អ្នកសម្របសម្រួលគួរតែសរសេរប្រយោគ២នៅលើក្តារខៀនហើយបាំងអោយជិត។ នៅចុងបញ្ចប់អ្នកសម្របសម្រួលអាចបង្ហាញប្រយោគ២នោះហើយសួរសិក្ខាកាមថា តើនឹងមានអ្វីកើតឡើងបើសិនលោក/លោកស្រីបានចំលងយកប្រយោគរបស់គ្រូបង្រៀនទាំងនេះ? *(ចំលើយ: យើងនឹងបានប្រយោគច្រើនដែលដូចគ្នាទាំងអស់)*។

អ្នកសម្របសម្រួលនិយាយថា អ្នកអប់រំនៅទូទាំងពិភពលោកបានរកឃើញថាមធ្យោបាយដែលល្អបំផុតក្នុងការរៀនបំនិនសរសេរគឺដោយសារការសរសេរ។ នេះមានន័យថាដើម្បីចង់ក្លាយជាអ្នកនិពន្ធ កុមារត្រូវសរសេរអោយបានច្រើនដោយខ្លួនពួកគេ-ដោយប្រើពាក្យផ្ទាល់ បង្កើតប្រយោគផ្ទាល់ សរសេររឿងផ្ទាល់។ វាមានភាពខុសគ្នាយ៉ាងចំបងរវាងការសរសេរនិងការចំលង... ពីព្រោះនៅពេលសរសេរទោះបីជាប្រយោគសាមញ្ញក៏ដោយគឺវាតំរូវអោយប្រើប្រាស់ការស្វែងយល់និងបំនិនភាសាច្រើន។

អ្នកសម្របសម្រួលសួរសិក្ខាកាមៈ **តើមានភាពខុសគ្នាអ្វីខ្លះរវាងការសរសេរនិងការចំលង?**
***ចំលើយរំពឹងទុក:*** *ការចំលងគឺជាការសរសេរឬកត់ត្រាអ្វីមួយដែលគេបានសរសេរទុករួចហើយ ចំណែកការសរសេរគឺនៅពេលអ្នកប្រើគំនិតផ្ទាល់ខ្លួន ប្រើពាក្យសំដីផ្ទាល់ បង្កើតអ្វីមួយដែលថ្មី។*

អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាមជ្រើសរើសប្រយោគដែលល្អបំផុតអំពីទង់ជាតិនោះ ហើយដាក់រួមគ្នាដើម្បីបង្កើតជាក្រុមអត្ថបទមួយ។

ថ្ងៃទី៧

ដំណាក់កាលបង្រៀនទី៩: ការសរសេររបស់កុមារ-សកម្មភាពទី២ ៣០ នាទី

អ្នកសម្របសម្រួលនិយាយថា គ្រូបង្រៀនមានមធ្យោបាយជាច្រើនក្នុងការងារបង្រៀនកុមារនៅបឋមសិក្សាដើម្បីជួយកុមារក្នុងការសរសេរ ហើយដើម្បីអោយកុមារអាចក្លាយទៅជាអ្នកនិពន្ធដែលមានជំនឿចិត្ត។ អ្នកសម្របសម្រួលនិយាយទៀតថា នៅក្នុងថ្នាក់ដំបូងកុមារមិនអាចសរសេរបានច្រើនទាល់តែសោះ ក្រោយមកពួកគេចេះសរសេរពាក្យ ប្រយោគ កថាខ័ណ្ឌ និងអាចជារឿងខ្លីៗផងដែរ។ ដូចនេះដំណាក់កាលសរសេររបស់កុមារយើងអាចដាក់ទៅជាទំរង់ដូចខាងក្រោម:

| កុមារនៅក្នុង | មធ្យោបាយនៃការប្រើភាសារបស់កុមារដើម្បីបង្កើតបំនិនសរសេរ |
|---|---|
| ថ្នាក់ទី១ | គ្រូប្រើរូបភាព ជាពិសេសគំនូរផ្ទាល់របស់កុមារ សួរកុមារថាតើគំនូរឬរូបភាពនេះនិយាយអំពីអ្វី បន្ទាប់មកសរសេរពាក្យផ្ទាល់របស់កុមារនោះ ហើយអោយគេចំលងទុក។ នៅពេលរៀនចប់ថ្នាក់ទី១កុមារភាគច្រើនអាចសរសេរដោយប្រើប្រាស់ពាក្យសំដីរបស់គេបាន។ |
| ថ្នាក់ទី២ | គ្រូអោយកុមារបង្កើតប្រយោគហើយអានប្រយោគនោះ។ គ្រូសរសេរប្រយោគផ្ទាល់របស់កុមារក្នុងពេលដែលគេអាន។ កុមារចំលងប្រយោគនោះទុក។ កុមារមួយភាគច្រើននឹងចាប់ផ្តើមបង្កើតប្រយោគសាមញ្ញៗរបស់គេផ្ទាល់។ |
| ថ្នាក់ទី៣ | កុមារចាប់ផ្តើមសរសេរប្រយោគងាយៗផ្ទាល់ខ្លួនឬលំដាប់នៃប្រយោគ។ |
| ថ្នាក់ទី៤ | កុមារអាចសរសេរប្រយោគដោយខ្លួនឯងបាននិងកុមារជាច្រើនទៀតអាចសរសេររឿងឬអត្ថបទខ្លីៗបាន។ |
| ថ្នាក់ទី៥ | កុមារអាចសរសេរអត្ថបទខ្លីដោយខ្លួនឯង ហើយកុមារមួយចំនួនទៀតអាចសរសេរបានកថាខ័ណ្ឌលើសពីមួយ។ |
| ថ្នាក់ទី៦ | កុមារអាចសរសេរជាអត្ថបទផ្ទាល់របស់គេដោយប្រើកថាខ័ណ្ឌជាច្រើន។ |

បញ្ហាសំខាន់បំផុតដែលគ្រូបង្រៀនត្រូវចងចាំគឺថា (ធ្វើយ៉ាងណាអោយអស់លទ្ធភាព) កុមារគួរតែជ្រើសរើសនិងសរសេរពាក្យនិងប្រយោគដោយខ្លួនពួកគេផ្ទាល់។

ថ្ងៃទី៧

ដំណាក់កាលបង្រៀនទី១០:ការអានឯកសារ"ការប្រើប្រាស់ភាសារបស់កុមារ-ការពិពណ៌នាអំពីកង់" ៣០ នាទី

| |
| --- |
| អ្នកសម្របសម្រួលចែកឯកសារអោយអាន ដែលបានពីឯកសារ TGL (ទំព័រ ១៨-១៩) សំរាប់គ្រូបង្រៀនដើម្បីធ្វើការស្វែងយល់បន្ថែមលើបច្ចេកទេស TGL ទី២ (**ឯកសារទី២៥**)។<br><br>នៅពេលគេបញ្ចប់ការអាននិងការពិភាក្សា អ្នកសម្របសម្រួលសួរសំនួរមួយចំនួនដើម្បីវាយតំលៃកំរិតយល់ដឹងរបស់ពួកគេ។ |
| **ថ្ងៃទី៧**<br>**ដំណាក់កាលបង្រៀនទី១១: ការសន្និដ្ឋាន(រំលឹកបច្ចេកទេសទាំង៤ឡើងវិញ) ៣០ នាទី**<br><br>អ្នកសម្របសម្រួលរំលឹកបច្ចេកទេសទាំងអស់ឡើងវិញ ដោយធ្វើការសង្ខេបគំនិតសំខាន់ៗហើយប្រាប់ពីសារៈប្រយោជន៍ព្រមទាំងសួរសំនួរមួយចំនួន ដូច្នោះពួកគេអាចចងចាំបានល្អ។ |

## ថ្ងៃទី៨  ការបង្កើតសម្ភារសំរាប់ល្បែងសិក្សា

## កញ្ចប់ធនធានសំរាប់គ្រូសហគមន៍

ថ្ងៃទី៨

ដំណាក់កាលបង្រៀនទី១: កញ្ចប់ធនធានសំរាប់គ្រូសហគមន៍ ៤៥ នាទី

អ្នកសម្របសម្រួលណែនាំបង្ហាញពីកញ្ចប់ធនធានដោយនិយាយថា អេស្កាប់បានប្រមូលផ្ដុំកញ្ចប់សម្ភារដែលអាចជួយគ្រូសហគមន៍បាន។

អ្នកសម្របសម្រួលនិយាយថា: ខ្លឹមសារសំខាន់ៗរបស់កញ្ចប់ធនធានគឺមានសម្ភារដែលបានផលិតរួចហើយអាចយកទៅដាក់តាំងលើជញ្ជាំងបន្ទប់រៀននិងប្រើប្រាស់បានទូទាំងឆ្នាំសិក្សា។ សម្ភារទាំងនេះមាន តារាងអក្ខរក្រម តារាងប្រព័ន្ធចំនួននិងផែនទី។

អ្នកសម្របសម្រួលនិយាយថា: កញ្ចប់ធនធាននេះរួមមានសម្ភារដែលគ្រូអាចប្រើដើម្បីធ្វើអោយបរិយាកាសថ្នាក់រៀនមានការចាប់អារម្មណ៍និងទាក់ទាញដល់កុមារ។ ឧទាហរណ៍សម្ភារដូចជា

- ស្កុតប្រើសំរាប់បិទកិច្ចការរបស់សិស្សនៅលើជញ្ជាំងថ្នាក់រៀន
- ខ្សែរនិងដង្កៀបសំរាប់តាំងបង្ហាញការងាររបស់កុមារនៅផ្នែកខាងលើតុសិស្សឆ្លងកាត់បន្ទប់
- ក្រដាសកាតុងសំរាប់កាត់ដើម្បីគូររូបភាពឬសរសេរជារូបមន្តផ្សេងៗ...
- ក្ដារឆ្នួនអាចប្រើសំរាប់គូររូបភាពងាយដោយមិនបាច់ប្រើផ្ទាំងរូបភាព ( អាចប្រើប្រាស់បានច្រើនដង)

អ្នកសម្របសម្រួលនិយាយថា: នៅក្នុងកញ្ចប់ធនធាននេះក៏មានសម្ភារសំរាប់អោយគ្រូប្រើប្រាស់ក្នុងការបង្រៀន-រៀនដែលអាចប្រើលើប្រភេទផ្សេងៗនៃល្បែងសិក្សាងាយៗ ជាពិសេសនៅក្នុងភាសាខ្មែរនិងគណិតវិទ្យា។ កុមារទាំងអស់ចូលចិត្តល្បែងទាំងអស់នេះណាស់ ហើយល្បែងទាំងនេះគឺសមស្របនៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌល និងមានលក្ខណៈប្រសើរសំរាប់កសាងបំនិននៅក្នុងភាសាខ្មែរនិងគណិតវិទ្យា។ សម្ភារទាំងនេះអាចជួយអោយកុមារលេងដោយមានភាពឯករាជ្យ។ នៅក្នុងដំណាក់កាល២បន្ទាប់ទៅនេះ យើងនឹងបានឃើញគំរូសម្ភារទាំងនេះ ហើយយើងអាចបង្កើតនិងប្រើប្រាស់វាបន្ថែមទៀត។

អ្នកសម្របសម្រួលនិយាយថាៈ មានក្រដាស២សន្លឹកនៅក្នុងកញ្ចប់ធនធាន។ សន្លឹកក្រដាសទី១គឺជាបញ្ជីសំរាប់អោយលោក/លោកស្រីផ្ទៀងផ្ទាត់ដោយគ្រាន់តែគូសសញ្ញា✓ទៅតាមវត្ថុទាំងនោះដើម្បីអោយបានដឹងថាវាមានលក្ខណៈគ្រប់គ្រាន់។ សន្លឹកក្រដាសទី២គឺជាសន្លឹកកំណត់ហេតុ (log sheet) ដែលនឹងប្រើប្រាស់នៅក្នុងឆ្នាំសិក្សាដើម្បីអោយដឹងថាអ្នកបានប្រើប្រាស់និងបង្កើតអ្វីខ្លះ។

អ្នកសម្របសម្រួលនិយាយថាៈ ឥឡូវនេះចូរត្រួតពិនិត្យមើលតើអ្នកមានអ្វីខ្លះហើយគូសសញ្ញា✓នៅលើបញ្ជី (**ឯកសារទី២៦**)។ ចូរចុះហត្ថលេខាលើបញ្ជីនោះហើយប្រគល់ទៅអោយអ្នកសម្របសម្រួលតាមក្រុម។ បើសិនជាមានសម្ភារណាមួយខ្វះខាតឬបាត់បង់ សូមប្រាប់ទៅអ្នកសម្របសម្រួល។ នៅពេលត្រួតពិនិត្យមើលសម្ភារទាំងនោះ វាគឺជាពេលមួយដែលលោក/លោកស្រីអាចពិភាក្សាអំពីការប្រើប្រាស់ផងដែរ។

អ្នកសម្របសម្រួលប្រមូលយកបញ្ជីផ្ទៀងផ្ទាត់មួយពីសិក្ខាកាមនីមួយៗ ហើយសួរថាតើពួកគេមានសំនួរអ្វីទេអំពីការប្រើប្រាស់សម្ភារទាំងនោះ?។ អ្នកសម្របសម្រួលអាចសួរសំនួរអំពីវត្ថុមួយចំនួនដើម្បីត្រួតពិនិត្យការយល់ដឹង (ឧទាហរណ៍ ខ្សែរ ដង្កៀប...)។

**កញ្ចប់សម្ភាររបស់គ្រូសហគមន៍-បញ្ជីខ្លឹមសារ**

| លរ | វត្ថុ | ចំនួន |
|---|---|---|
| ១ | តារាងអក្ខរក្រម | ១ |
| ២ | តារាងចំនួន | ១ |
| ៣ | ផែនទីប្រទេសកម្ពុជា | ១ |
| ៤ | ក្រដាសវ៉ាមធំ | ១០ សន្លឹក |
| ៥ | មែត្រខ្សែ(វាស់ខោអាវ) | ៤ |
| ៦ | ជញ្ជីងថ្លឹងដៃ | ១ |
| ៧ | កៅស៊ូកង | ១០០ក |
| ៨ | បំពង់បឺត | ៣៧៥ |
| ៩ | ខ្សែ | ៥០ម |
| ១០ | ដង្កៀបសំរាប់ហាលខោអាវ | ៦០ |
| ១១ | ស្កុត | ១ដុំ |

| | | |
|---|---|---|
| ១២ | ដែកគោលមូក | ២ប្រអប់ |
| ១៣ | កន្ត្រៃធំ | ១គូ |
| ១៤ | កន្ត្រៃតូច | ១គូ |
| ១៥ | ហ្វឺតក្រដាស (ពណ៌ខ្មៅ) | ៦ |
| ១៦ | ទឹកហ្វឺត (ពណ៌ខ្មៅ) | ១ដប |
| ១៧ | ឃ្នាបគាបក្រដាស | ១ប្រអប់ |
| ១៨ | ឃ្នាបគាបធំ | ១២ |
| ១៩ | ក្រដាសកាតុង | ៤សន្លឹក |
| ២០ | គូល័រឈើ | ៥ប្រអប់ |
| ២១ | ក្តារឆ្នួន | ១០ |
| ២២ | តារាងរដ្ឋបាលទាំង៩ | ១ឈុត |
| ២៣ | តយវាស់ចំណុះ | ១ឈុត |
| ២៤ | បន្ទាត់ផ្លាស្ទិចតូច | ២០ |
| | ប្រអប់ | ១ |

ថ្ងៃទី៨

**ដំណាក់កាលបង្រៀនទី២: ល្បែងសិក្សា** **៤៥ នាទី**

អ្នកសម្របសម្រួលនិយាយថា: មានល្បែងជាច្រើនត្រូវបានគេប្រើប្រាស់ក្នុងការសិក្សានៅក្នុងសាលារៀនពាសពេញពិភពលោក ប៉ុន្តែល្បែងដែលប្រសើរបំផុតសំរាប់យើងនៅក្នុងប្រទេសកម្ពុជាគឺជាល្បែងដែល:

- កុមាររៀនបានច្រើន
- កុមារចូលចិត្តលេងល្បែង និងការសិក្សា
- ល្បែងដែលមានតំលៃថោក ហើយងាយប្រើប្រាស់
- សម្ភារនោះអាចប្រើប្រាស់បានលើល្បែងច្រើនប្រភេទ (អាចបត់ទៅណាក៏បាន ដើម្បីបង្កើតជារូបភាពផ្សេងៗទៀត)

អ្នកសម្របសម្រួលនិយាយថា: ចំនុចចុងក្រោយនេះគឺសំខាន់ណាស់ពីព្រោះសម្ភារសំរាប់ការបង្រៀនភាគច្រើនដែល

បានផលិតនិងប្រើប្រាស់នៅក្នុងសាលារៀននៅប្រទេសកម្ពុជា គឺមិនមានលក្ខណៈបត់បែនទេ-វាអាចប្រើបានតែម្តងនៅក្នុងតែមេរៀនមួយ រួចហើយត្រូវទុកចោលសំរាប់ប្រើនៅឆ្នាំក្រោយទៀត។ សម្ភារមួយចំនួនដែលយើងនឹងផលិតនៅថ្ងៃនេះអាចយកទៅប្រើប្រាស់បានច្រើនដង ដោយគ្រូនិងសិស្សគ្រាន់តែយកទៅបង្កើតជារបៀបថ្មីលើសម្ភារនោះតែប៉ុណ្ណោះ។

អ្នកសម្របសម្រួលនិយាយថាៈ យើងនឹងបង្ហាញលោក/លោកស្រីនូវរបៀបផ្សេងៗជាច្រើននៃល្បែងសិក្សានៅក្នុងគណិតវិទ្យានិងភាសាខ្មែរនៅថ្ងៃនេះ។ ប្រភេទល្បែងដែលយើងនឹងមើលនៅពេលនេះគឺពាក់ព័ន្ធទៅនឹងបញ្ញត្តិ៣ដែលខ្ញុំនឹងធ្វើបង្ហាញដោយប្រើប័ណ្ណមួយចំនួន...

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| មួយ | ពីរ | បី | បួន | ប្រាំ | ប្រាំមួយ | ប្រាំពីរ | ប្រាំបី | ប្រាំបួន | ដប់ |

ទី១ អ្នកសម្របសម្រួលបង្កើតជា២ក្រុម-មួយជាប័ណ្ណចំនួននិងមួយទៀតជាប័ណ្ណចំនួនពាក្យ ហើយសួរសិក្ខាកាមថាៈ តើលោក/លោកស្រីពិពណ៌នាការរៀបចំសកម្មភាពនេះយ៉ាងដូចម្តេច?

*ចំលើយរំពឹងទុកៈ ការដាក់ប័ណ្ណដែលដូចគ្នាជាមួយគ្នាទៅតាមប្រភេទក្រុមខុសៗគ្នា។*

ទី២ អ្នកសម្របសម្រួលបង្កើតប័ណ្ណចំនួនទាំងអស់ពីលំដាប់ទី១-១០ហើយសួរសិក្ខាកាមថាៈ **តើលោក/លោកស្រីពិពណ៌នាការរៀបចំសកម្មភាពនេះយ៉ាងដូចម្តេច?**
*ចំលើយរំពឹងទុកៈ ការដាក់ប័ណ្ណទៅតាមលំដាប់ត្រឹមត្រូវ*

ទី៣ អ្នកសម្របសម្រួលរៀបចំប័ណ្ណដោយផ្គូរផ្គងប័ណ្ណលេខនីមួយៗជាមួយប័ណ្ណចំនួនពាក្យហើយសួរសិក្ខាកាមថាៈ **តើលោក/លោកស្រីពិពណ៌នាការរៀបចំ សកម្មភាពនេះយ៉ាងដូចម្តេច?**
*ចំលើយរំពឹងទុកៈ ការដាក់ប័ណ្ណដែលមានន័យដូចគ្នាជាមួយគ្នាជាគូៗ។*

អ្នកសម្របសម្រួលនិយាយថាៈ ជាធម្មតាយើងហៅសកម្មភាពនៃការរៀបចំទាំង៣នេះថា...

| ការផ្គូរផ្គង | ការរៀបតាមលំដាប់លំដោយ (លំដាប់/ការរៀបលំនាំគំរូ) | ការធ្វើចំណាត់ថ្នាក់ប្រភេទ |
|---|---|---|

អ្នកសម្របសម្រួលនិយាយថាៈ **តើលោក/លោកស្រីគិតថាមានចំណេះដឹងនិងបំនិនអ្វីខ្លះដែលកុមារកំពុងអនុវត្តដោយការលេងល្បែងទាំងអស់នេះ? តើលោក/លោកស្រីគិតថាល្បែងនេះសមស្របសំរាប់ថ្នាក់ទីប៉ុន្មាន?**

***ចំលើយរំពឹងទុកៈ*** ចំណេះដឹងក្នុងការរាប់ចំនួនពី១-១០ ការអានឈ្មោះចំនួនពី១-១០ ការធ្វើការរបៀបសហការ ការពន្យល់ពីគំនិតផ្ទាល់របស់ពួកគេ ការចេះស្តាប់អ្នកដទៃ ។ល ។ ល្បែងនេះសមស្របសំរាប់ថ្នាក់ទី១ ។

អ្នកសម្របសម្រួលនិយាយថាៈ **បញ្ញត្តិនៅក្នុងល្បែងនោះគឺសំខាន់ណាស់ ។** បើសិនជាគ្រូបង្រៀនយល់ពីបញ្ញត្តិនេះ វាមានន័យថាពួកគេអាចបង្កើតល្បែងប្រភេទតែមួយបានគ្រប់កំរិតថ្នាក់ ដោយគ្រាន់តែផ្លាស់ប្តូរខ្លឹមសារអោយស្រប ទៅតាមកំរិតថ្នាក់នោះតែប៉ុណ្ណោះ ។

---

**ថ្ងៃទី៨**

**ដំណាក់កាលបង្រៀនទី៣ៈ ការបង្ហាញអំពីល្បែងសិក្សាសំរាប់គណិតវិទ្យា** **៩០ នាទី**

អ្នកសម្របសម្រួលពន្យល់ពីរបៀបនៃការបង្ហាញ និងរបៀបដែលសិក្ខាកាមត្រូវវិលពីកន្លែងមួយទៅកន្លែងមួយទៀត នៅពេលដែលឮសំលេងកណ្តឹងរោទិ៍ ( ក្រុមទី១វិលទៅក្រុមទី២ ក្រុមទី២វិលទៅក្រុមទី៣ និង ក្រុមទី៣ត្រឡប់ទៅក្រុមទី១ខាងដើម) រហូតដល់សិក្ខាកាមទាំងអស់បានចូលទៅតាមក្រុមគ្រប់ៗគ្នា ។

អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៣ក្រុម ។ អ្នកសម្របសម្រួល៣នាក់ធ្វើការបង្ហាញអំពីល្បែងសិក្សានៅក្នុងផ្នែកខុសៗគ្នាទាំង៣នៃវគ្គបណ្តុះបណ្តាល ។ នៅក្នុងការបង្ហាញទី១ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាជាច្រើននៅក្នុងគណិតវិទ្យាដោយផ្អែកលើគំនិតនៃការរៀបតាមលំដាប់លំដោយ ។ នៅក្នុងការបង្ហាញទី២ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាដោយផ្អែកលើគំនិតនៃការផ្គូរផ្គង ។ ហើយការសំដែងតួទី៣នេះ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាដោយផ្អែកលើគំនិតនៃការធ្វើចំណាត់ថ្នាក់ប្រភេទ ។ ក្រុមនីមួយៗនៃសិក្ខាកាមចាប់ផ្តើមការបង្ហាញទី១ ដោយធ្វើការសង្កេតនិងចូលរួមលេងល្បែង ។

បន្ទាប់ពីការបង្ហាញលើប្រភេទល្បែងនីមួយៗ អ្នកសម្របសម្រួលសួរថាៈ **តើល្បែងនេះផ្តល់នូវចំណេះដឹងនិងបំនិន**

អ្វីខ្លះ? តើល្បែងនេះប្រហែលជាសមស្របនឹងកំរិតថ្នាក់ទីប៉ុន្មាន? តើប្រភេទល្បែងអ្វីខ្លះទៀតដែលអាចលេងជាមួយសម្ភារនេះបាន?

បន្ទាប់ពីរយៈពេល២០នាទី អ្នកសម្របសម្រួលម្នាក់ចុចកណ្ដឹងហើយក្រុមនីមួយៗចូលទៅដល់ការបង្ហាញនៅក្នុងក្រុមបន្ទាប់ទៀត។

*សេចក្ដីសង្ខេបអំពីល្បែងគណិតវិទ្យា*

| បញ្ញត្តិ | ឧទាហរណ៍ |
|---|---|
| ការរៀបតាមលំដាប់លំដោយ | ១. គំរូ ទ្រង់ទ្រាយធរណីមាត្រចំនួន (ប្រើប័ណ្ណ)<br>២. ដ្យាក្រាមចំនួននិងចំនួន (ប្រើក្ដារឆ្នួន)<br>៣.ប្រៀបធៀបវត្ថុដែលមានប្រវែងខុសគ្នា (ប្រើចំណិតក្រដាស)<br>៤. ឯកតារង្វាស់ប្រវែងផ្សេងៗ (ប្រើប័ណ្ណ) |
| ការផ្គូរផ្គង | ១. រូបភាពនិងចំនួន (ប្រើក្ដារឆ្នួន)<br>២. ប្រភាគ ភាគរយនិងទស្សភាគជាមួយនឹងរូបភាព (ប្រើប័ណ្ណ)<br>៣. រង្វាស់ បម្លាស់ សមមូល (ប្រើប័ណ្ណ)<br>៤. ចំនួនតួលេខបីដែលមានលេខ ១ ,១០, ១០០ (ប្រើប័ណ្ណ) |
| ចំណាត់ថ្នាក់ប្រភេទ | ១. ទ្រង់ទ្រាយ (ប្រើក្ដារឆ្នួន)<br>២. ចំនួនដែលមានលក្ខណៈផ្សេងៗគ្នា (មេគុណនៃចំនួន១០ ការេ ចំនួនគូ ចំនួនសេស)<br>៣. ការស្វែងរកចំនួនខុសគេ-ពហុគុណនៃចំនួន១០និងមិនមែនពហុគុណ ការេនិងមិនមែនការេ ចំនួនសេសនិងចំនួនគូ (ប្រើប័ណ្ណ)<br>៤. អក្សរកាត់នៃឯកតារង្វាស់ប្រវែង ម៉ាស ចំណុះ និងផ្ទៃ (ប្រើប័ណ្ណ) |

នៅពេលបញ្ចប់ការបង្ហាញទាំងអស់អ្នកសម្របសម្រួលផ្តល់ឯកសារដែលពួកគាត់អាចសរសេរកំណត់សំគាល់អំពីអ្វីដែលបានឃើញនៅក្នុងការបង្ហាញ (**ឯកសារទី២៧**) ។

**ថ្ងៃទី៨**

**ដំណាក់កាលបង្រៀនទី៤: ការបង្ហាញអំពីល្បែងសិក្សាសំរាប់ភាសាខ្មែរ** **៩០ នាទី**

ការបង្ហាញលើល្បែងសិក្សាភាសាខ្មែរមានដំណើរការដូចដំណាក់កាលបង្រៀនមុន (ល្បែងសិក្សាគណិតវិទ្យា) ។

អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៣ក្រុម ។ អ្នកសម្របសម្រួល៣នាក់ធ្វើការបង្ហាញអំពីល្បែងសិក្សានៅក្នុងផ្នែកខុសៗគ្នាទាំង៣នៃវគ្គបណ្តុះបណ្តាល ។ នៅក្នុងការបង្ហាញទី១ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាមួយចំនួននៅក្នុងភាសាខ្មែរដោយផ្អែកលើបញ្ញត្តិនៃការរៀបតាមលំដាប់លំដោយ ។ នៅក្នុងការបង្ហាញលើកទី២ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាដោយផ្អែកលើបញ្ញត្តិនៃការផ្គូរផ្គង ។ ហើយការសំដែងតួទី៣នេះ អ្នកសម្របសម្រួលបង្ហាញនូវល្បែងសិក្សាដោយផ្អែកលើបញ្ញតិនៃការធ្វើចំណាត់ថ្នាក់ ។ ក្រុមនីមួយៗនៃសិក្ខាកាមចាប់ផ្តើមការបង្ហាញទី១ ដោយធ្វើការសង្កេតនិងចូលរួមលេងល្បែង ។ បន្ទាប់ពីរយៈពេល២០នាទី អ្នកសម្របសម្រួលម្នាក់ចុចកណ្តឹង ហើយក្រុមនីមួយៗចូលទៅដល់ការបង្ហាញទី២ ។ បន្ទាប់ពីរយៈពេល១ម៉ោងក្រុមទាំងអស់នឹងបានបញ្ចប់នូវការបង្ហាញទាំង៣ ។ នៅពេលបញ្ចប់ការបង្ហាញទាំងអស់អ្នកសម្របសម្រួលផ្តល់ឯកសារដែលពួកគាត់អាចសរសេរកំណត់សំគាល់អំពីអ្វីដែលបានឃើញនៅក្នុងការបង្ហាញ (**ឯកសារទី២៨**) ។

បន្ទាប់ពីការបង្ហាញលើប្រភេទល្បែងនីមួយៗ អ្នកសម្របសម្រួលសួរថា: **តើល្បែងនេះផ្តល់នូវចំណេះដឹងនិងបំនិនអ្វីខ្លះ? តើល្បែងនេះប្រហែលជាសមស្របនឹងកំរិតថ្នាក់ទីប៉ុន្មាន? តើប្រភេទល្បែងអ្វីខ្លះទៀតដែលអាចលេងជាមួយសម្ភារនេះបាន?**

*សេចក្តីសង្ខេបអំពីល្បែងសិក្សាភាសាខ្មែរ*

| បញ្ញត្តិ | ឧទាហរណ៏ |
|---|---|
| **ការរៀបចំតាមលំដាប់លំដោយ** | ១. ថ្ងៃនៃសប្តាហ៏និងថ្ងៃនេះ/ថ្ងៃស្អែក/ម្សិលមិញ ។ល ។ (ប្រើក្តារឆ្នួន)<br>២. រៀបចំអក្សរច្របល់អោយក្លាយជាអត្ថបទ (ប្រើប័ណ្ណ) |

| | |
|---|---|
| | ៣. រៀបចំពាក្យច្របល់អោយក្លាយជាប្រយោគ (បូករួមទាំងសញ្ញាវណ្ណយុត្តិ) (ប្រើប័ណ្ណ)<br>៤. លំដាប់អក្ខរក្រម (ប្រើប័ណ្ណ) |
| **ការផ្គូរផ្គង** | ១.ពាក្យនិងរូបភាពអំពីសមាជិកគ្រួសារ (ប្រើក្តារឆ្នួន)<br>២. រូបភាពនិងប្រយោគ (ប្រើប័ណ្ណ)<br>៣. ពាក្យផ្ទុយ (ប្រើប័ណ្ណ)<br>៥. ពាក្យនិងនិយមន័យ (ប្រើប័ណ្ណ) |
| **ការធ្វើចំណាត់ថ្នាក់ប្រភេទ** | ១. នាម កិរិយាស័ព្ទ គុណនាម ធ្នាក់នៃពេលវេលា (ប្រើប័ណ្ណ)<br>២. ពាក្យដែលចាប់ផ្តើមដោយក្រុមព្យញ្ជនៈពីរខុសគ្នា (ប្រើប័ណ្ណ)<br>៣. ប្រភេទអាហារខុស១គ្នា (បន្លែ ផ្លែឈើ សាច់ បាយ) (ប្រើក្តារឆ្នួន)<br>៥. ពាក្យទៅតាមប្រភេទអត្ថន័យ (ឧ. សត្វល្អិត និងត្រី) |

**សេចក្តីសន្និដ្ឋានៈ** អ្នកសម្របសម្រួលអោយសិក្ខាកាមគិតពីរបៀប ថាតើល្បែងភាសាខ្មែរនិងគណិតវិទ្យាដែលពួកគេបានឃើញនៅក្នុងដំណាក់កាលបង្រៀនទាំងពីរនេះអាចផ្សាភ្ជាប់ទៅនឹងសៀវភៅសិក្សាក្រសួងអប់រំឬទេ? ។ សិក្ខាកាមផ្តល់ចំលើយ...**ចំលើយរំពឹងទុកៈ** ប្រើប្រាស់អត្ថបទនៅក្នុងសៀវភៅភាសាខ្មែរសំរាប់យកមកកាត់ជាពាក្យនិងប្រយោគ ជ្រើសរើសពាក្យលំបាកនិងសរសេរនិយមន័យនៅលើប័ណ្ណហើយច្របល់ចូលគ្នា លេងល្បែងគណិតវិទ្យាដើម្បីសិក្សាអំពីប្រព័ន្ធចំនួន តំលៃលេខ រង្វាស់ ធរណីមាត្រដោយប្រើប្រាស់ខ្លឹមសារនៅក្នុងសៀវភៅសិក្សា... ។

## ថ្ងៃទី៩ ភាពជាគ្រូបង្រៀន_គុណភាព តួនាទី ការទទួលខុសត្រូវ

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី១: តើអ្វីទៅដែលធ្វើអោយក្លាយជាគ្រូបង្រៀនល្អ?** ៤៥ នាទី

**កិច្ចការ:** អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមតូចៗ។ សិក្ខាកាមនីមួយៗទទួលបានក្រដាស២ចំណែក។ អ្នកសម្របសម្រួលប្រាប់អោយពួកគេបិទភ្នែកដើម្បីគិតអំពីគ្រូដែលបានបង្រៀនពួកគេនៅសាលាដែលពួកគេចូលចិត្ត។ បន្ទាប់ពីរយៈពេល១នាទី អ្នកសម្របសម្រួលអោយពួកគេបើកភ្នែកហើយអោយបំពេញប្រយោគដាក់លើក្រដាសចំណែកនោះដែលចាប់ផ្តើមដោយ "ខ្ញុំចូលចិត្តគ្រូរបស់ខ្ញុំពីព្រោះ..."ដោយសរសេរចំលើយ២ ចំលើយមួយនៅលើក្រដាសមួយចំណែក។ បន្ទាប់ពីរយៈពេល៣នាទី អ្នកសម្របសម្រួលជួយសិក្ខាកាមប្រមូលចំណែកក្រដាសនោះហើយបិទទៅលើផ្ទាំងក្រដាសធំដោយដាក់ចំលើយដែលដូចគ្នានៅផ្នែកខាងលើបន្តរៀងមក។

បន្ទាប់មកសិក្ខាកាមអនុវត្តសកម្មភាពដូចខាងលើដែរ តែសរសេរអំពីគ្រូដែលពួកគេមិនចូលចិត្តដោយដាក់លើក្រដាសធំមួយផ្សេងទៀត។

នៅពេលសរសេរចប់ ក្រុមតូចទាំងអស់បិទក្រដាសធំនៃចំលើយនោះទៅលើក្តារខៀនដើម្បីអោយក្រុមផ្សេងទៀតពិនិត្យមើល។ អ្នកសម្របសម្រួលអោយក្រុមមួយរាយការណ៍ ហើយក្រុមផ្សេងទៀតបន្ថែមតែចំនុចឬចំលើយដែលខុសគ្នាប៉ុណ្ណោះ។

អ្នកសម្របសម្រួលនិងសិក្ខាកាមត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រៀបធៀបប្រវត្តិទាំងពីរ។ **អ្នកសម្របសម្រួលសួរថា:** ***តើលោក/លោកស្រីអាចធ្វើចំណាត់ទៅលើចំលើយនោះបានឬទេ?***

***ចំលើយអាចជា:*** *ចំលើយមួយចំនួនសំដៅលើបុគ្គលិកលក្ខណៈរបស់គ្រូ មួយចំនួនបង្ហាញតួនាទីគ្រប់គ្រងរបស់គ្រូ និងមួយចំនួនទៀតបង្ហាញបំនិនក្នុងការបង្រៀន...។*

សេចក្តីសន្និដ្ឋានៈ អ្នកសម្របសម្រួលនិយាយថាកុមារមិនងាយនឹងភ្លេចអំពីគ្រូល្អឬគ្រូមិនល្អឡើយ។ គ្រូបង្រៀនបានធ្វើអោយមានចំណាប់អារម្មណ៍រយៈពេលយូរណាស់ទៅលើចិត្តរបស់កុមារ។

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី២: គំនិតអំពីបរិស្ថានសាលាកុមារមេត្រីនិងសិទ្ធិកុមារ** **៦០ នាទី**

**២.១ សាលាកុមារមេត្រី**

អ្នកសម្របសម្រួលនិយាយថា: នៅក្នុងដំណាក់កាលចុងក្រោយនេះ អ្នកបានពិពណ៌នាអំពីគុណភាពជាច្រើនរបស់គ្រូបង្រៀន។ អ្នកសម្របសម្រួលសួរក្រុមទាំងមូល: **ហេតុអ្វីក៏លោក/លោកស្រីគិតថាវាជាការសំខាន់ដែលគ្រូត្រូវព្យាយាមសំដែងតាមរបៀបនេះ?**

***ចំលើយអាចជា:*** *ដើម្បីធ្វើអោយកុមារចង់មកសាលារៀន ដើម្បីធ្វើអោយកុមារសប្បាយក្នុងការសិក្សា ដើម្បីកុំអោយកុមារខ្លាចគ្រូបង្រៀន កុមារមានភាពជឿជាក់លើគ្រូបង្រៀន ធ្វើអោយកុមារមានអារម្មណ៍សុវត្ថិភាព និងសប្បាយរីករាយដែលនាំអោយពួកគេកាន់តែរៀនបានពូកែ។*

អ្នកសម្របសម្រួល ទទួលស្គាល់គំនិតរបស់សិក្ខាកាម ហើយនិយាយថាចំលើយរបស់លោក/លោកស្រីបានបង្ហាញនូវគំនិតមួយដែលក្រសួងអប់រំបានអោយឈ្មោះថា "សាលាកុមារមេត្រី"។ អ្នកសម្របសម្រួលនិយាយថាក្រសួងអប់រំបានចែកគំនិតនៃសាលាកុមារមេត្រីជា៦ផ្នែក (6 dimensions)។ អ្នកសម្របសម្រួលសួរសំនួរដើម្បីទាញយកព័ត៌មានអំពីផ្នែកទាំង៦ (ដោយពុំមានកំណត់ឈ្មោះផ្នែកទាំងនោះទេ)។ សហអ្នកសម្របសម្រួលកត់ត្រាចំលើយរបស់សិក្ខាកាម។ នៅពេលព័ត៌មានត្រូវទទួលបានច្រើនហើយ អ្នកសម្របសម្រួលសួរសិក្ខាកាមអោយគិតអំពីឈ្មោះនៃផ្នែកនីមួយៗ។

អ្នកសម្របសម្រួលបង្ហាញដ្យាក្រាមនៃផ្នែកទាំង៦នៅលើក្តារខៀនហើយនិយាយពន្យល់អំពីផ្នែកទាំងនោះ។ បន្ទាប់មកសិក្ខាកាមធ្វើកិច្ចការខាងក្រោមដើម្បីបង្កើនការយល់ដឹងថែមទៀត។

**កិច្ចការ: លំហាត់ផ្គូរផ្គង**

អ្នកសម្របសម្រួលចែកចំណិតប្រយោគដែលបានបង្ហាញនៅក្នុងឯកសារទៅអោយសិក្ខាកាម។ ចំណិតក្រដាសនីមួយៗមានប្រយោគតែពាក់កណ្តាល។ សិក្ខាកាមត្រូវបង្កើតប្រយោគពេញលេញដោយប្រើចំណិតក្រដាសដោយអោយពួកគេដើរស្វែងរកចំណិតពាក់កណ្តាលទៀតពីសិក្ខាកាមផ្សេងៗ។ នៅពេលពួកគេបានផ្គូរផ្គងរួចហើយ ពួកគេគួរតែពិភាក្សាជាមួយដៃគូលើអត្ថន័យរបស់ប្រយោគនោះ តើប្រយោគនេះនាំអោយមានការសិក្សាបានល្អប្រសើរដោយរបៀបណា ហើយតើប្រយោគនេះស្ថិតនៅក្នុង dimensions ទីប៉ុន្មាន?។

សិក្ខាកាមគួរតែបង្ហាញប្រយោគពេញលេញរបស់គេទៅកាន់ក្រុមទាំងអស់ ហើយនឹងបង្ហាញថាប្រយោគនេះស្ថិតនៅក្នុង dimensions ទីប៉ុន្មាន? ។ នៅពេលចប់សកម្មភាពនេះអ្នកសម្របសម្រួលផ្តល់ឯកសារអោយសិក្ខាកាមដែលមានការបរិយាយខ្លីៗអំពី dimensions ទាំង៦នៃសាលាកុមារមេត្រីនិងប្រយោគពេញលេញ (**ឯកសារទី២៩**) ។

បន្ទាប់មកអ្នកសម្របសម្រួលចែកឯកសារអានអំពីសាលាកុមារមេត្រី (**ឯកសារទី៣០**) មើលសេចក្តីសង្ខេបខាងក្រោមដែលសិក្ខាកាមត្រូវអាននិងពិភាក្សាជាមួយអ្នកអង្គុយក្បែរ ។ បន្ទាប់ពីអានចប់សិក្ខាកាមសួរសំនួរដើម្បីអោយដឹងថាសិក្ខាកាមបានយល់ឯកសារ ។

សេចក្តីសង្ខេបខ្លឹមសារអំពីអំនានសាលាកុមារមេត្រី-ចូរប្រើសំនួរដើម្បីជំរុញការគិតអំពីផ្នែកនីមួយៗ

<u>Dimension1:</u> ហេតុអ្វីបានជាកុមារដែលនៅក្នុងភូមិហាក់ដូចជារៀនអ្វីៗដោយខ្លួនឯងបានប្រសើរទោះបីជាគ្មានគ្រូបង្រៀន? (ចំលើយ: ការរៀនមានលក្ខណ:សប្បាយ ការរៀនមិនមានលក្ខណ:ផ្លូវការ កុមាររៀនអ្វីៗដែលពួកគេចូលចិត្ត ។ល ។

<u>Dimension2:</u> ហេតុអ្វីកុមារមិនបានចូលសាលារៀន? (ចំលើយ:ពីព្រោះពួកគេក្រីក្រហើយមិនអាចទិញសម្ភារចាំបាច់សំរាប់ការសិក្សាបាន ពីព្រោះពួកគេមិនចេះភាសាដែលប្រើនៅក្នុងសាលារៀន ពីព្រោះពួកគេមានភាពពិការទៅលើផ្នែកណាមួយ) ។

<u>Dimension3:</u> តើសាលារៀនដែលមានបរិស្ថានល្អអាចជួយដល់កាសិក្សារបស់កុមារយ៉ាងដូចម្តេចខ្លះ? (ចំលើយ:កុមារមិនឃ្លានដូច្នេះពួកគេអាចផ្តោតអារម្មណ៍ទៅលើការសិក្សាបានច្រើន កុមារមានអារម្មណ៍សប្បាយរីករាយនៅក្នុងសាលារៀន ហើយមិនមានអារម្មណ៍គំរាមកំហែងពីសិស្សផ្សេងៗទៀត ។ល ។

<u>Dimension4:</u> តើសាលារៀនត្រូវមានលក្ខណ:យេនឌ័រយ៉ាងដូចម្តេច? (ចំលើយ: គ្រូបង្រៀនមិនត្រូវរើសអើងរវាងសិស្សស្រី និងសិស្សប្រុសនៅពេលសួរសំនួរ ត្រូវមានការបង្ហាញគំរូល្អរវាងសិស្សស្រី និងសិស្សប្រុសនៅក្នុងសាលាកុមារមិនត្រូវមានការរើសអើងចំពោះគ្នាទៅវិញទៅមកលើចរិកលក្ខណ:ភេទ ឧទាហរណ៍ ដូចជាការប្រើប្រាស់បង្គន់អនាម័យ ។ល ។

<u>Dimension5:</u> តើសាលារៀនអាចមានប្រសិទ្ធភាពយ៉ាងណាបើសិនជាឪពុកម្តាយរបស់សិស្សចូលរួមនៅក្នុងការអប់រំ? (ចំលើយ: ការសិក្សាត្រូវបានជួយជំរុញនៅផ្ទះ បើសិនជាសាលារៀនផ្តល់នូវព័ត៌មានដែលទាក់ទងនឹងការសិក្សាបានច្រើន ឪពុកម្តាយរបស់សិស្សនឹងអាចជួយជំរុញកូនៗរបស់គេមកសាលារៀនបានទៀងទាត់ ។ល ។)

<u>Dimension6:</u> ការគាំទ្រកម្មវិធីពីប្រព័ន្ធគ្រប់គ្រងអប់រំ

## ២.២ សិទ្ធិកុមារ

អ្នកសម្របសម្រួលនិយាយថា ទស្សនៈវិទ្យានៃសាលាកុមារមេត្រីគឺមួយផ្នែកផ្អែកលើអនុសញ្ញាស្តីពីសិទ្ធិកុមារ

គ្រូបង្រៀនទាំងអស់គួរតែដឹងថាប្រទេសកម្ពុជាបានចុះហត្ថលេខា លើអនុសញ្ញា អន្តរជាតិស្តីពីសិទ្ធិកុមារ។ អនុសញ្ញានៃសិទ្ធិកុមារបង្ហាញពីអ្វីៗដែលកុមារអាចធ្វើបាននិងអំពីអ្វីដែលមនុស្សពេញវ័យ មិនអាចរំលោភបានទៅលើពួកគេផងដែរ។

អ្នកសម្របសម្រួលបង្ហាញដ្យាក្រាម/ផ្ទាំងក្រដាសធំអំពីប្រភេទសំខាន់ៗ៤នៃសិទ្ធិកុមារ ហើយអានជាមួយសិក្ខាកាម។ បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមតូចៗ ហើយក្រុមនីមួយៗទទួលបានប្រភេទសិទ្ធិមួយដើម្បីពិភាក្សានិងសរសេរឧទាហរណ៍មួយចំនួនចំពោះប្រភេទសិទ្ធិនីមួយៗ។ ក្រុមនីមួយៗនឹងទទួលបានរូបភាពចំនួន៤ដើម្បីជួយអោយពួកគេពិពណ៌នាឧទាហរណ៍របស់ពួកគេជាមួយនឹងរូបភាពនោះដែលបាំងដោយស្កុត។ ក្រុមនីមួយៗគួរតែរៀបចំតារាងដាក់លើផ្ទាំងក្រដាសរ៉ាមធំ ដែលមានប្រភេទសិទ្ធិជាចំណងជើងនៅផ្នែកខាងលើ និងចំនុចចំនួន៤សំរាប់សរសេរឧទាហរណ៍ដែលបានបង្ហាញនៅក្នុងរូបភាពនៅពីខាងក្រោមចំណងជើងនោះ។

បន្ទាប់មកសិក្ខាកាមបិទក្រដាសរ៉ាមធំទាំង៤នៅខាងមុខថ្នាក់ដោយអានចំលើយតបនិងបង្ហាញរូបភាព។ បើសិនការបកស្រាយរបស់ពួកគេមានលក្ខណៈខុសពីរូបភាពពេក អ្នកសម្របសម្រួលអាចសួរទៅសិក្ខាកាមផ្សេងទៀតដើម្បីសុំយោបល់ និងបន្ទាប់មកបង្ហាញរូបភាពដោយបកស្កុតចេញ។

នៅពេលចប់សកម្មភាព អ្នកសម្របសម្រួលផ្តល់ឯកសារទៅអោយសិក្ខាកាម(**ឯកសារទី៣០**) ដែលមានដ្យាក្រាមប្រភេទសិទ្ធិទាំង៤ដាក់នៅផ្នែកម្ខាងនិងឧទាហរណ៍នៅពីក្រោមប្រភេទសិទ្ធិនោះនៅផ្នែកខាងក្រោយ។

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៣: គ្រូត្រូវធ្វើជាគំរូរដ៏ល្អ** **៣០ នាទី**

អ្នកសម្របសម្រួលរំលឹកសិក្ខាកាមថា កុមារតូចៗបានដឹងអ្វីៗច្រើនបំផុតពីឪពុកម្តាយ បងប្អូនបង្កើត និងសមាជិកគ្រួសារផ្សេងៗទៀត។ នៅក្នុងភាសាអង់គ្លេសគេប្រើពាក្យ " គំរូ" ដើម្បីពិពណ៌នាជាក៏រិតសារៈសំខាន់មួយ។ អ្នកសម្របសម្រួលសួរថា: **នៅក្នុងថ្នាក់រៀន តើលោក/លោកស្រីគិតថានរណាជាគំរូដ៏សំខាន់?** ***ចំលើយរំពឹងទុក: គឺគ្រូបង្រៀន***។ អ្នកសម្របសម្រួលយល់ស្របហើយនិយាយថាគ្រូបង្រៀន គឺមានឥទ្ធិពលណាស់សំរាប់ធ្វើជាគំរូទាំងផ្នែកឥរិយាបថនិងអាកប្បកិរិយាដែលកុមារត្រូវរៀនសូត្រតាម។

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមបំពេញនៅក្នុងចន្លោះទំនេរនៅក្នុងតារាង (**ឯកសារទី៣១**) ដែលជ្រើស

រើសពីចំលើយដែលអាចត្រឹមត្រូវ។ តារាងបង្ហាញនូវឥរិយាបថល្អៗជាច្រើន ហើយនឹងមានចន្លោះទំនេរសំរាប់ឧទាហរណ៏អំពីអាកប្បកិរិយាវិជ្ជមាននិងអវិជ្ជមានដែលគ្រូសំដែងឡើង។ កិច្ចការដែលត្រូវធ្វើគឺជ្រើសរើសឧទារណ៏នៃអាកប្ប-កិរិយាវិជ្ជមាននិងអវិជ្ជមាននោះអោយបានសមស្របទៅបំពេញនៅក្នុងតារាងនីមួយៗ (ចំលើយរំពឹងទុកត្រូវបានសរសេរនៅក្នុងតារាងខាងក្រោម)។

| ឥរិយាបថល្អ | គ្រូជាគំរូ<br>វិជ្ជមាន | គ្រូជាគំរូ<br>អវិជ្ជមាន |
|---|---|---|
| យកចិត្តទុកដាក់ធ្វើការបានល្អ | *គ្រូសរសេរបានច្បាស់និងស្អាតនៅលើក្តារខៀន* | *គ្រូសរសេរដោយមិនយកចិត្តទុកដាក់* |
| ទៀងទាត់ពេលវេលា | *គ្រូជានិច្ចកាលមកបង្រៀនទៀងទាត់ពេលវេលា* | *ជួនកាលគ្រូមកធ្វើការយឺតពេលវេលា* |
| សុភាពរាបសារ និងសំដែងការគោរពចំពោះអ្នកដទៃ | *គ្រូរួសរាយរាក់ទាក់ និងសុភាពរាបសារ* | *គ្រូប្រើប្រាស់ភាសាមិនសមរម្យ* |
| គ្រប់គ្នា ត្រូវចេះជួយថែរក្សាបរិស្ថានអោយបានល្អស្អាត | *គ្រូជានិច្ចកាលប្រើប្រាស់ធុងសំរាម* | *គ្រូបោះក្រដាស់ឬថង់ប្លាស្ទិចនៅលើដី* |
| សុខភាពល្អគឺមានន័យថាមិនជក់បារី | *គ្រូមិនដែលជក់បារីនៅក្នុងថ្នាក់* | *គ្រូជក់បារីនៅក្បែរឬនៅក្នុងថ្នាក់* |
| មិនប្រើហិង្សាដើម្បីដោះស្រាយបញ្ហា | *គ្រូមិនដែលវាយដំកុមារ* | *គ្រូប្រើរំពាត់ឬដៃវាយកុមារ* |
| កុមារអាចរៀននៅក្នុង និងក្រៅសាលារៀន | *គ្រូដាក់កិច្ចការអោយសិស្សធ្វើនៅផ្ទះ* | *គ្រូមិនដែលដាក់កិច្ចការអោយសិស្សធ្វើនៅផ្ទះ* |
| ប្រព្រឹត្តដោយយុត្តិធម៌ ទៅលើសិស្សគ្រប់គ្នា | *គ្រូជានិច្ចកាលអោយសិស្សរួមគ្នាធ្វើកិច្ចការ* | *គ្រូហៅសិស្សតែមួយចំនួនអោយធ្វើការងារមិនល្អ/គ្រខ្វក់* |
| ទទួលស្គាល់ការខំប្រឹងប្រែង, ទោះបីជាមានកំហុស, ធ្វើអោយអ្នកផ្សេងៗមាន អារម្មណ៏ល្អ | *គ្រូនិយាយពាក្យអរគុណដល់កុមារចំពោះចំលើយរបស់គេទោះបីចំលើយខុសក៏ដោយ* | *គ្រូរិះគន់ឬចំអកចំពោះកុមារដែលឆ្លើយខុស* |
| បង្ហាញការទទួលខុសត្រូវលើអាជីពរបស់ខ្លួន | *គ្រូជានិច្ចកាលនៅជាមួយសិស្សក្នុងកំឡុងពេលបង្រៀន* | *គ្រូដើរទៅខាងក្រៅនៅពេលសិស្សធ្វើកិច្ចការឬតេស្ត* |

អ្នកសម្របសម្រួលសរុបបញ្ចប់ដោយនិយាយថា គ្រូបង្រៀនជានិច្ចកាលគួរតែដឹងអំពីឥទ្ធិពលដែលពួកគេមានទៅលើសិស្សដែលជាគំរូដ៏ល្អមួយ ដូច្នោះត្រូវគិតអំពីសកម្មភាពរបស់ខ្លួន ហើយព្យាយាមយល់ពីអារម្មណ៍របស់សិស្ស (ដាក់ខ្លួនយើងទៅក្នុងស្ថានភាពជាសិស្ស) ។

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៤: អ្នករៀនគឺមានភាពខុសៗគ្នា: ការប្រើប្រាស់វិធីច្រើនប្រភេទ ៤៥ នាទី**

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូល: **តើមានមធ្យោបាយអ្វីខ្លះសំរាប់រៀបចំអោយសិស្សធ្វើការដែលគ្រូបង្រៀនប្រើនៅក្នុងថ្នាក់រៀន?** អ្នកសហសម្របសម្រួលសរសេរគំនិតរបស់សិក្ខាកាមដាក់លើក្តារខៀន។

***ចំលើយរំពឹងទុក:*** *ជាលក្ខណ:បុគ្គល ការសួរនិងឆ្លើយសំនួរជាដៃគូ ជាក្រុមតូច និងជាថ្នាក់ទាំងមូល ។*

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូល: **តើប្រភេទសកម្មភាពសិក្សាចំបងៗមួយចំនួនដែលកុមារអាចធ្វើបានមានអ្វីខ្លះ?** អ្នកសហ សម្របសម្រួលសរសេរចំលើយរបស់សិក្ខាកាមដាក់លើក្តារខៀន ។

***ចំលើយរំពឹងទុក:*** *ការស្តាប់គ្រូ ការពិភាក្សា ការសរសេរ ការគូរ ការអាន ការបង្កើតអ្វីមួយ ការដោះស្រាយប្រស្នា ការលេងល្បែង ការធ្វើលំហាត់ (ផលបូក) ការឆ្លើយសំនួរដោយនិយាយ ការឆ្លើយសំនួរដោយសរសេរ ការពន្យល់អ្វីមួយ ការបង្ហាញកិច្ចការមួយចំនួន ។*

អ្នកសម្របសម្រួលនិយាយថា គាត់បានរៀបចំបញ្ជី(**ឯកសារទី៣២**) នៃការកំណត់ក្រុមចំនួន១០ប្រភេទនិងសកម្មភាពរៀន១០ប្រភេទទៀត ហើយអោយសិក្ខាកាមធ្វើការជាលក្ខណ:បុគ្គលដើម្បីធ្វើចំណាត់ថ្នាក់ទៅតាមសកម្មភាពដែលចូលចិត្តបំផុត (ដាក់លេខ១) ទៅសកម្មភាពដែលមិនចូលចិត្តបំផុត (ដាក់លេខ១០) ។ នៅពេលសិក្ខាកាមបានបញ្ចប់ពួកគេអាច ក្រោកឈរឡើង ហើយដើរស្វែងរកអ្នកដែលបានចប់ដែរនោះដើម្បីធ្វើការប្រៀបធៀបគ្នា ។

បន្ទាប់មកអ្នកសម្របសម្រួលសួរទៅសិក្ខាកាមមួយគូៗនៅសំនួរខាងក្រោម...

**តើមនុស្សគ្រប់គ្នាចូលចិត្តប្រភេទនៃការរៀបចំ និងសកម្មភាពដូចៗគ្នាឬទេ?**

***ចំលើយរំពឹងទុក:*** *ចំលើយភាគច្រើនគឺ ទេ តែមានភាពស្រដៀងខ្លះ ។*

អ្នកសម្របសម្រួលសួរថា: **តើគ្រូបង្រៀនគួរតែបានដឹងអ្វីខ្លះពីលទ្ធផលនៃសកម្មភាពនេះ?**

***ចំលើយរំពឹងទុក:*** *គ្រូបង្រៀនគួរតែប្រើវិធីសាស្ត្រ សកម្មភាពបង្រៀន និងរៀនអោយបានច្រើនប្រភេទ ។*

បន្ទាប់មកអ្នកសម្របសម្រួលសួរថ្នាក់ទាំងមូលៈ **តើលោក/លោកស្រីគិតថាមានអ្វីខ្លះកើតឡើងនៅក្នុងសាលាភាគច្រើនបំផុតនៅប្រទេសកម្ពុជា?**
***ចំលើយរំពឹងទុកៈ*** *មិនមានការប្រើប្រាស់វិធីអោយបានច្រើនប្រភេទ សកម្មភាពភាគច្រើនគឺដូចគ្នា សិស្សស្តាប់តែគ្រូ សិស្សគិតតែពីចំលង សិស្សធ្វើលំហាត់ពីសៀវភៅឬពីក្តារខៀន។*

អ្នកសម្របសម្រួលសរុបបញ្ចប់ដោយបញ្ជាក់ថាការប្រើប្រាស់បច្ចេកទេស វិធីអោយបានច្រើននៅក្នុងថ្នាក់រៀនគឺសំខាន់ណាស់ពីព្រោះតាមរយៈការធ្វើបែបនេះវាអាចតម្រូវទៅតាមប្រភេទនៃការសិក្សារបស់កុមារបានគ្រប់គ្នា និងថែមទាំងរក្សាបាននូវចំណាប់អារម្មណ៍ពីកុមារទៀតផង។

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៥ៈ ការគ្រប់គ្រងថ្នាក់រៀន ក្បួនច្បាប់ វិន័យ ការសរសើរ ការស្តីបន្ទោស ៣០ នាទី**

អ្នកសម្របសម្រួលនិយាយទៅកាន់ថ្នាក់ទាំងមូលៈ ចំណែកនៃការទទួលខុសត្រូវរបស់គ្រូបង្រៀនគឺត្រូវរក្សាសុវត្ថិភាព មេត្រីភាពនិងបង្កើតនូវបរិស្ថានល្អក្នុងការបង្រៀនកុមារនិងមានក្បួនច្បាប់វិន័យក្នុងការបង្រៀន-រៀន។ សាលាភាគច្រើនបំផុតមានក្បួនច្បាប់នេះខ្លះហើយដែលនិយាយអំពីការប្រព្រឹត្តរបស់កុមារនៅក្នុងថ្នាក់ ទោះបីជាមិនមានការសរសេរជាលាយល័ក្ខអក្សរក៏ដោយ។ តើលោក/ លោកស្រីគិតថាអាចមានច្បាប់វិន័យអ្វីខ្លះទៅ?
***ចំលើយរំពឹងទុកៈ*** *កុមារមិនត្រូវស្រែកឡូឡា កុមារមិនត្រូវវាយគ្នា...*

អ្នកសម្របសម្រួលនិយាយទៅកាន់ថ្នាក់ទាំងមូលៈ ជាបន្ថែម មានក្បួនច្បាប់មួយចំនួនដែលគ្រូបង្កើតនិងជួនកាលបង្កើតដោយគ្រូនិងសិស្សរួមគ្នាអំពីអ្វីដែលគេត្រូវធ្វើសំរាប់ថ្ងៃនីមួយៗ និងអាកប្បកិរិយាដែលត្រូវសំដែងចំពោះគ្នាទៅវិញទៅមក។ តើលោក/លោកស្រីអាចផ្តល់ជាឧទាហរណ៍ខ្លះបានទេ?
***ចំលើយរំពឹងទុកៈ*** *កុមារមិនត្រូវហូប ឬផឹកអ្វីនៅក្នុងថ្នាក់រៀនទេ កុមារត្រូវចែករួមចំណែកគ្នានូវរាល់សម្ភារដែលមិនគ្រប់គ្រាន់សំរាប់ទាំងអស់គ្នា (ឧ. សៀវភៅសិក្សា) កុមារត្រូវសុំការអនុញ្ញាតពីគ្រូសិនបើសិនជាគេចង់ទៅបង្គន់។*

អ្នកសម្របសម្រួលនិយាយថាទៅកាន់ថ្នាក់ទាំងមូលៈ វាមិនមែនអ្វីៗទាំងអស់សុទ្ធតែគ្រូជាអ្នកទទួលខុសត្រូវលើសិស្សគ្រប់យ៉ាងទាំងអស់នោះទេ។ តួនាទីរបស់សិស្សក៏សំខាន់ណាស់ដែរ។ តើលោក/លោកស្រីអាចផ្តល់ជាឧទាហរណ៍ខ្លះនូវអ្វីដែលសិស្សអាចធ្វើបានឬទេ?

*ចំលើយរំពឹងទុក: ក្រុមសិស្សដែលទទួលខុសត្រូវលើកិច្ចការ ក្រុមសិស្សដែលធ្វើស្វ័យគ្រប់គ្រងខ្លួនឯង ក្រុមសិស្សដែលត្រូវមានភាពសកម្មនៅក្នុងសកម្មភាពបង្រៀនបែបសិស្សមជ្ឈមណ្ឌល ក្រុមសិស្សដែលសកម្មក្នុងការជួយគ្រូ និងសិស្សផ្សេងៗទៀត តាមរយៈសកម្មភាពសិស្សជួយសិស្ស ។*

នៅពេលចប់ដំណាក់កាលបង្រៀន អ្នកសម្របសម្រួលអោយឯកសារអំនានខ្លីមួយទៅសិក្ខាកាមដែលដកស្រង់ពីឯកសារ TGL មានឈ្មោះថា" ការដោះស្រាយចំលើយខុស" (**ឯកសារទី៣៣**)

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៦: ការរៀបចំថ្នាក់រៀនសំរាប់ការសិក្សាបែបកុមារមជ្ឈមណ្ឌល ៤៥ នាទី**

អ្នកសម្របសម្រួលរៀបចំសិក្ខាកាម ជាក្រុមតូចហើយផ្តល់អោយក្រុមនិមួយៗនូវរូបថត២សន្លឹក (**ឯកសារទី៣៤**)។ រូបថតមួយមានបន្ទប់រៀនរៀបចំបានល្អ ជាបន្ទប់កុមារមេត្រី (ឧ. សាលាបឋមសិក្សាព្រៃទទឹង) ហើយរូបថតមួយទៀតជាបន្ទប់រៀនដែលគួរអោយធុញទ្រាន់ (ដែលមានអ្វីៗនៅលើជញ្ជាំងតិចតួច គ្មានខ្សែរ និងអ្វីៗសំរាប់ព្យួរ កៅអីនិងតុត្រូវបានគេរៀបជាជួរ គ្រូអង្គុយនៅខាងមុខ...)។ អ្នកសម្របសម្រួលអោយសិក្ខាកាមវិភាគបន្ទប់រៀនទាំងពីរ ដោយនិយាយថាតើបន្ទប់រៀនមួយណាមានបរិស្ថានគួរអោយចាប់អារម្មណ៍ជាង រួចហើយសរសេរចរិកលក្ខណៈនៃបន្ទប់រៀននោះទៅក្នុងតារាងខាងក្រោម ។

| **រូបថតបន្ទប់ទី១** | **រូបថតបន្ទប់ទី២** |
|---|---|
| *ឧទាហរណ៍នៃចំលើយ* | *ឧទាហរណ៍នៃចំលើយ* |
| *មានរូបភាពច្រើននៅលើជញ្ជាំង* | *គ្មានអ្វីនៅលើជញ្ជាំង* |
| *រូបភាពព្យួរនៅលើខ្សែ* | *តុសិស្សស្ថិតនៅជាជួរ* |
| *តុរៀបចំសំរាប់ការងារជាក្រុម* | *គ្រូឈរនៅខាងមុខសិស្សទាំងអស់ក្នុងថ្នាក់* |
| *មានធ្នើនិងបណ្ណាល័យសំរាប់ដាក់សៀវភៅ* | *គ្មានគៀនបណ្ណាល័យ ឬកន្លែងផ្សេងៗទៀត* |
| *មានរាំងននៅលើបង្អួច* | |
| *គ្រូបង្រៀនកំពុងធ្វើការជាមួយក្រុមសិស្ស* | |

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៧: កិច្ចការរដ្ឋបាលរបស់គ្រូបង្រៀននៅសាលារដ្ឋ ៩០ នាទី**

**សេចក្តីផ្តើម** (១០ នាទី)

អ្នកសម្របសម្រួលនិយាយបន្តទៀតថាៈ ថ្នាក់នៅសាលាបឋមសិក្សានីមួយៗមានគ្រូម្នាក់ដែលតែងតាំងដោយនាយកសាលា ហើយគ្រូបង្រៀននេះទទួលខុសត្រូវលើការបង្រៀនគ្រប់មុខវិជ្ជាទាំងអស់(ដូចយើងបានដឹងរួចហើយនៅក្នុងវគ្គបណ្តុះបណ្តាលនេះ)។ ភារកិច្ចសំខាន់របស់គ្រូបង្រៀនគឺជួយកុមារអោយរៀនប្រកបដោយប្រសិទ្ធភាពពីព្រោះវាគឺជាការងារស្នូលរបស់សាលារៀន។ថ្នាក់នីមួយៗមានកម្មវិធីសិក្សាពីក្រសួងអប់រំសំរាប់ឆ្នាំសិក្សានីមួយៗ ហើយដែលមានការរៀបចំទៅតាមឆមាស ខែ មុខវិជ្ជា និងម៉ោងសិក្សាដែលគ្រូបង្រៀនត្រូវអនុវត្តតាម។ ក្រសួងក៏បានផ្តល់នូវសេចក្តីណែនាំអំពីវិធីសាស្ត្របង្រៀន វត្ថុបំណងមេរៀន និងលំហាត់សំរាប់កុមារអនុវត្តផងដែរ។

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនក៏ត្រូវគ្រប់គ្រងសិស្សប្រមាណ៤០ឬ៥០នាក់នៅក្នុងថ្នាក់ផងដែរ ដែលពួកគេទាំងអស់មានបុគ្គលិកលក្ខណៈ សមត្ថភាព ចំណង់ចំណូលចិត្ត និងមកពីស្ថានភាពគ្រួសារខុសៗគ្នា។ ចំពោះការគ្រប់គ្រងថ្នាក់គឺគ្រូបង្រៀនត្រូវធានាថា ថ្នាក់រៀនមានភាពស្អាត និងគួរអោយចាប់អារម្មណ៍ ហើយអាកប្បកិរិយារបស់សិស្សសំដែងឡើងក្រុបដោយសីលធម៌ល្អ ដូចជាការគោរពចំពោះគ្រូបង្រៀន និងមិត្តភ័ក្រ ក្រុមការងារ ការចូលរួមយ៉ាងសកម្មការផ្តល់ជាគំនិតយោបល់ ការធ្វើការដោយការប្រុងប្រយ័ត្នជាដើម។

អ្នកសម្របសម្រួលនិយាយថាៈ គ្រូបង្រៀនក៏មានកិច្ចការខាងរដ្ឋបាលជាច្រើនទៀតដែលត្រូវធ្វើ ហើយលោក/លោកស្រីនឹងបានឃើញនៅក្នុងដំណាក់កាលបង្រៀននាពេលនេះ។ អ្នកសម្របសម្រួលចែកឯកសារមួយចំនួនដែលគ្រូទទួលបន្ទុកថ្នាក់ប្រើប្រាស់សំរាប់ការងាររដ្ឋបាលនេះ (**ឯកសារទី៣៥ និង៣៦**)។ អ្នកសម្របសម្រួលលើកបង្ហាញឯកសារម្តងមួយៗហើយនិយាយប្រាប់ឈ្មោះនៃសៀវភៅ/ឯកសារនីមួយៗនោះ...

១. **បញ្ជីហៅឈ្មោះ** ទំហំ A3-សំណៅថតចំលងទំព័រមុខ (បង្ហាញសៀវភៅជាក់ស្តែងនៅក្នុងសិក្ខាសាលា)
២. **បញ្ជីអវត្តមាន** ទំហំ A3 - សំណៅថតចំលងទំព័រមុខ (បង្ហាញសៀវភៅជាក់ស្តែងនៅក្នុងសិក្ខាសាលា)
៣. **សៀវភៅសិក្ខាគារិក** -សិស្សម្នាក់ៗចាប់ពីថ្នាក់ទី៤ ទៅត្រូវមានសៀវភៅមួយនេះដែលគេរក្សាទុកនៅក្នុងសាលារៀន (ចែកជូនសៀវភៅជាក់ស្តែង)
៤. **សៀវភៅតាមដានការសិក្សា**-ក្នុង១ឆ្នាំសិក្សាសិស្សម្នាក់ៗត្រូវមានសៀវភៅនេះ ដែលគ្រូសរសេរព័តិមានការសិក្សាសំរាប់ផ្ញើទៅកាន់ឪពុកម្តាយរបស់សិស្សជារៀងរាល់ខែ។ (ចែកជូនសៀវភៅជាក់ស្តែង)
៥. **សៀវភៅវេន**-សៀវភៅនេះត្រូវបានផ្តល់ទៅអោយសិស្សផ្សេងៗគ្នា ជារៀងរាល់ថ្ងៃដើម្បីកត់ត្រាមេរៀនចំណងជើងមេរៀន ប្រធានបទឬសិស្សធ្វើលំហាត់ដាក់ក្នុងសៀវភៅនោះ...(បង្ហាញសំណៅថតចំលងទំព័រមុខ

និងឧទាហរណ៍ពីរបៀបសរសេរ)

៦. **សៀវភៅចូលមើលម៉ោងបង្រៀន**-សៀវភៅនេះសំរាប់អោយគ្រូធ្វើការកត់ត្រានៅពេលសង្កេតការបង្រៀនរបស់គ្រូផ្សេងដូចជា ការកត់ត្រាអ្វីដែលគេបានរៀន...( បង្ហាញសំណៅថតចំលងទំព័រមុខ និងឧទាហរណ៍ពីរបៀបសរសេរ)

៧. **សៀវភៅទំនាក់ទំនង**-សៀវភៅនេះគ្រូមានតែមួយទេសម្រាប់សិស្សទាំងអស់គ្នា គឺគ្រូប្រើដើម្បីសរសេរបញ្ហារបស់សិស្សទៅកាន់ឪពុកម្ដាយរបស់គេដូចជា ការឈប់ដោយគ្មានមូលហេតុ។ល។ (បង្ហាញសំណៅថតចំលងទំព័រមុខ និងឧទាហរណ៍ពីរបៀបសរសេរ)

៨. **សៀវភៅប្រជុំបច្ចេកទេស**-សម្រាប់រាល់ការប្រជុំនៅថ្ងៃព្រហស្បតិ៍(សំណៅថតចំលងទំព័រមុខជាគំរូ)

៩. **តារាងផ្សេងៗដូចជា**

- តារាងវេនបោសសំអាត
- តារាងមធ្យមភាគប្រចាំខែ
- តារាងមធ្យមភាគប្រចាំឆមាស
- តារាងមធ្យមភាគប្រចាំឆ្នាំ
- តារាងកិត្តិយស
- តារាងសារពើភណ្ឌ
- តារាងបទបញ្ជាផ្ទៃក្នុង
- តារាងកម្មវិធីសិក្សា
- តារាងកាលវិភាគ

**ការពិភាក្សាជាក្រុមតូចៗ ជាមួយអ្នកសម្របសម្រួល** (៤៥ នាទី)

បន្ទាប់មកសិក្ខាកាមបំបែកជាក្រុមតូចៗ(ក្រុមនីមួយៗមានសមាជិកក្រុមអ្នកសម្របសម្រួលម្នាក់អង្គុយជាមួយពួកគេ)។ សិក្ខាកាមត្រួតពិនិត្យមើលឯកសារម្ដងមួយៗ និង ពិភាក្សាថាឯកសារនេះសំរាប់ធ្វើអ្វី បន្ទាប់មកធ្វើការសង្ខេបដាក់ក្នុងឯកសារ (**ឯកសារទី៣៥**)។

ការពិភាក្សាជាក្រុមធំ (១០-១៥ នាទី)

បន្ទាប់ពីការពិភាក្សា អ្នកសម្របសម្រួលសួរក្រុមទាំងអស់ថាតើពួកគេមានសំនួរ ឬបញ្ហា ដែលពួកគេមិនអាចដោះស្រាយបាននៅក្នុងក្រុមតូចឬទេ...ហើយពិភាក្សាបន្តទៅទៀត។

**កិច្ចការ** (២០ នាទី)

បន្ទាប់មកអ្នកសម្របសម្រួលផ្តល់អោយក្រុមនីមួយៗនូវកិច្ចការពីរដើម្បីអនុវត្តការយល់ដឹង...

**កិច្ចការទី១:** ក្រុមតូចៗត្រូវគណនាភាគរយនៃអវត្តមានសិស្សសំរាប់ខែ តុលា ឆ្នាំ២០០៥ដោយដឹងថា...

ខែតុលាមាន៣១ថ្ងៃ

មានថ្ងៃអាទិត្យចំនួន៥ និងថ្ងៃព្រហស្បតិ៍ចំនួន៤

មានការឈប់សំរាកនៅថ្ងៃច័ន្ទ ទី២៤ ខែតុលាដែលជាទិវាសន្តិភាពទីក្រុងប៉ារីស

មានសិស្ស៤៥នាក់នៅក្នុងថ្នាក់

មានសិស្ស៩នាក់អវត្តមាននៅក្នុងខែនេះ

***ចំលើយរំពឹងទុក:*** *០.៥២%*

**កិច្ចការទី២:** ចូរមើលបញ្ជីពិន្ទុហើយគណនាមធ្យមភាគនិងធ្វើចំណាតថ្នាក់មធ្យមភាគនោះ(**ឯកសារទី៣៦ B**)

សេចក្តីសន្និដ្ឋាន: អ្នកសម្របសម្រួលអោយក្រុមនីមួយៗរាយការណ៍លើបញ្ហាដែលបានជួបប្រទះនៅពេលធ្វើកិច្ចការនេះ។

**ថ្ងៃទី៩**

**ដំណាក់កាលបង្រៀនទី៨: ការរួមគ្នាទទួលខុសត្រូវលើការគ្រប់គ្រងថ្នាក់រៀន** ៣០ នាទី

**សកម្មភាព: កិច្ចការក្នុងថ្នាក់រៀន**

អ្នកសម្របសម្រួលគូរតារាងខាងក្រោម ដាក់ក្នុងផ្ទាំងក្រដាសធំ ហើយបិទនៅលើក្តារខៀន ឬចែកឯកសារនៃតារាងនេះអោយសិក្ខាកាម (**ឯកសារទី៣៧**)

| **ការងារក្នុងថ្នាក់រៀន** | **ការទទួលខុសត្រូវរបស់...** | | |
|---|---|---|---|
| | **គ្រូ** | **សិស្ស** | **ទាំងពីរ** |
| ចុះបញ្ជី | | | |

| | | | |
|---|---|---|---|
| ចែក/ប្រមូលសៀវភៅ និងក្រដាសផ្សេងៗ | | | |
| កំណត់ពេលចេញលេង/សំរាក | | | |
| ជ្រើសរើសសម្ភារ | | | |
| ផ្តល់ការសរសើរ | | | |
| សំអាតបន្ទប់រៀន | | | |
| សរសេរលើក្តារខៀន | | | |
| ប្រើសម្ភារឧបទេស | | | |
| រៀបចំសម្ភារឧបទេស | | | |
| បំលាស់ទីគ្រឿងសង្ហារឹម | | | |
| រក្សាវិន័យ | | | |
| កំណត់/បែងចែកវេនដែលត្រូវនិយាយ | | | |
| រៀបចំកិច្ចតែងការ | | | |
| បង្កើតក្រុម | | | |
| រក្សាក្តារបិទប្រកាស | | | |
| កែកិច្ចការផ្ទះ | | | |
| ផ្តល់មតិកែលំអ | | | |

អ្នកសម្របសម្រួលអោយសិក្ខាកាមបំពេញតារាងដោយធ្វើការសំរេចចិត្តទៅលើកិច្ចការក្នុងថ្នាក់រៀន រួចហើយអោយពួកគេប្រៀបធៀបជាដៃគូ។

អ្នកសម្របសម្រួលដើរត្រួតពិនិត្យដៃគូទាំងអស់។ បើសិនសិក្ខាកាមបែងចែកការងារច្រើនទៅលើគ្រូបង្រៀន ចូរធ្វើការផ្តល់ជាគំនិតថា ការងារមួយចំនួនអាចត្រូវបានរៀបចំអោយក្លាយទៅជាការទទួលខុសត្រូវរបស់សិស្ស។

## ថ្ងៃទី ១០ សាលារៀន និងសហគមន៍

| |
|---|
| ថ្ងៃទី១០<br>**ដំណាក់កាលបង្រៀនទី១: ស្ថាប័នរបស់សាលា និងគោលបំណងរបស់វានៅក្នុងសង្គម ៣០ នាទី**<br><br>អ្នកសម្របសម្រួលនិយាយថានៅថ្ងៃចុងក្រោយនេះ វគ្គបណ្តុះបណ្តាលនឹងផ្តោតទៅលើសាលារៀនដែលជាផ្នែកមួយនៃសង្គមឬសហគមន៍។<br><br>**អ្នកសម្របសម្រួលសួរសិក្ខាកាមទាំងអស់គ្នាថា: ហេតុអ្វីក៏យើងត្រូវមានសាលារៀន? តើវាមានគោលបំណងអ្វី?**<br><br>***ចំលើយរំពឹងទុក:*** *ផ្តល់ការអប់រំដល់កុមារ ផ្តល់តំរូវការសំរាប់អនាគតកាលនៅក្នុងសហគមន៍ ជួយដល់កុមារអោយមានភាពមាំមួន សុខភាពល្អ និងឆ្លាតវាងវៃ ដើម្បីរក្សាវប្បធម៌និងភាសា ដើម្បីជួយដល់កុមារអោយទទួលបាននូវបំនិននិងចំណេះដឹងដែលមានប្រយោជន៍ សំរាប់ជីវិតរស់នៅបន្តទៅអនាគត ជួយអោយកុមារចេះថែរក្សាខ្លួនរបស់គេនិងគ្រួសាររបស់គេនៅពេលគេធំឡើងដើម្បីអោយកុមារអាចរកបានប្រាក់ចំនូលច្រើននៅពេលធំឡើង កុមារអាចជ្រើសរើសអ្វីមួយដែលគេចង់ធ្វើអភិវឌ្ឍបំនិននិងកោសល្យដល់កុមារជួយផ្លាស់ប្តូរសង្គមកម្ពុជា និងធ្វើអោយប្រជាពលរដ្ឋគ្រប់រូបក្លាយទៅជាពលរដ្ឋល្អ ។ល ។*<br><br>អ្នកសម្របសម្រួលសរសេរគំនិតទាំងនោះនៅលើក្តារខៀន។ អ្នកសម្របសម្រួលអាចនឹងសួរសំនួរណាមួយ បើសិនសិក្ខាកាមរកនឹកចំលើយពុំឃើញ។ |
| ថ្ងៃទី១០<br>**ដំណាក់កាលបង្រៀនទី២: អ្នកពាក់ព័ន្ធនៅក្នុងសាលារៀន និងគោលគំនិតនៃកម្មសិទ្ធិ ៦០ នាទី**<br><br>អ្នកសម្របសម្រួលនិយាយថា អ្នកពាក់ព័ន្ធគឺជាមនុស្សទាំងឡាយណាដែលមានចំណាប់អារម្មណ៍ ចំពោះការអប់រំនិងការងាររបស់សាលារៀន។ គំនិតនៃអ្នកពាក់ព័ន្ធ គឺទាក់ទងជិតដិតទៅក្នុងដំណើរការនៃការធ្វើផែនការសាលារៀន។ អ្នកពាក់ព័ន្ធទាំងអស់មានការបារម្ភ និងមានគំនិតយោបល់ ហើយអាចរួមវិភាគទានជាមធ្យោបាយផ្សេងៗលើការងារអភិវឌ្ឍសាលារៀន។ |

អ្នកសម្របសម្រួលអោយក្រុមនីមួយៗធ្វើបញ្ជីអ្នកពាក់ព័ន្ធផ្សេងៗ រួចហើយសរសេរចូលកូឡោនទី១នៃតារាងក្នុងឯកសារដែលបានចែកជូន។ កូឡោនទី២ គឺជាចន្លោះទំនេរ ប៉ុន្តែមានចំណងជើងមួយសរសេរថា " ចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធនៅក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន..." ។

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមទាំងអស់ផ្តល់ជាគំនិតដើម្បីបំពេញកូឡោនទី២ សំរាប់អ្នកពាក់ព័ន្ធនីមួយៗ (ចំណាប់អារម្មណ៍នៅក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន) ។ អ្នកសម្របសម្រួលសរសេរគំនិតរបស់សិក្ខាកាមចូលទៅក្នុងតារាងធំនៅខាងមុខ ។

***ចំលើយរំពឹងទុក:*** *ចូរមើលតារាងខាងក្រោម*

| អ្នកពាក់ព័ន្ធ | **តើមូលហេតុអ្វីបានជាអ្នកពាក់ព័ន្ធ មានចំណាប់អារម្មណ៍ក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន?** *...ចំលើយរំពឹងទុក...* |
|---|---|
| ឪពុកម្តាយសិស្ស | *- អនាគតកូនចៅរបស់ពួកគេគឺពឹងផ្អែកលើគុណភាពអប់រំ*<br>*- ឪពុកម្តាយបានផ្តល់ជាទឹកប្រាក់ដើម្បីគាំទ្រសាលារៀន តាមរបៀបផ្សេងៗ ហើយចង់ឃើញសាលារៀនមានការរៀបចំ និងគ្រប់គ្រងបានល្អ* |
| គ្រូបង្រៀន | *- ការបង្រៀនគឺជាមុខរបររបស់ពួកគេ ហើយពួកគេចង់អោយវាមានដំណើរការល្អ*<br>*- គ្រូបង្រៀនចង់អោយមានការផ្គត់ផ្គង់ ផ្នែកសម្ភារ និងធនធានអោយបានគ្រប់គ្រាន់*<br>*- គ្រូបង្រៀនចង់បានគ្រឿងបរិក្ខាល្អៗសំរាប់ការសិក្សា* |
| នាយកសាលារៀន | *- វាគឺជាមុខរបររបស់គាត់ហើយគាត់ចង់អោយវាមានដំណើរការល្អ*<br>*-ត្រូវទទួលខុសត្រូវលើបុគ្គលិក និងសហគមន៍ដើម្បីគុណភាពអប់រំ ជាពិសេសលើការចាត់ចែង និងគ្រប់គ្រង ។* |
| សហគមន៍ | *- អនាគតរបស់សហគមន៍គឺពឹងផ្អែកលើគុណភាពអប់រំ-ពួកគេចង់ឃើញសាលារៀនរីកចំរើន ហើយមានបរិក្ខា និងធនធានគ្រប់គ្រាន់ ។* |
| គណៈកម្មការទ្រទ្រង់សាលារៀន | *- ពួកគេប្រមូលថវិកា និងធ្វើអ្វីៗផ្សេងទៀតដើម្បីជួយសាលារៀន ពួកគេចង់អោយសាលារៀនមានការគ្រប់គ្រងល្អ និងប្រើប្រាស់ធនធានប្រកបដោយ* |

| | |
|---|---|
| | *ភាពវៃឆ្លាត* |
| កុមារ | *- កុមារមកសាលារៀនជារៀងរាល់ថ្ងៃ រយៈពេល៩ខែក្នុង១ឆ្នាំ-ពួកគេចង់អោយសាលារៀនជាកន្លែងសប្បាយ ផាសុខភាព និងសុវត្ថិភាព<br>- សាលារៀនគឺជាកន្លែងសំរាប់ពួកគេសិក្សាដើម្បីអនាគត-ការសិក្សាត្រូវមានគុណភាពល្អបើមិនដូច្នោះទេ វាជាការឥតប្រយោជន៍។* |
| ក្រសួងអប់រំ | *- ផ្តល់ប្រាក់ខែអោយគ្រូបង្រៀន និងការចំណាយផ្សេងៗទៀត ពួកគេចង់ទទួលបានលទ្ធផលល្អ ជំនួសរាល់ការចំណាយ ហើយរំពឹងចង់បានការចាត់ចែង និងការគ្រប់គ្រងល្អមួយ ។* |
| អាជ្ញាធរមូលដ្ឋាន | *- ពួកគេចង់បានការគ្រប់គ្រង និងការអប់រំល្អសំរាប់កុមារនៅក្នុងឃុំ ឬស្រុករបស់ពួកគេ* |
| វត្តអារាម ព្រះសង្ឃ | *- គណៈកម្មការវត្តចំណាយទឹកប្រាក់ដើម្បីថែរក្សា និងពង្រីកសាលារៀន ហើយចង់ឃើញថាសាលារៀនមានការចាត់ចែង និងគ្រប់គ្រងល្អ ។* |
| ។ល។ | |

អ្នកសម្របសម្រួលអោយឯកសារទៅសិក្ខាកាម (**ឯកសារទី៣៨**) ដែលពួកគេអាចយកទៅកត់ត្រាចំលើយតប ។

ថ្ងៃទី១០

**ដំណាក់កាលបង្រៀនទី៣: គំនិត និងការបង្កើតភាពជាកម្មសិទ្ធ** ៦០ នាទី

អ្នកសម្របសម្រួលនិយាយថា មនុស្សគ្រប់គ្នាមានអារម្មណ៍ថាគេមានកម្មសិទ្ធទៅលើ ផ្ទះ ដីស្រែចំការ និងកង់របស់ពួកគេ។

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូល: **ហេតុអ្វីក៏មនុស្សគ្រប់គ្នាមានអារម្មណ៍ទៅលើភាពជាកម្មសិទ្ធ?**

***ចំលើយរំពឹងទុក:*** *មនុស្សជាធម្មតាមានអារម្មណ៍ជាកម្មសិទ្ធិនៅពេលពួកគេ ទទួលមរតិកអ្វីមួយពីគ្រួសាររបស់គេឬទិញ ឬចំណាយប្រាក់ទៅលើអ្វីមួយ* ***<u>រួចហើយធ្វើការសម្រេចចិត្តលើអ្វីៗទាំងនោះ ។</u>***

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូល: **តើមនុស្សសំដែងអាកប្បកិរិយាចំពោះវត្ថុដែលគេមានអារម្មណ៍ជាកម្មសិទ្ធិដោយរបៀបណា?**

***ចំលើយរំពឹងទុក:*** *ពួកគេថែរក្សា ជួសជុលនៅពេលខូចឬបែកបាក់ ប្រើប្រាស់វត្ថុនោះច្រើនជាងនិងទទួលខុសត្រូវថែ*

*រក្សាអោយមានសភាពលក្ខណៈល្អ ។*

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូលទៀតថាៈ **តើអ្វីដែលធ្វើអោយអារម្មណ៍ជាកម្មសិទ្ធិកាន់តែខ្សោយទៅៗ?**
***ចំលើយរំពឹងទុកៈ*** *បើសិនជាអ្នកចំណាយលុយទៅលើអ្វីមួយ រួចហើយមានអ្នកផ្សេងប្រើប្រាស់វត្ថុនោះគ្រប់ពេល ដោយមានទាំងធ្វើការសម្រេចចិត្តផ្សេងៗទៅលើវត្ថុនោះ នាំអោយអារម្មណ៍ជាកម្មសិទ្ធិរបស់អ្នកកាន់តែតិចទៅៗ ហើយអាចនឹងបាត់បង់ទាំងស្រុង ។ មនុស្សទាំងអស់ត្រូវចូលរួមអោយបានសកម្មនៅក្នុងការងារអ្វីមួយ ឬធ្វើការសម្រេចចិត្តអំពីវត្ថុនោះដើម្បីអោយអារម្មណ៍កម្មសិទ្ធិពិតប្រាកដកើតមាន ។*

អ្នកសម្របសម្រួលសួរថ្នាក់ទាំងមូលៈ **តើគ្រូបង្រៀន ឪពុកម្តាយសិស្ស និងសមាជិកសហគមន៍ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា មានអារម្មណ៍ជាកម្មសិទ្ធិទៅលើសាលារៀននៅក្នុងមូលដ្ឋានដែរឬទេ?**
*ចំលើយអាចជា " បាទ/ចាស់ " ឬ " ទេ "*

បន្ទាប់មកអ្នកសម្របសម្រួលសួរបន្តទៀតថាៈ **បើសិនគេពិតជាមានអារម្មណ៍ជាកម្មសិទ្ធិ តើយើងរំពឹងចង់ឃើញអ្វី?**
***ចំលើយរំពឹងទុកៈ***

- *បុគ្គលិកសាលារៀនប្រឹងប្រែងធ្វើការបានល្អ*
- *ការរួមវិភាគទានទឹកប្រាក់/មូលនិធិ*
- *ការចូលរួមធ្វើពលកម្ម*
- *ផ្តល់អំណោយជាសម្ភារ*
- *ផ្តល់ការគាំទ្រក្នុងការពង្រីកបរិស្ថានសាលារៀន*
- *លើកទឹកចិត្តកុមារអោយចូលសាលារៀន កុំអោយគេចសាលារៀន*
- *ជួយពង្រឹងកុមារបន្ថែម ដោយផ្តល់ជាកិច្ចការធ្វើនៅផ្ទះ ។*

ថ្ងៃទី១០

**ដំណាក់កាលបង្រៀនទី៤ៈ អភិបាលកិច្ចល្អ-ការទទួលខុសត្រូវ តម្លាភាព** ៦០ នាទី

អ្នកសម្របសម្រួលនិយាយថាៈ អម្បាញ់មិញសិក្ខាកាមបានគិតអំពីបញ្ញត្តិនៃអ្នកពាក់ព័ន្ធនិងភាពជាកម្មសិទ្ធិ ហើយឥឡូវនេះយើងចង់និយាយអំពីការទទួលខុសត្រូវរបស់សាលារៀនចំពោះសហគមន៍ ។គំនិតសំខាន់ពីរដែលយើងចង់ផ្តោតទៅលើគឺ **ការទទួលខុសត្រូវនិងតម្លាភាព** ។ គំនិតទាំងនេះគឺជាផ្នែកមជ្ឈការមួយនៃកំនែទំរង់ការអប់រំរបស់ក្រសួងអប់រំ ។

អ្នកសម្របសម្រួលចែកឯកសារ (**ឯកសារទី៣៩**)ដែលសង្ខេបគំនិតទាំងពីរនេះថាជាគោលការណ៍នៅក្នុងចំណោមគោលការណ៍ទាំង៤នៃអភិបាលកិច្ចល្អ។ សិក្ខាកាមគួរតែអានកថាខ័ណ្ឌពីរដែលបានបង្ហាញយ៉ាងច្បាស់និងពិភាក្សាជាមួយលោក/ លោកស្រីដែលនៅក្បែរ។

បន្ទាប់ពីសិក្ខាកាមអានឯកសារ អ្នកសម្របសម្រួលសួរសិក្ខាកាមអោយផ្តល់ជាយោបល់លើនិយមន័យនៃពាក្យ **ការទទួលខុសត្រូវ** ។

បន្ទាប់មកអ្នកសម្របសម្រួលប្រើប្រាស់វត្ថុប្រៀបធៀបពីរដើម្បីពន្យល់ពីបញ្ញត្តិនៃពាក្យតម្លាភាព (១) កញ្ចក់បង្អួច (២) ត្រីនៅក្នុងទឹកថ្លា និងទឹកល្អក់។ បន្ទាប់ពីសកម្មភាពនេះអ្នកសម្របម្រួលអោយសិក្ខាកាមផ្តល់និយមន័យនៃពាក្យ**តម្លាភាព**។

អ្នកសម្របសម្រួលនិយាយថាហេតុផលផ្សេងទៀត តម្លាភាពគឺជាគោលការណ៍ដឹកនាំនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុពីព្រោះវាបង្កើននូវជំនឿទុកចិត្តរបស់អ្នកពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសាលារៀន និងអារម្មណ៍នៃភាពជាកម្មសិទ្ធិ។ អ្នកពាក់ព័ន្ធដែលមានជំនឿទុកចិត្តលើភាពស្មោះត្រង់ និងការបើកចំហរនៃការគ្រប់គ្រងហិរញ្ញវត្ថុគឺហាក់ដូចជាមានការរួមចំណែកច្រើនទៅដល់សាលារៀនតាមរយៈមធ្យោបាយផ្សេងៗ។ កង្វះខាតតម្លាភាពនាំអោយមានការមិនទុកចិត្ត ការសង្ស័យ និងការមិនគាំទ្រ។ សិក្ខាកាមអានឯកសារ។

អ្នកសម្របសម្រួលសន្និដ្ឋានដោយសួរសិក្ខាកាមក្នុងថ្នាក់ទាំងមូលៈ **តើគ្រូបង្រៀនអាចជួយសាលារៀនដើម្បីបង្កើនការទទួលខុសត្រូវ និងតម្លាភាពដោយរបៀបណា?**
***ចំលើយរំពឹងទុកៈ*** *ដោយការរាយការណ៍ទៅកាន់ឪពុកម្តាយសិស្ស ដោយនិយាយទៅកាន់ឪពុកម្តាយសិស្សអំពីដំណើរការនៃការសិក្សារបស់គេដោយនិយាយទៅកាន់ឪពុកម្តាយសិស្សអំពីសមិទ្ធផលដែលសាលារៀនសម្រេចបាន តម្រូវការបន្តទៀត និងបញ្ហាដែលកើតមានឡើងដោយការចូលរួមនិងការប្រជុំធ្វើផែនការរវាងសាលារៀន និងសហគមន៍ ដោយការស្វែងរកឯកសារអានអំពីការគ្រប់គ្រងសាលារៀន និងការធ្វើផែនការដោយការស្វែងរក ការអាន និងការស្វែងយល់ពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាលារៀន...។*

ថ្ងៃទី១០

**ដំណាក់កាលបង្រៀនទី៥: ការចូលរួមរបស់សហគមន៍ នៅក្នុងអភិបាលកិច្ចសាលារៀន (SSC, PAP) ៦០ នាទី**

ឯកសាររបស់លោកអៀ អ៊ិន អំពីរគណៈកម្មការទ្រទ្រង់សាលារៀន និងកម្មវិធីសកម្មភាពជាអាទិភាព (**ឯកសារទី៤០**) ។

អ្នកសម្របសម្រួលសួរសិក្ខាកាមក្នុងថ្នាក់ទាំងមូលៈ តើមានមធ្យោបាយចំបងៗអ្វីខ្លះដែលសាលារៀនប្រើដើម្បីរាយការ-ណ៍ទៅកាន់សមាជិកសហគមន៍អំពីអ្វីដែលខ្លួនបានកំពុងធ្វើ?

***ចំលើយរំពឹងទុក:*** *តាមរយៈគណៈកម្មការសាលារៀន ដែលជាធម្មតាគេហៅថាគណៈកម្មការទ្រទ្រង់សាលារៀន ឬតាមគណៈកម្មការផ្សេងៗទៀតនៅតាមវត្តអារ៉ាមឬតាមរយៈរដ្ឋបាលមូលដ្ឋាន ។*

អ្នកសម្របសម្រួលនិយាយថាៈ ត្រឹមត្រូវហើយ ។ វាគឺជាច្បាប់របស់ក្រសួងអប់រំដែលនាយកសាលារៀនត្រូវតែពិភាក្សាបញ្ហាដែលទាក់ទងនឹងការអភិវឌ្ឍន៏សាលារៀនជាមួយគណៈកម្មការនេះ ។ ក្រសួងអប់រំផ្តល់ប្រាក់ទៅអោយសាលារៀនរាល់ឆ្នាំនីមួយៗតាមរយៈកម្មវិធីសកម្មភាពជាអាទិភាព ។ សាលារៀនអាចទទួលបានប្រាក់នេះនៅពេលដែលខ្លួនបានប្រគល់ផែនការពីរបៀបប្រើប្រាស់ប្រាក់ទៅកាន់ការិយាល័យអប់រំស្រុក ។ ផែនការនេះត្រូវមានការយល់ព្រមពីនាយកសាលារៀន លោកគ្រូ/អ្នកគ្រូ និងគណៈកម្មការទ្រទ្រង់សាលារៀន ពោលគឺត្រូវមានការចុះហត្ថលេខាដោយនាយកសាលារៀន និងប្រធានគណៈកម្មការទ្រទ្រង់សាលារៀន បើមិនដូច្នោះទេសាលារៀនមិនអាចទទួលបានប្រាក់ឡើយ ។

អ្នកសម្របសម្រួលនិយាយបន្តទៀតៈ បើសិនជាអ្នកចូលទៅក្នុងសាលារៀនជាច្រើននៅក្នុងប្រទេសកម្ពុជា អ្នកនឹងបានឃើញផ្ទាំងក្រដាសរ៉ាមធំនៅលើជញ្ជាំងនៃបន្ទប់របស់បុគ្គលិក និងទីចាត់ការនាយក ដែលបង្ហាញពីចំនួនទឹកប្រាក់ PAP ទទួលបាន និងផែនការចំណាយទឹកប្រាក់នោះ ។ នាយកសាលារៀនក៏ត្រូវរាយការណ៍ទៅកាន់គណៈកម្មការទ្រទ្រង់សាលារៀនអំពីរបៀបដែលបានចំណាយប្រាក់ជាក់ស្តែង និងត្រូវបញ្ជូនវិក័យប័ត្រទៅការិយាល័យអប់រំស្រុកដើម្បីអនុម័ត ។ នៅពេលកិច្ចការទាំងនេះមានដំណើរការល្អ យើងអាចនិយាយថាសាលារៀនមានការទទួលខុសត្រូវ និងមានតម្លាភាព ។

អ្នកសម្របសម្រួលនិយាយថា គាត់នឹងផ្តល់ឯកសារអំពីរគណៈកម្មការទ្រទ្រង់សាលារៀន និងតួនាទីនៅក្នុងការធ្វើផែន-ការអភិវឌ្ឍសាលារៀន ព្រមទាំងការគ្រប់គ្រងប្រាក់ PAP ។ អ្នកសម្របសម្រួលរៀបចំសិក្ខាកាមជាក្រុមដើម្បីអានឯកសារ និងឆ្លើយសំនួរខាងក្រោម (ចូរកត់ត្រាចំលើយ តែមិនបាច់សរសេរលើផ្ទាំងក្រដាសរ៉ាមធំទេ):

**១.តើនរណាខ្លះជាសមាជិករបស់គណៈកម្មការទ្រទ្រង់សាលារៀន?**

**២.តើគណៈកម្មការទ្រទ្រង់សាលារៀនគួរជួបប្រជុំគ្នានៅពេលណា ហើយឯកសារអ្វីខ្លះដែលគណៈកម្មកានោះ**

ត្រូវរក្សាទុក?

៣.តើគណៈកម្មការនេះមានតួនាទីនិងភារកិច្ចសំខាន់ៗអ្វីខ្លះនៅក្នុងប្រាក់ **PAP**?

***ចំលើយរំពឹងទុកៈ***

*១. ប្រធានកិត្តិយស (ចៅអធិការវត្ត/អាជ្ញាធរដែនដី)*

*ប្រធាន ( អ្នកមានឥទ្ធិពល/អ្នកមុខអ្នកការ)*

*អនុប្រធាន ( នាយក/នាយករង)*

*ហិរញ្ញឹក ( លោកគ្រូ/អ្នកគ្រូ ឬមាតាបិតាសិស្សដែលស្មោះត្រង់)*

*សមាជិក ( តំណាងមាតាបិតាសិស្សចំនួន២-៥នាក់)*

*២. គណៈកម្មការទ្រទ្រង់សាលារៀនជួបប្រជុំគ្នាពរដងក្នុង១ឆ្នាំគឺនៅដើមឆ្នាំសិក្សា ដំណាច់ឆមាសទី១ និងនៅចុងឆ្នាំសិក្សា ។ ហើយគណៈកម្មការនេះត្រូវរក្សាទុកឯកសារសំខាន់ៗមួយចំនួនដូចជាៈ*

*-ឯកសារដែលបង្កើតគណៈកម្មការនេះ*

*-ស្ថិតិសិស្សនៅក្នុងភូមិជាចំណុះរបស់សាលារៀន និងប្រជាជន*

*-ឯកសារស្តីពីការចំណាយសំខាន់ផ្សេងៗរបស់សាលារៀន*

*-រក្សាទុកផែនទីសិក្សាកុមារតាមភូមិ*

*-ឯកសារស្តីពីលទ្ធផលសិក្សាដំណាច់ឆ្នាំសិក្សានីមួយៗ*

*-កំណត់ហេតុនៃការប្រជុំផ្សេងៗ*

*៣. -ផ្សព្វផ្សាយដល់សហគមន៍មាតាបិតាសិស្សអំពីគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈ ការអោយសិស្សចូលរៀនដោយមិនបង់ថ្លៃសិក្សា និងខ្លឹមសារកម្មវិធីសកម្មភាពជាអាទិភាព និងការចូលរួមរបស់ សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន*

*-ចូលរួមកសាងផែនការអភិវឌ្ឍសាលារៀន*

*-ចូលរួមត្រួតពិនិត្យការប្រើប្រាស់ថវិកា*

*-ចូលរួមជំរុញការលើកទឹកចិត្តដល់ នាយក គ្រូ សិស្ស*

*-ចូលរួមផ្តល់យោបល់គ្រប់សកម្មភាពអភិវឌ្ឍសាលារៀន*

*-រិះរកមធ្យោបាយសាងសង់ផ្សេងៗដោយប្រើប្រាស់ថវិកាកម្មវិធីសកម្មភាពជាអាទិភាព ។*

បន្ទាប់ពីការពិភាក្សាអ្នកសម្របសម្រួលអោយក្រុមនីមួយៗផ្តល់ចំលើយ ។ ក្រុមផ្សេងអាចបន្ថែមគំនិតពិស្តារបើសិនជាពួកគេចង់ ។

ថ្ងៃទី១០

**ដំណាក់កាលបង្រៀនទី៦: គណៈកម្មការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ អាជ្ញាធរមូលដ្ឋាន និងការអប់រំ ៦០ នាទី**

**សេចក្តីផ្តើម** (១៥នាទី)

អ្នកសម្របសម្រួលនិយាយថា: ចាប់តាំងពីមានសន្និសិទ្ធិអន្តរជាតិស្តីអំពីការអប់រំសំរាប់ទាំងអស់គ្នានៅ Jomtiem និងនៅពេលថ្មីៗនេះនៅ Dakar ដែលមាន១១៦ប្រទេសបានចូលរួម រួមទាំងប្រទេសកម្ពុជាផងនោះ បានសន្យាថាកុមារគ្រប់រូបនឹងត្រូវបានទទួលការអប់រំជាមូលដ្ឋានប្រកបដោយគុណភាពនៅឆ្នាំ២០១៥។ ដូចបណ្តាប្រទេសដទៃទៀតដែរ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការធានាអោយកុមារកម្ពុជាមានសិទ្ធិទទួលការអប់រំពេញលេញ និងធ្វើអោយសម្រេច គោលដៅនៃការអប់រំសំរាប់ទាំងអស់គ្នា។ ទោះបីជាយ៉ាងនេះក្តី នៅតែមានគំលាតគួរអោយកត់សំគាល់រវាងគោលនយោបាយអប់រំ និងការអនុវត្តជាក់ស្តែង។ កត្តាចំបងៗមួយចំនួន ទាំងកត្តាផ្គត់ផ្គង់ និងកត្តាតំរូវការ នៅតែបន្តធ្វើអោយរាំងស្ទះដល់គុណភាពអប់រំទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាលរួមមានការខ្វះខាតគ្រូបង្រៀន កម្មវិធីសិក្សាមិនទាន់ឆ្លើយតបទៅនឹងការរស់នៅជាក់ស្តែងពេញលេញ ភាពងាយស្រួលក្នុងការចូលសាលារៀននៅមានកំរិត ដោយសារការចំណាយផ្ទាល់ និងមិនផ្ទាល់របស់មាតាបិតាលើការសិក្សារបស់កូន និងការយល់ឃើញរបស់សហគមន៍មិនទាន់អោយតំលៃខ្ពស់ទៅលើការអប់រំ។

អ្នកសម្របសម្រួលនិយាយបន្តទៀតថា: គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំត្រូវបានបង្កើតឡើងជាផ្លូវការដោយលេខាធិការដ្ឋានអប់រំសំរាប់ទាំងអស់គ្នានៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងគោលបំណងអោយគណៈកម្មាធិការនេះចូលរួមសកម្មក្នុងការសម្រេចគោលដៅការអប់រំសំរាប់ទាំងអស់គ្នានៅឆ្នាំ២០១៥។ ដូច្នោះគណៈកម្មាធិការនេះគឺតំណាងអោយសំលេងរបស់សមាជិកសហគមន៍ និងតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល ដូចជាអេស្កាប់នេះ រួមទាំងជាមួយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សេវាអប់រំដែលមានគុណភាព ឆ្លើយតបទៅនឹងតំរូវការរៀន សូត្ររបស់កុមារទាំងអស់។ ដើម្បីធ្វើដូច្នេះបាន គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ ក៏ដូចជាសមាគមមាតា បិតាសិស្ស គួរឈានទៅបំពេញតួនាទីបន្ថែមទៀតក្រៅពីអ្វីដែលធ្លាប់បានធ្វើកន្លងមក ដូចជាការសាងសង់អាគារជាដើម។ ការផ្ទេរអំណាចតាមរយៈ ការផ្តល់នូវចំណេះដឹង និងបំនិន អាចអោយពួកគេធ្វើការជាមួយអ្នកពាក់ព័ន្ធជាច្រើនទៀត ដើម្បីដោះស្រាយផ្នែកនានានៅក្នុងប្រព័ន្ធអប់រំក្នុងនោះរួមមាន ធនធាន ដំណើរការ ខ្លឹមសារ និងគុណភាព។

បន្ទាប់មកអ្នកសម្របសម្រួលអោយសិក្ខាកាមធ្វើការជាក្រុមដើម្បីអានឯកសារ (**ឯកសារទី៤១**) រួចឆ្លើយសំនួរខាងក្រោម (៤៥ នាទី):

១. តើនរណាខ្លះជាសមាជិកនៅក្នុងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ?

២. តើគណៈកម្មាធិការនេះមានតួនាទីនិងភារកិច្ចអ្វីខ្លះនៅក្នុងមូលដ្ឋានរបស់ខ្លួន?

បន្ទាប់ពីឆ្លើយសំនួរចប់ក្រុមនីមួយៗឡើងរាយកាណ៍ ហើយអ្នកសម្របសម្រួលផ្តល់យោបល់បន្ថែមបើចាំបាច់។

*ចំលើយរំពឹងទុក:*

*១.*

- *មេឃុំ*
- *ក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកសេវាអប់រំ*
- *នាយក និងនាយករងវិទ្យាល័យឬអនុវិទ្យាល័យ*
- *នាយកសាលាបឋមសិក្សា២នាក់ក្នុងមួយឃុំ*
- *ប្រធានកម្រងសាលារៀន*
- *គ្រូបង្គោលឃុំ*
- *មេភូមិ*

*២.*

- *រៀបចំផែនការអភិវឌ្ឍកម្មវិធីអប់រំសំរាប់ទាំងអស់គ្នាអោយបានសមស្របតាមគោលដៅរបស់ជាតិ ខេត្ត/ ក្រុង ស្រុក/ខ័ណ្ឌ និង ស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន*
- *បំផុសស្មារតីរបស់ប្រជាពលរដ្ឋនិង អ្នកដឹកនាំនៅក្នុងមូលដ្ឋានអោយចូលរួមក្នុងកម្មវិធីអោយបានច្រើន*
- *កៀរគរ និង ប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋាន*
- *សម្របសម្រួលជាមួយគ្រឹះស្ថានសិក្សានានា និង ភ្នាក់ងារមូលដ្ឋានដទៃទៀត*
- *ធ្វើការប្រជុំតាមការចាំបាច់ ដើម្បីវាយតំលៃការងារដែលបានដាក់ចុះ*
- *ចុះតាមដានវាយតំលៃសកម្មភាពអប់រំសំរាប់ទាំងអស់គ្នាតាមភូមិជាប្រចាំ*
- *រៀបចំរបាយការណ៍ជាទៀងរាល់ខែផ្ញើជូនគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ស្រុក/ខណ្ឌ*

ថ្ងៃទី១០

ដំណាក់កាលទី៧: ការបិទវគ្គបណ្តុះបណ្តាល